ក្រសួងអប់រំយុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

# របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា
# ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

# ចំណូលពីការប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ

Revenue From Tax Collection of the General Department of Taxation

**ជំនាញៈ ពន្ធដារ**

**រៀបរៀងដោយ៖ សយ ចិត្រា**

**អត្តលេខៈ** MA20/033

**ឆ្នាំសិក្សា ៖ ឆ្នាំ២០២២ - ២០២៤**

ក្រសួងអប់រំយុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

# របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា
# ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

# ចំណូលពីការប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ

Revenue From Tax Collection of the General Department of Taxation

ជំនាញ: ពន្ធដារ

សាស្ត្រាចារ្យណែនាំ ៖ បណ្ឌិត កង ឱម

បេក្ខបណ្ឌិត យ៉ាក ឧទ្ធី

ឆ្នាំសិក្សា ៖ ឆ្នាំ២០២២ - ២០២៤

**គណៈកម្មការត្រួតពិនិត្យរបាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា**
**ប្រធានបទ៖ ចំណូលពីការប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ**

សាស្ត្រាចារ្យណែនាំ

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

សាស្ត្រាចារ្យណែនាំ

បណ្ឌិត កង ឱម

គណៈកម្មការអភិវឌ្ឍន៍កម្មវិធីសិក្សា និងស្រាវជ្រាវ
ប្រធាន

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

ប្រធានមជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

**នាយកវិទ្យាស្ថាន**

**បណ្ឌិត ហេង វ៉ាន់ដា**

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញពន្ធដារ វិទ្យាស្ថាន វ៉ាន់ដា អស់រយៈពេល២ ឆ្នាំសិក្សារួចមកហើយនាងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ពាក់ព័ន្ធនឹងមុខវិជ្ជាសវនកម្មជាពិសេសរូបនាងខ្ញុំយល់ច្បាស់ថាជំនាញពន្ធ គឺជាជំនាញមួយមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ទីផ្សារបច្ចុប្បន្នក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តីសុទ្ធតែត្រូវអនុវត្តកិច្ចការសវនកម្ម ដើម្បីប្រសិទ្ធភាពការងាររបស់ខ្លួន។ ដោយឡែកដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ វិទ្យាស្ថាន វ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងារសវនកម្មតាមកម្មវិធីសិក្សាទៅតាមកម្រិតថ្នាក់ក្នុង ឆ្នាំសិក្សាទីមួយរហូត ដល់ឆ្នាំសិក្សាទីពីដែលត្រូវបានបញ្ចប់ការសិក្សា។

គ្រប់មុខវិជ្ជាទាំងអស់សុទ្ធតែជាយានសម្រាប់ស្សិតយកទៅប្រើប្រាស់នៅក្នុងវិស័យការងារដែលមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិត ឱ្យយល់ច្បាស់ពីការអនុវត្តសវនកម្មពីការចាប់ផ្តើមរៀបចំផែនការការអនុវត្តការបញ្ចប់និងត្រួតពិនិត្យវាយតម្លៃព្រមទាំងផ្តល់ជា អនុសាសន៍នៅក្នុងការងារសវនកម្ម ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយនាងខ្ញុំសង្កេតឃើញថាកិច្ចការងារមួយនេះមាន សារៈសំខាន់ខ្លាំងស្របពេលនៃការសរសេររបាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់បានមកដល់ទើបនាងខ្ញុំ ធ្វើការសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី "ចំណូលពីការប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ" យកមកធ្វើការសិក្សាស្រាវជ្រាវនិងចងក្រងក្នុងគោលបំណងឱ្យ អ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅអំពីការរៀបចំ
គម្រោង។ នាងខ្ញុំសង្ឃឹមថាការរៀបចំរបាយការណ៍ស្រាវជ្រាវនេះនឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗព្រមទាំងអ្នកស្រាវជ្រាវដ៏ទៃទៀតដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការរៀបចំគម្រោង។

ជាទីបញ្ចប់នាងខ្ញុំ សូមមេត្តាខន្តីអភ័យទោសពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនានៅក្នុងរបាយការណ៍ស្រាវជ្រាវនេះ ហើយនាងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនាដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំ **សយ ចិត្រា** ភេទស្រីជានិស្សិតនៃវិទ្យាស្ថាន វ៉ាន់ដា ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់ទី២០ ជំនាញពន្ធដារ

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ៖**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភគាំទ្រទាំងសម្ភារ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់រូបនាងខ្ញុំក្នុងការសិក្សារៀនសូត្រដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះនាងខ្ញុំសូមសំដែងនូវការគោរព និងកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតដល់អ្នកមានគុណទាំងពីរ ដែលបានផ្តល់កំណើតដល់រូបនាងខ្ញុំនិងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្តាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ទាំងអស់ដែលបានបណ្តុះបណ្តាលរូបនាងខ្ញុំនាពេលកន្លងមក។

នាងខ្ញុំសូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅ ដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ានដា** នាយកនៃវិទ្យាស្ថាន វ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់នាងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះសាស្ត្រាចារ្យបណ្ឌិត **កង ឱម** ជាសាស្ត្រាចារ្យដឹកនាំ ការស្រាវជ្រាវ និងសាស្ត្រាចារ្យ **យ៉ាក វុទ្ធី** ជាសាស្ត្រាចារ្យត្រួតពិនិត្យ ដោយបានជួយជ្រោមជ្រែង បង្ហាត់បង្ហាញសព្វបែបយ៉ាងដើម្បីជួយដល់រូប ខ្ញុំបញ្ចប់ កិច្ចការស្រាវជ្រាវនេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ និងបុគ្គលិកនៃវិទ្យាស្ថាន វ៉ាន់ដាទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់នាងខ្ញុំ រហូតធ្វើឱ្យការ សិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ រូបនាងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យ ជួបតែពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

នាងខ្ញុំ **សយ ចិត្រា** ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ ជំនាញពន្ធដារ នៃវិទ្យាស្ថាន វ៉ាន់ដា ជំនាន់ទី ២០។

សូមធានាអះអាងថាខ្លឹមសារស្រាវជ្រាវក្រោមប្រធានបទ "ចំណូលពីការប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ" នេះគឺជាស្នាដៃរបស់រូបនាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ ដែលលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើ ប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃ២៥៦៧ .ស.ឆ្នាំថោះ បញ្ចស័ក ព...............ខែ.................

ភ្នំពេញ ថ្ងៃទី..........ខែ............ឆ្នាំ២០....

**ហត្ថលេខា**

**សយ ចិត្រា**

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

អគ្គនាយកដ្ឋានពន្ធដារដំបូងឡើយមានឈ្មោះថា នាយកដ្ឋានពន្ធដារ បានបង្កើតឡើងក្នុងឆ្នាំ១៩៥៣ តែត្រូវបានលុបបំបាត់វិញក្នុងរបបប្រល័យពូជសាសន៍ក្នុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ក្រោយរបបប្រល័យពូជសាសន៍ត្រូវបានដួលរលំ នាយកដ្ឋានពន្ធដារបានបង្កើតឡើងវិញក្នុងឆ្នាំ១៩៨០ បន្ទាប់មកនាយកដ្ឋានពន្ធដារបានដំឡើងឈ្មោះទៅជាអគ្គនាយកដ្ឋានពន្ធដារក្នុងឆ្នាំ២០០៨ រហូតមកដល់បច្ចុប្បន្ន ស្ថិតក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ បន្ទាប់ពីទទួលបាននូវតារាងខាងលើដែលបង្ហាញពីចំណូលពន្ធរយៈពេលដប់ឆ្នាំ បន្តបន្ទាប់គ្នាមកយើងសង្កេតឃើញថាចំណូលពន្ធគឺមានការកើនឡើងជាលំដាប់រៀងរាល់ឆ្នាំ។ ដោយជាមធ្យមមានកំណើនប្រមាណ ១២២,៥៤% ក្នុងមួយឆ្នាំ ដែលក្នុងនោះឃើញថាក្នុងឆ្នាំ២០២១សម្រេចបានកំណើនច្រើនជាងគេដែលកើនដល់ទៅ ១២៤,០២% ឯឆ្នាំ២០២២ កើនបានត្រឹមតែ ១២២,៥៤% ប៉ុណ្ណោះដោយសារការរងផលប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ចក្នុងឆ្នាំ២០២២។

តាមការពិតការបង់ពន្ធវាគឺជាការចូលរួមចំណែកក្នុងថវិកាជាតិដើម្បីឱ្យ រដ្ឋមានលុយយកទៅចំណាយដោយមិនចាំបាច់បោះពុម្ពលុយដែលអាចបង្កឲ្យមានបញ្ហាអតិផរណា។ សម្រាប់កម្ពុជាការបង្កើនចំណូលពីការបង់ពន្ធ គឺជាគន្លឹះដ៏សំខាន់មួយដើម្បីឈានទៅបញ្ឈប់ការពឹងផ្អែកលើជំនួយពីបរទេស។ សម្រាប់អ្នកបង់ពន្ធ ថ្វីដ្បិតតែពន្ធនេះមិនមានការកំណត់អំពីសេវាណាមួយជាថ្នូរមកវិញជាក់លាក់ក៏ពិតមែនក៏ប៉ុន្តែ គេអាចទទួលបានផលប្រយោជន៍ជាច្រើនដោយផ្ទាល់ឬ ដោយប្រយោលពីការបង់ពន្ធនេះពីព្រោះថាលុយដែលបានពីការបង់ពន្ធនេះនឹងត្រូវយកទៅចំណាយទៅលើការបើកប្រាក់បៀវត្សដល់មន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធដែលជាអ្នកទទួលបន្ទុកផ្តល់សេវារដ្ឋបាល ការពារសន្តិសុខ សណ្តាប់ធ្នាប់និងការពារអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់ប្រទេស។

# មាតិកា

ទំព័រ


អារម្ភកថា ........................................ i
សេចក្តីថ្លែងអំណរគុណ ........................................ ii
អំណះអំណាង ........................................ iii
សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........................................ iv


## ជំពូកទី១
## សេចក្តីផ្តើម


១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........................................ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........................................ ២
១.៣ គោលបំណងនៃការស្រាវជ្រាវ ........................................ ២
១.៤ ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ ........................................ ៣
១.៥ វិធីសាស្ត្រស្រាវជ្រាវ ........................................ ៣
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........................................ ៤
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........................................ ៤


## ជំពូកទី២
## រំលឹកទ្រឹស្តី


២.១ លក្ខណៈទូទៅនៃពន្ធ ........................................ ៥
២.១.១ និយមន័យពន្ធ ........................................ ៥
២.១.២ ប្រវត្តិពន្ធ ........................................ ៦
២.១.៣ ប្រភេទពន្ធ ........................................ ៧
២.២ ចំណូលដែលទទួលបានពីការប្រមូលពន្ធ ........................................ ១០
២.២.១ និយមន័យចំណូល ........................................ ១០
២.២.២ សារៈសំខាន់នៃការប្រមូលចំណូលពន្ធ ........................................ ១០
២.២.៣ ប្រភេទចំណូលពន្ធ ........................................ ១១
២.២.៤ ច្បាប់និងបទបញ្ញត្តិស្តីពីពន្ធដារពាក់ពន្ធដារ ........................................ ១១
២.៣ នីតិវិធីនៃការប្រមូលចំណូលពន្ធ ........................................ ១៤
២.៣.១ និយមន័យនីតិ ........................................ ១៤
២.៣.២ ប្រភពនីតិ ........................................ ១៤
២.៣.៣ តួនាទីនីតិ ........................................ ១៥

# ជំពូកទី៣
# លទ្ធផលនៃការសិក្សាស្រាវជ្រាវ

៣.១ ស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ ........ ១៧
៣.១.១ សញ្ញាសម្គាល់........ ១៧
៣.១.២ ប្រវត្តិនិងទីតាំងភូមិសាស្ត្រ........ ១៧
៣.១.៣ អគ្គនាយកដ្ឋានពន្ធដារតួនាទី និងភារៈកិច្ច........ ១៨
៣.១.៤ រចនាសម្ព័ន្ធអគ្គនាយកដ្ឋានពន្ធដារ ........ ១៨
៣.១.៥ ទស្សនៈវិស័យ និងបេសកកម្ម ........ ២១
៣.២ ចំណូលពីការប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ........ ២១
៣.២.១ ការប្រមូលចំណូលពន្ធដារ........ ២១
៣.២.១.១ ចំណូលថ្នាក់ជាតិ ........ ២១
៣.២.១.២ ចំណូលថ្នាក់ក្រោមជាតិ........ ២៨
៣.៣ នីតិវិធីនៃការប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ........ ៣៣
៣.៣.១ នីតិវិធីនៃការប្រមូលចំណូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ........ ៣៣

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង........ ៤០
៤.២ ការវិភាគលើចំណុចខ្សោយ........ ៤១

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន........ ៤២
៥.២ ការផ្តល់អនុសាសន៍........ ៤៣
ឯកសារយោង
ឧបសម្ព័ន្ធ

# ជំពូកទី ១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលមានរបបដឹកនាំវិវត្តន៍ពីសម័យកាលមួយទៅសម័យកាលមួយ ដែលមានសេដ្ឋកិច្ចនយោបាយច្បាប់ និងការគ្រប់គ្រងទៅតាមព្រឹត្តិការណ៍ដែលផ្លាស់ប្តូរនិងកើតមានឡើង នៅក្នុងសម័យកាលនីមួយៗ។ ក្នុងនោះទៀតប្រទេសកម្ពុជាក៏បានបង្កើតឱ្យមាននូវប្រព័ន្ធពន្ធឡើងគឺក្នុង គោលបំណងប្រមូលពន្ធពីប្រជាពលរដ្ឋដើម្បីលើកស្ទួយដល់សេដ្ឋកិច្ចជាតិឱ្យមានការរីកចម្រើននោះក្តី។ ម្យ៉ាងវិញទៀតយើងឃើញថាប្រព័ន្ធពន្ធដារនៅកម្ពុជាក៏ មានការប្រែប្រួលទៅតាមសម័យកាលដឹកនាំផ្សេងៗ គ្នាតួយ៉ាងសំខាន់ដូចជានៅក្នុងនោះសម័យកាលដែលប្រទេសកម្ពុជាស្ថិតនៅក្រោមរបបអាណានិគមនិយម បារាំងដែលបានយកពន្ធទៅមនុស្សនិង សត្វពាហនៈ ដីធ្លី ស្រែ ចម្ការ ផ្ទះសម្បែងជាដើម។ល។

ដោយឡែកនៅពេលបច្ចុប្បន្ននេះប្រព័ន្ធពន្ធដារនៅកម្ពុជា ត្រូវបានធ្វើកំណែទម្រង់យ៉ាងស៊ីជម្រៅទៅ លើគោលនយោបាយសារពើពន្ធនិងរដ្ឋបាលសារពើពន្ធព្រមទាំងបែបបទការងារសំដៅពង្រឹងដល់ គ្រប់គ្រង ការប្រមូលពន្ធឱ្យមានប្រសិទ្ធភាពនិង តម្លាភាពដោយអនុវត្តន៍ទៅតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញ វត្ថុសាធារណៈដែលរាជរដ្ឋាភិបាលកម្ពុជាបានប្រកាសដាក់ឱ្យអនុវត្តន៍កាលពីថ្ងៃទី០៥ខែធ្នូ ឆ្នាំ២០០៤ អគ្គនាយក ដ្ឋានពន្ធដារបានអនុវត្តន៍ដោយជោគជ័យនិងសម្រេចបាននូវគោលដៅនៃដំណាក់កាលទី១។ ចំណូលពន្ធដារ ដែលទទួលបានក៏មានលទ្ធផលល្អប្រសើរជាងមុន នោះបញ្ជាក់ឱ្យឃើញថាការគោរពប្រត្តិបត្តិច្បាប់របស់អ្នក ជាប់ពន្ធមានការកើនឡើងច្រើនជាងមុន។ អគ្គនាយកដ្ឋានពន្ធដារបានធ្វើការប្រមូលចំណូលពន្ធសម្រាប់ធ្វើ ការអភិវឌ្ឍនូវគ្រប់វិស័យដូចជាបើកប្រាក់បៀវត្សជូនមន្ត្រីរាជការ កងទ័ព សាងសង់ស្ពាន ផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យចំណាយទូទៅសង្គមកិច្ចសេដ្ឋកិច្ច និងអភិវឌ្ឍន៍ការពារព្រំដែនជាដើម។ ក្នុងនោះដែរអគ្គនាយក ដ្ឋានពន្ធដារបានដាក់ចេញនូវកម្មថ្មីៗ វិធីសារពើពន្ធជាច្រើនដើម្បីលើកទឹកចិត្តផ្នែកពន្ធដារនិងធ្វើការប្រមូល ចំណូលពន្ធដារទៅតាមប្រភេទពន្ធអាករនីមួយៗផ្សេងៗគ្នាដែលមានដូចជា៖ ពន្ធលើប្រាក់ចំណូល ពន្ធប៉ាត ង់ ពន្ធលើប្រាក់បៀវត្ស និងអត្ថប្រយោជន៍បន្ថែម ពន្ធប្រថាប់ត្រា ពន្ធលើអចលនទ្រព្យ ពន្ធលើដីធ្លីមិនបាន ប្រើប្រាស់ ពន្ធតែមប្រ៏សារពើពន្ធ ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ពន្ធកាត់ទុក ពន្ធ លើឈ្នួលផ្ទះ និងដី អាករពិសេសលើទំនិញ និងសេវាមួយចំនួន អាករសម្រាប់បំភ្លឺសាធារណៈ អាករលើការ ស្នាក់នៅ អាករលើតម្លៃបន្ថែម។នៅក្នុងប្រទេសអភិវឌ្ឍន៍ក្តី និងប្រទេសកំពុងអភិវឌ្ឍន៍ក្តី វិស័យពន្ធដារដើរតួ យ៉ាងសំខាន់នៅក្នុងការរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិឱ្យមានការរីកចំរើន ការកាត់បន្ថយភាពក្រីក្រ និង ពង្រឹងសេដ្ឋកិច្ចឱ្យកាន់តែមានការរីកចំរើន។ ជាការពិតណាស់បច្ចុប្បន្ននេះចំណូលមួយផ្នែកធំរបស់រាជរដ្ឋាភិ បាលគឺបានមកពីការប្រមូលពន្ធពីប្រជាពលរដ្ឋហើយចំណូលនេះគឺ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការចូលរួម ចំណែកការអភិវឌ្ឍន៍ប្រទេសជាតិអោយរីកចំរើនដូចជាការសាង់សង់សាលារៀនមន្ទីរពេទ្យ ផ្លូវថ្នល់និង ស្ពាន ជាដើម។ ហេតុដូចនេះហើយ ទើបបច្ចុប្បន្ននេះរដ្ឋាភិបាលបានយក ចិត្តទុកដាក់យ៉ាងខ្លាំងនៅក្នុងការកែ ទម្រង់វិស័យពន្ធដារនៃប្រទេសកម្ពុជាអោយកាន់តែមានភាពប្រសើរឡើង។ សព្វថ្ងៃនេះរបបកំណត់ពន្ធនៃ ព្រះរាជាណាចក្រកម្ពុជាត្រូវបានធ្វើការកែទម្រង់ពី របបពន្ធបីយ៉ាង (របបពិត របបបំព្រួញ និងរបបម៉ៅការ)

ឱ្យនៅសល់តែមួយរបបប៉ុណ្ណោះគឺ ដោយសារការប្រមូលពន្ធគឺជាផ្នែកមួយសំខាន់ទើបនាងខ្ញុំសម្រេចចិត្តជ្រើសរើសប្រធានបទ "ចំណូលពីការប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ" យកមកធ្វើការសិក្សាស្រាវជ្រាវដើម្បីយល់ដឹងឱ្យបានកាន់តែច្បាស់ពីដំណើរការនៃការប្រមូលពន្ធរបស់រាជរដ្ឋាភិបាល។

ដោយយោងតាមប្រភពចំណូលរបស់របស់អគ្គនាយកដ្ឋានពន្ធដារ ទើបនាងខ្ញុំសម្រេចចិត្តជ្រើសរើសប្រធានបទ ស្តីពី «ការប្រមូលចំណូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ» យកមកស្រាវជ្រាវនិងរៀបចំជារបាយការណ៍បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះធ្វើឡើងក្នុងគោលបំណងស្វែងយល់អោយកាន់តែច្បាស់អំពីនីតិវិធីនិងវិធិសាស្ត្រនៃការប្រមូលចំណូលពន្ធដារបានដើរតួយ៉ាងសំខាន់ៗក្នុងការស្តារសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ប្រទេស។ ឯការបង់ពន្ធវិញគឺជាការចូលរួមចំណែកក្នុងថវិកាជាតិដើម្បីរដ្ឋភិបាលមានលុយច្រើនយកទៅចំណាយដោយមិនបាច់បោះពុម្ពលុយដែលអាចបង្កអោយមានបញ្ហាអតិផរណាសម្រាប់ កម្ពុជាការបង្កើនចំណូលពីការបង់ពន្ធជាគឺគន្លឹះដ៏សំខាន់ៗមួយដើម្បីឈានទៅបញ្ឈប់ការពឹងផ្អែក លើជំនួយបរទេសសម្រាប់អ្នកបង់ពន្ធថ្វីត្បិតតែពន្ធនេះមិនមានការកំណត់អំពីសេវាណាមួយមកវិញជាក់លាក់ក៏ ពិតមែនក៏ប៉ុន្តែគេអាចទទួលបានផលប្រយោជន៍ជាច្រើនដោយផ្ទាល់ឬដោយប្រយោលពីការបង់ពន្ធពីព្រោះថាលុយដែលបានពីការបង់ពន្ធនេះនឹងត្រូវយកចំណាយទៅលើការបើកប្រាក់បៀវត្សដល់មន្ត្រីរាជការស៊ីវិលនិង កងកម្លាំងប្រដាប់អាវុធដែលជាអ្នកទទួលបន្ទុកផ្តល់សេវារដ្ឋបាលការពារសន្តិសុខសណ្តាប់និង ការពារអធិបតេយ្យភាពបូរណភាពទឹកដី និងការកសាងហេដ្ឋារចនាសម្ព័ន្ធនានានៅក្នុងប្រទេស។សព្វថ្ងៃនេះយើងឃើញថាកម្ពុជាបានកសាងនូវហេដ្ឋារចនាសម្ព័ន្ធប្រណិតៗជាច្រើន ឯសេវាសាធារណៈក៏បានផ្តល់ភាពងាយស្រួលដល់សាធារណៈជន ក្នុងការទទួលយកសេវាប្រើប្រាស់។

១ តើប្រភេទចំណូលនៃការប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារមានប៉ុន្មានប្រភេទ?

២ តើអគ្គនាយកដ្ឋានពន្ធដារមាននីតិវិធីដូចម្តេចក្នុងការប្រមូលចំណូលពន្ធ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ដើម្បីបង្កើនភាពងាយស្រួលគោលបំណងនៃការស្រាវជ្រាវនេះ គឺផ្តោតសំខាន់ទៅលើបរិបទនៃការប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារដើម្បីធ្វើការ ឆ្លុះបញ្ចាំងពីការអនុវត្តន៍ជាក់ស្តែងពីនីតិវិធីក៏ដូចជាវិធីសាស្ត្រដើម្បីបង្កើនភាពងាយស្រួលនិងជាគន្លឹះ ក្នុងការសិក្សាស្រាវជ្រាវឱ្យកាន់តែល្អមានប្រសិទ្ធភាពខ្ពស់ក្នុងការកំណត់យកនូវគោលបំណងសំខាន់ៗដូចតទៅៈ

- ✓ ច្បាប់សារពើពន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ✓ ប្រព័ន្ធកំណត់ពន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ✓ កាតព្វកិច្ច និងសិទ្ធរបស់អ្នកជាប់ពន្ធ
- ✓ អំណាច និងសិទ្ធរបស់រដ្ឋបាលសារពើពន្ធ
- ✓ របបកំណត់ពន្ធរបស់ព្រះរាជាណាចក្រកម្ពុជា
- ✓ ទោសទណ្ឌសារពើពន្ធ
- ✓ អត្រាពន្ធ មូលដ្ឋានគិតពន្ធ និង ការគណនាប្រាក់ពន្ធ
- ✓ មុខសញ្ញាជាប់ពន្ធ

- ✓ ការលើកលែងពន្ធ
- ✓ យល់ដឹងពីស្ថានភាពទូទៅនៃអគ្គនាយកដ្ឋានពន្ធដារ
- ✓ យល់ដឹងអំពីការប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ
- ✓ យល់ដឹងពីប្រភពចំណូលរបស់រដ្ឋ
- ✓ ប្រភេទពន្ធនៅក្នុងប្រទេសកម្ពុជា
- ✓ ស្វែងយល់ពីប្រភេទពន្ធផ្សេងៗដោយសង្ខេប...។

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំ ដែនកំណត់

ប្រធានបទដែលនាងខ្ញុំលើកយកមកស្រាវជ្រាវនេះពាក់ព័ន្ធទៅនឹងចំណូលពីការប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ នៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះយោងតាមច្បាប់ស្តីពីសារពើពន្ធបច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជាមានប្រភេទពន្ធចំនួន ១៦ ប្រភេទពន្ធ។

### ១.៤.២ វិសាលភាព

យោងតាមប្រធានបទដែលបានស្រាវជ្រាវនេះ នាងខ្ញុំបានលើកយកតែទិន្នន័យដែលទាក់ទងទៅនឹងលទ្ធផលឆ្នាំ២០២២ និង២០២៣ តែប៉ុណ្ណោះ។ ប៉ុន្តែដោយសារវិសាលភាពនៃ ច្បាប់ពន្ធមានលក្ខណៈទូលំទូលាយ និងទាមទាររយៈពេលនៃការសិក្សាស្រាវជ្រាវច្រើន ដូច្នេះ នាងខ្ញុំគ្រាន់តែលើកយកចំណុចសំខាន់នៃប្រភេទពន្ធនីមួយៗ និងនីតិវិធីនៃការប្រមូលពន្ធតាម ការិយាល័យនីមួយៗ នៃអគ្គនាយកដ្ឋានពន្ធដារយកមកធ្វើការសិក្សាស្រាវជ្រាវ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

### ១.៥.១ វិធីសាស្ត្រយកមកប្រើប្រាស់ក្នុងការសរសេរ

វិធីសាស្ត្របែបនេះដែលគេយកមកអនុវត្តន៍សម្រាប់ការស្រាវជ្រាវមានច្រើនរបៀបចំណែកឯការសិក្សាស្រាវជ្រាវនៅក្នុងរបាយការណ៍បញ្ចប់ការសិក្សានេះ គឺនាងខ្ញុំប្រើប្រាស់វិធីសាស្ត្របែបរុករកបែបប្រៀបធៀបនិងបែបពិពណ៌នា ដើម្បីធ្វើការបកស្រាយ។

### ១.៥.២ វិធីសាស្ត្រស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវនេះ នាងខ្ញុំបានប្រើប្រាស់វិធីសាស្ត្រសិក្សាស្រាវជ្រាវតាមបែបវិធីសាស្ត្រគុណវិស័យសំរាប់ធ្វើការបកស្រាយទៅលើប្រធានបទមួយនេះ។ ការប្រមូលទិន្នន័យត្រូវការទិន្នន័យពីរយ៉ាងគឺទិន្នន័យបឋមនិងទិន្នន័យបន្ទាប់ដោយទិន្នន័យបឋមគឺនាងខ្ញុំបានធ្វើការប្រមូលទិន្នន័យតាមរយៈការចុះធ្វើកម្មសិក្សាដល់ទីកន្លែងនៅអគ្គនាយកដ្ឋានពន្ធដារដោយការធ្វើសម្ភាសន៍និងការអានឯកសារទាក់ទិនដើម្បីទទួលបានព័ត៌មាន។ ទិន្នន័យបន្ទាប់គឺ ការសិក្សាស្រាវជ្រាវឯកសារដូចជាច្បាប់អនុក្រឹត្យក្រមប្រកាសសេចក្តីជូនដំណឹងសារាចរណ៍ឯកសារចងក្រងដោយសាស្ត្រាចារ្យនិងអគ្គនាយកដ្ឋានពន្ធដារ។

ទិន្នន័យ និងឯកសារដែលបានស្រាវជ្រាវ៖

- ស្រាវជ្រាវឯកសារដែលមានស្រាប់តាមគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ
- តាមរយៈសារណារបស់សិស្សច្បងនិស្សិតជំនាន់មុន

- ស្វែងរកឯកសារនៅក្នុងបណ្ណាល័យរបស់វិទ្យាស្ថាន វ៉ាន់ដា
- លើកយកឯកសារដែលមានស្រាប់ដូចជា ព្រះរាជក្រម ប្រកាស អនុក្រឹត្យ ពាក់ព័ន្ធនឹងច្បាប់ពន្ធ
- សៀវភៅសិក្សាគណនេយ្យអនុវត្ត របស់វិទ្យាស្ថានវ៉ាន់ដា

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

តាមរយៈការសិក្សាស្រាវជ្រាវនេះ បានផ្តល់សារៈសំខាន់យ៉ាងខ្លាំងដល់នាងខ្ញុំឱ្យយល់កាន់តែច្បាស់អំពីការធ្វើសវនកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងច្បាប់ពន្ធ របស់អគ្គនាយកដ្ឋានពន្ធដារ ក៏សង្ឃឹមផងដែរថា ឯកសារស្រាវជ្រាវនេះនឹងអាចជួយជាគំនិតយោបល់ ជាប្រយោជន៍ដល់និស្សិតផ្សេងៗផងដែរ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ជំពូកទី១៖ សង្ខេបទៅលើ លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវដែនកំណត់វិសាលភាពនៃការស្រាវជ្រាវនិងវិធីសាស្ត្រនៃការស្រាវជ្រាវ។ ហើយបង្ហាញអំពីមូលដ្ឋានគ្រឹះនៃពន្ធដារនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានបង្ហាញអំពីប្រព័ន្ធពន្ធដារនៅព្រះរាជាណាចក្រកម្ពុជាសិទ្ធិនិងកាតួកិច្ចរបស់អ្នកជាប់ពន្ធការបង្ហាញអំពីចំនុចសំខាន់ៗនៃការប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធ។

ជំពូកទី២៖ រំលឹកទ្រឹស្តី

ជំពូកទី៣៖ នីតិវិធីនៃការប្រមូលចំណូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធ

ជំពូកទី៤៖ ការវិភាគពីចំណុចខ្លាំង និង ចំណុចខ្សោយ

ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និង ការផ្តល់អនុសាសន៍

# ជំពូកទី ២
# ចំណូលពីការប្រមូលពន្ធ

## ២.១ លក្ខណៈទូទៅនៃពន្ធ

### ២.១.១ និយមន័យពន្ធ

តាមវចនានុក្រមរបស់សម្តេចព្រះសង្ឃរាជ្យ ជួន ណាត ដែលបោះពុម្ពផ្សាយដោយពុទ្ធសាសន៍បណ្ឌិត្យនៅចន្លោះឆ្នាំ ១៩៦៧-១៩៦៨ ពន្ធ គឺជាសួយ-អាករដែលប្រជានិករខ្មែរត្រូវបង់តាមកំណត់។

តាមលោក Gaston Jèze ពន្ធ ត្រូវបានកំណត់និយមន័យថាជាតាវកាលិកគិតជាប្រាក់កាស ដែលប្រមូល ពីបុគ្គលឯកជននានាតាមរយៈអំណាចសាធារណៈ ជាលក្ខណៈស្ថាពរនិងគ្មានអ្វីជាថ្នូរ ក្នុងគោលបំណងដើម្បីបំពេញបន្ទុកសាធារណៈ។ តាមរយៈនិយមន័យនេះ ពន្ធបង្ហាញនូវសារជាតិផ្សេងៗ ជាអាទិ៍ ៖

ពន្ធ គឺជាការកាត់យកមុន។

ពន្ធ គឺជាការកាត់យកមុនដោយបង្ខំតាមមធ្យោបាយនៃអំណាចសាធារណៈ។

ពន្ធ គឺជាការកាត់យកមុនជាស្ថាពរ។

ពន្ធ គឺជាការកាត់យកមុនដោយគ្មានការតបស្នង ឬគ្មានអ្វីជាថ្នូរ។

ពន្ធ គឺជាការបង់ដោយបង្ខំដែលកំណត់ដោយរដ្ឋាភិបាលទៅលើរូបវន្តបុគ្គលសាជីវកម្ម ឬសហគ្រាស ហើយគ្មានផ្តល់សេវាកម្មទៅឱ្យអ្នកបង់ពន្ធទាំងនោះ ដោយផ្ទាល់វិញឡើយ។ ប្រជាពលរដ្ឋគ្រប់រូបត្រូវបង់ពន្ធដោយផ្អែកលើចំណូលដែលគេរកបាន ឧទាហរណ៍ពន្ធលើប្រាក់បៀវត្សនិងដោយផ្អែកលើចំណាយ អាករលើតម្លៃបន្ថែម អាករលើផលរបរ អាករបំភ្លឺសាធារណៈជាដើម។

ពន្ធ គឺជាបន្ទុករបស់ប្រជាជនជូនចំពោះរដ្ឋ ដើម្បីកៀរគរចំណូលថវិកាចូលរួមជាតិសម្រាប់ចំណាយសេវាសាធារណៈ។

ពន្ធ គឺជាបន្ទុករបស់អ្នកជាប់ពន្ធចំពោះរដ្ឋនិងជាកាតព្វកិច្ចរបស់គ្រប់សមាសភាព ដែលកំណត់ ដោយច្បាប់។

ពន្ធគឺជារូបភាពនៃការបែងចែកឡើងវិញ នូវចំណូលជាតិដែលរដ្ឋាភិបាលបានប្រើប្រាស់ដើម្បីប្រមូលចំណូល មួយផ្នែកពីការគ្រប់សមាសភាពសេដ្ឋកិច្ច មានដូចជាក្រុមហ៊ុនសហគ្រាសអាជីវកម្មនិង ប្រជាពលរដ្ឋ ដើម្បីបម្រើឱ្យតម្រូវការរួមរបស់សង្គមជាតិទាំងមូល។

ពន្ធ គឺជារូបធាតុនៃការប្រមូលចំណូល ដែលផ្សាភ្ជាប់ជាមួយនឹងសិទ្ធិអំណាច នយោបាយរបស់រដ្ឋាភិបាលដែលក្រឹត្យច្បាប់ជាកំណត់។

ពន្ធ គឺជាការបង់វិភាគទាន នូវកាតព្វកិច្ចរបស់គ្រប់សមាសភាពសេដ្ឋកិច្ច ដែលរួមទាំងរូបវន្តបុគ្គល និង នីតិបុគ្គល ជូនរាជរដ្ឋាភិបាលដែលមានច្បាប់កំណត់។

ពន្ធគឺជាចំណូលចន្តដ៏សំខាន់របស់រដ្ឋាភិបាលសម្រាប់ធ្វើការទ្រទ្រង់នូវដំណើរការវិស័យសាធារណៈផ្សេងៗពន្ធមានលក្ខណៈបង្ខំហើយមិនសងឱ្យវិញផ្ទាល់ឡើយប៉ុន្តែនិងអាចសងឱ្យវិញជាលក្ខណៈ រូបភាពប្រយោលទៅតាមគោលនយោបាយប្រទេសនីមួយៗ។គ្រប់អង្គភាពអាជីវកម្មសេវាកម្មដែលចំណុះឱ្យគ្រប់សមាសភាពសេដ្ឋកិច្ចត្រូវមានកាតព្វកិច្ចនិងទំនួលខុសត្រូវចំពោះមុខច្បាប់ក្នុងការអនុវត្តឱ្យបានគ្រប់

គ្រាន់ក្នុងការពន្ធទាំងឡាយដែលបានកំណត់និងមានសិទ្ធិស្មើៗគ្នា ក្នុងការទទួលមកវិញនូវផលប្រយោជន៍ពីរដ្ឋាភិបាល ដែលប្រកបដោយយុត្តិធម៌ព្រមទាំងមានភាពងាយស្រួល។

ពន្ធបានធ្វើឱ្យមានការផ្លាស់ប្តូរកម្មសិទ្ធិនៃប្រភពចំណូលដែលបានប្រមូល។ផ្លាស់ប្តូរកម្មសិទ្ធិនៃ ប្រភពចំណូលនេះបានកំណត់ដោយមុខងារគ្រប់គ្រងសេដ្ឋកិច្ចរបស់រដ្ឋាភិបាល ហើយបានស្តែងឡើងនៅឯកភាពគ្នាអំពីគោលចរិតផលប្រយោជន៍របស់រដ្ឋជាមួយនិង ផលប្រយោជន៍របស់ក្រុមហ៊ុនសេវាកម្ម និងប្រជាជនគ្រប់រូប។ នៅក្នុងល្បឿនសេដ្ឋកិច្ចទីផ្សារដែលសមាសភាពសេដ្ឋកិច្ចច្រើនគោលនយោបាយពន្ធដារត្រូវយកមកប្រើប្រាស់ជាចំបាច់ ជាទូទៅពន្ធដារបានចាត់ទុកជាឧបករណ៍ហិរញ្ញវត្ថុយ៉ាងមានប្រសិទ្ធភាព សេដ្ឋកិច្ចហិរញ្ញវត្ថុរបស់រដ្ឋាភិបាលដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសជាតិ[1]។

**២.១.២ ប្រវត្តិពន្ធ**

ពន្ធដារបានបង្កើតពន្ធមួយចំនួនផ្សេងទៀត ដើម្បីយកមកអនុវត្តន៍ និងមានការបែងចែកច្បាប់ និងមាត្រាយ៉ាងច្បាស់លាស់។ ផ្អែកទៅលើមាត្រាទី៤ នៃច្បាប់សារពើពន្ធបានបង្កើតឡើងនូវការកំណត់របបពន្ធជាបីប្រភេទ៖ គឺរបបពិត របបម៉ៅការ និងរបបបំព្រួញ ក៏ប៉ុន្តែបទប្បញ្ញត្តិស្តីពីរបបបំព្រួញមានចែងក្នុងក្រដាសមួយជាច់ដោយឡែក។ដែលជាវិធាននិងជានីតិវិធីដើម្បីចាត់បញ្ចូលអ្នកជាប់ពន្ធឱ្យស្ថិតនៅក្នុងរបបកំណត់ណាមួយនោះ ត្រូវកំណត់ដោយផ្អែកទៅលើទ្រង់ទ្រាយអាជីវកម្ម និងកម្រិតផលរបរ។

នៅពេលបច្ចុប្បន្ននេះក្នុងប្រទេសកម្ពុជាយើងមានតែរបបពិត តែមួយប៉ុណ្ណោះ(ស្វ័យប្រកាស) ការអនុវត្តន៍និងការកំណត់នៃរបបពិតរបស់សហគ្រាសដោយផ្អែកទៅលើទ្រង់ទ្រាយគតិយុត្តិនៃកម្រិតផលរបរប្រចាំឆ្នាំ និងប្រភេទសកម្មភាពអាជីវកម្ម។

- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៩ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/ រកម/ ០១.៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ចែងអំពីការអនុញ្ញាតឱ្យប្រមូលអាករបំភ្លឺសាធារណៈលើ តម្លៃ សុរាមេរ៉យ និងបារី ដែលជាផលិតផលមកពីបរទេស។

ពន្ធប៉ាតង់ ត្រូវបានអនុលោមតាមខ្លឹមសារក្រឹត្យច្បាប់លេខ ២២ ក្រ.ច ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ ១៩៩៤ ស្តីពីពន្ធប៉ាតង់និងមាត្រា ៣៩ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាស ដោយព្រះរាជក្រមលេខ១១ ន.ស៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងបទបញ្ញត្តិស្តីពីសារពើពន្ធ។

- ពន្ធលើប្រាក់បៀវត្ស ចាប់ផ្តើមដំបូងគឺ ចេញពីព្រះរាជក្រមលេខ ១១ ន.ស ៩៤ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៩៤ (ច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ ១៩៩៥) តែត្រូវបានធ្វើវិសោធនកម្មដ៏ធំនៅឆ្នាំ ១៩៩៧ ។

ពន្ធលើកាត់ទុក ចាប់ផ្តើមគឺចេញពីព្រះរាជក្រមលេខ នស.រកម. ០២៩៧ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ (ច្បាប់ស្តីពី ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៥) តែត្រូវបានធ្វើវិសោធនកម្មដ៏ធំនៅឆ្នាំ ១៩៩៧ ។

- ច្បាប់ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ៤ ខែ ធ្នូ ១៩៩៧ ចេញដោយព្រះរាជ ក្រម និងអនុក្រឹត្យលេខ៨៨ អនុក្រ.បក ថ្ងៃទី២៩ធ្នូ១៩៩៧ ស្តីពីការអនុវត្តច្បាប់វិនិយោគនៃព្រះរាជាណា ចក្រកម្ពុជា។

[1] www.tax.gov.kh( 27.11.2023 )

• អាករលើតម្លៃបន្ថែមត្រូវបានអនុម័តដោយព្រះរាជក្រមលេខ នស.រកម ០២៩៧ ថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ១៩៩៧ តែអនុម័តពិតប្រាកដគឺ ថ្ងៃទី១ ខែ មករា ឆ្នាំ១៩៩៩។

• អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា ៤ និង ៦ថ្មីនៃច្បាប់ស្តីពីសារពើពន្ធដែលត្រូវបានធ្វើវិសោធន កម្មដោយមាត្រា ១១នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ ដែលប្រកាសប្រើដោយព្រះរាជក្រមលេខ នស.រកម. ១២១៥/០១៦ ចុះថ្ងៃទី ១៧ ធ្នូ ២០១៥ និងប្រកាសលេខ ១៨២០ សហវ.ប្រក ចុះថ្ងៃ ទី២៥ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពីការកំណត់វិធាននិងនីតិវិធីនៃការអនុវត្តបញ្ជី គណនេយ្យ

ទ្រង់ទ្រាយគតិយុត្តិមានន័យថា រាល់សហគ្រាសដែលមិនមែនជាសហគ្រាសឯកបុគ្គល គឺត្រូវជាប់ពន្ធរបបពិត ទោះបីសហគ្រាសនោះមានសកម្មភាពអាជីកម្មប្រភេទអ្វី ឬមានកម្រិតផលរបរប្រចាំឆ្នាំប៉ុន្មានក៏ដោយ។ សហគ្រាសទាំងនោះមានដូចជាសហគ្រាសចម្រុះ ក្រុមហ៊ុនឯកជន សមូហភាពសាធារណៈ ឬអង្គការឯកជនដែលធ្វើសកម្មភាពក្នុងលក្ខខណ្ឌប្រាក់ចំណេញ ឬប្រាក់ចំណូលដែលជាបេតិកភ័ណ្ឌរបស់ខ្លួន។ កម្រិតផលរបររប្រចាំឆ្នាំ គឺជាការកំណត់ពន្ធលើប្រាក់ចំណេញតាមរបបពិតដែលត្រូវអនុវត្តន៍ ហើយចំពោះសហគ្រាសដែលមានផលរបរប្រចាំឆ្នាំចាប់ពី៥០០លានរៀនឡើងទៅ។ ចំណែកឯការផ្គត់ផ្គង់ចម្រុះដែលមានរបរប្រចាំឆ្នាំចាប់ពី ២៥០លានរៀលឡើងទៅ។

រាល់សហគ្រាសដែលធ្វើការដេញថ្លៃ ប្រសិនបើសហគ្រាសទាំងនោះបានទទួលសញ្ញាធ្វើ ឬក៏ជាការផ្គត់ផ្គង់របស់អង្គការសាធារណៈដែលមានចំនួនទឹកប្រាក់ប្រចាំឆ្នាំសរុប ១២៤លានរៀន សកម្មភាពសេវាកម្មដូចជា សណ្ឋាគារ កន្លែងម៉ាស្សា រង្គសាល ភោជនីយដ្ឋាន កន្លែងកម្សាន្តនានាដែលចាត់ថ្នាក់ជាគ្រឹះស្ថានធើត សកម្មភាពអណ្តូងរ៉ែនិងអាជីវកម្មនេសាទ[2]។

ដើម្បីថែរក្សាផលប្រយោជន៍សាធារណៈទាំងអស់ចាំបាច់ត្រូវ ទាមទារឱ្យមានការចូលរួមពីសំណាក់មហាជន តាមការស្រាវជ្រាវ ការកកើតពន្ធ ឬទ្រឹស្តីទាក់ទងនឹងពន្ធ ត្រូវបានគេរកឃើញថា បានកើតឡើងស្របជាមួយនឹងការកកើតឡើងនៃការប្រមូលផ្តុំគ្រប់គ្រងដំបូង និងនៅពេលដែលមានការកើតចេញឡើង នូវទម្រង់អង្គការចាត់តាំងនៃសង្គមមនុស្ស។ Evolution នៃសង្គមមនុស្សជាហេតុផលដែលបង្ហាញពីភាពងាយស្រួលនៃការប្រមូលពន្ធ ដែលស្ថិតនៅលើរបត់មួយដ៏យូរលង់ ត្រូវបានឆ្លោះមករកភាពសាំញ៉ាំ និងពិបាកមកដល់បច្ចុប្បន្ននេះ[3]។

**២.១.៣ ប្រភេទពន្ធ**

ពន្ធ គឺជាចំណូលចរន្តដ៏សំខាន់របស់រដ្ឋ សម្រាប់ធ្វើការទ្រទ្រង់នូវដំណើរការវិស័យសាធារណៈផ្សេងៗ។ នៅកម្ពុជាបច្ចុប្បន្នបានកំណត់នូវពន្ធចំនួន១៨ ប្រភេទ ដែលតម្រូវឱ្យប្រជាពលរដ្ឋ ឬអ្នកជាប់ពន្ធទាំងអស់ត្រូវធ្វើការបង់ជូនរដ្ឋ។ ប្រភេទពន្ធទាំងនោះរួមមាន៖

- ពន្ធលើប្រាក់ចំនេញ
- ប្រាក់រំដោះពន្ធលើប្រាក់ចំនេញ
- ពន្ធអប្បបរមា

[2] វិទ្យាស្ថាន វ៉ាន់ដារបាយការស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១៩ទំព័រទី៥ របស់និស្សិតឈ្មោះម៉ែន វ៉ាន់នី

[3] www.tax.gov.kh( 27.11.2023 )

- ពន្ធកាត់ទុក
- ពន្ធលើប្រាក់បៀវត្ស
- អាករលើតម្លៃបន្ថែម
- អាករលើផលរបរ
- ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ
- អាករពិសេស
- ពន្ធលើផ្ទាំងផ្សព្វផ្សាយ
- ពន្ធប៉ាតង់
- ពន្ធប្រថាប់ត្រា
- ពន្ធលើដីធ្លីមិនបានប្រើប្រាស់
- ពន្ធសត្តឃាត
- អាករស្នាក់នៅ
- អាករបំភ្លឺសាធារណៈ
- ពន្ធលើអចលនទ្រព្យ
- ពន្ធលើមធ្យោបាយដឹកជញ្ជូន[4]។

នៅកម្ពុជាបច្ចុប្បន្ន បានកំណត់នូវពន្ធចំនួន១៨ ប្រភេទ ដែលតម្រូវឱ្យប្រជាពលរដ្ឋ ឬអ្នកជាប់ពន្ធ ទាំងអស់ត្រូវធ្វើការបង់ជូនរដ្ឋ។ ប្រភេទពន្ធទាំងនោះរួមមាន៖

- ពន្ធលើប្រាក់ចំណេញ គឺត្រូវបានកំណត់លើអ្នកជាប់ពន្ធនិវាសនជន ចំពោះប្រាក់ចំណូលប្រភពកម្ពុជានិងប្រាក់ចំណូលប្រភពបរទេស។ សម្រាប់អ្នកជាប់ពន្ធអនិវាសនជន ពន្ធលើប្រាក់ ចំណេញ កំណត់តែលើប្រាក់ចំណូលប្រភពកម្ពុជាប៉ុណ្ណោះ។
- ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ គឺជាប្រភេទពន្ធដែលយកទៅលើប្រាក់ចំណេញដុលរបស់ក្រុមហ៊ុនដែលបានមកពីសកម្មភាពផលិតកម្មអាជីវកម្មនិងសេវាកម្មជាដើមរួមទាំងគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលត្រូវជាប់ពន្ធលើអត្រា៩% មានកាតព្វកិច្ចបង់ប្រាក់រំដោះប្រចាំខែតាមអត្រា ១% សម្រាប់ពន្ធលើប្រាក់ចំណេញ ។
- ពន្ធអប្បបរមា គឺជាពន្ធមួយប្រភេទដែលមានលក្ខណៈដាច់ដោយឡែកនិងផ្សេងៗពីពន្ធលើប្រាក់ចំណេញ។
- ពន្ធកាត់ទុក គឺជាពន្ធលើប្រាក់ចំណូលដែលបានដកពីប្រាក់ឈ្នួលរបស់និយោជិត ហើយត្រូវបានបង់ដោយផ្ទាល់ដល់រដ្ឋាភិបាលដោយនិយោជក ដែលស្ថិតក្នុង អត្រា ១៥% ចំពោះពន្ធកាត់ទុកចំនួនទឹកប្រាក់ដែលត្រូវដកហូតគឺជាឥណទានធៀបនឹងពន្ធលើប្រាក់ចំណូលដែលនិយោជិតត្រូវបង់ក្នុងកំឡុងឆ្នាំ។
- ពន្ធលើប្រាក់បៀវត្ស គឺជាពន្ធប្រចាំខែកំណត់លើប្រាក់បៀវត្សដែលរូបវន្តបុគ្គលបានទទួលក្នុងក្របខ័ណ្ឌនៃការ បំពេញសកម្មភាពបំរើការងារ។

[4] រៀបរៀងដោយសាស្ត្រាចារ្យ វ៉ែន ឈុនហួត

- អាករលើតម្លៃបន្ថែម គឺជាប្រភេទពន្ធប្រយោលដែលរដ្ឋដកហូតដោយប្រយោលពីអ្នកប្រើប្រាស់ (អ្នកទិញ) ចុងក្រោយតាមរយៈអ្នកផ្គត់ផ្គង់ដែលជាបុគ្គលជាប់អាករ (អ្នកផ្គត់ផ្គង់ដែលមានប័ណ្ណអ.ត.ប) នៅអត្រា ១០% ទៅលើការផ្គត់ផ្គង់ទំនិញ ឬសេវាកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា និង អត្រា 0% ចំពោះការនាំចេញ។
- អាករលើផលរបរ គឺជាប្រភេទពន្ធប្រយោលដែលត្រូវបានយកពន្ធពីសកម្មភាពសេដ្ឋកិច្ចផ្សេងៗដូចជា ពាណិជ្ជកម្ម ផលិតកម្ម អាជីវកម្ម និងសេវាកម្ម។ អាករលើផលរបរប្រមូលពីអ្នកប្រើប្រាស់ និងបង់ជូនរដ្ឋដោយអ្នកលក់អាករនេះអនុវត្តចំពោះអ្នកជាប់ពន្ធតាមរបបម៉ៅការតែប៉ុណ្ណោះ។
- ពន្ធលើឈ្នួលផ្ទះ និងដី គឺជាប្រភេទពន្ធផ្ទាល់គិតលើប្រាក់ឈ្នួលដែល ទទួលមកពីការជួលផ្ទះ ឬ ដីធ្លី (Real property rental/lease)។ កម្មសិទ្ធិករ នៃអចលនទ្រព្យជួល មានកាតព្វកិច្ចត្រូវនូវបង់ ពន្ធនេះ ។ អត្រាពន្ធលើឈ្នួលផ្ទះ និងដីត្រូវបានកំណត់ស្មើនឹង ១០% នៃប្រាក់ឈ្នួលដុល ដែល បានចុះក្នុងកិច្ចសន្យាឬព្រមព្រៀងជាមួយអ្នកជួល។ អាករពិសេសលើទំនិញនិងសេវាមួយចំនួនគឺជាប្រភេទពន្ធប្រយោលដែលយកទៅលើមុខទំនិញនិងសេវាមួយចំនួន ដែលប្រែប្រួលទៅតាមប្រទេសនីមួយៗអ្នកលក់ឬអ្នកផ្គត់ផ្គង់ ត្រូវ ប្រមូលអាករនេះពីអ្នកទិញ (អ្នកប្រើប្រាស់) ហើយបង់ជូនរដ្ឋជា បន្តនាពេលក្រោយ។
- ពន្ធតែមប្រ៊ិ៍ គឺជាតម្លៃតែមប្រ៊ិ៍សារពើពន្ធ។
- ពន្ធប៉ាតង់ គឺជាពន្ធដែលកំណត់ដោយសកម្មភាពអាជីវកម្មគ្រប់ប្រភេទពន្ធនេះប្រែប្រួលទៅតាមកម្រិតផលរបរសរុបប្រចាំឆ្នាំនៃការជួញដូរនោះអាជីវករមានកាតព្វកិច្ចបង់ពន្ធលើសកម្មភាពអាជីវកម្មរបស់ខ្លួនពេញមួយឆ្នាំប្រសិនបើចាប់ផ្តើមអាជីវកម្ម៦ខែដំបូងដើមឆ្នាំឬបង់ពាក់កណ្តាលឆ្នាំប្រសិនបើចាប់ផ្តើមអាជីវកម្ម ៦ ខែដំបូងចុងឆ្នាំ។
- ពន្ធប្រថាប់ត្រា គឺជាប្រភេទពន្ធមួយដែលគិតលើការផ្ទេរកម្មសិទ្ធិឬសិទ្ធិប្រើប្រាស់ក្រោមរូបភាពជាការទិញលក់ការផ្ទេរពីម្នាក់ទៅម្នាក់ការដោះដូរនៃចលនទ្រព្យនិងអចលនទ្រព្យអ្នកទទួលការ ផ្ទេរកម្មសិទ្ធិនៃទ្រព្យនោះមានកាតព្វកិច្ចត្រូវបង់ពន្ធនេះ។ពន្ធលើដីធ្លីមិនបានប្រើប្រាស់។
- ពន្ធសត្តឃាត
- អាករស្នាក់នៅ គឺជាប្រភេទពន្ធប្រយោលដែលគិតលើតម្លៃសរុបនៃការជួលកន្លែងស្នាក់នៅដែលអ្នកប្រើប្រាស់សេវាស្នាក់នៅជាប់កាតព្វកិច្ចត្រូវបង់និងដែលទទួលកាត់ទុកដោយអ្នកផ្គត់ផ្គង់ដើម្បីបង់ជូនរដ្ឋជាបន្ត នាពេលក្រោយទៀត។
- អាករបំភ្លឺសាធារណៈ គឺជាប្រភេទពន្ធប្រយោល ដែលគិតទៅលើតម្លៃសុរាមេរ័យនិងបារី ដែលអ្នកប្រើប្រាស់មានកាតព្វកិច្ចត្រូវបង់ហើយដែលត្រូវកាត់ទុកដោយអ្នកលក់ដើម្បីបង់ជូនរដ្ឋជាបន្តនាពេលក្រោយទៀត។
- ពន្ធលើអចលនទ្រព្យ គឺត្រូវប្រមូលប្រចាំឆ្នាំតាមអត្រា 0,១% (សូន្យក្បៀសមួយភាគរយ) លើ តម្លៃអចលនទ្រព្យ ដែលតម្រូវឱ្យគិតតាមមូលដ្ឋានគិតពន្ធគឺជាតម្លៃ ដី ផ្ទះ អគារ និងសំណង់ផ្សេងៗដែលសង់ភ្ជាប់នឹងដីនោះដែលមានតម្លៃលើសពី១00,000,000 (មួយរយលាន) រៀល នឹងត្រូវកំណត់តម្លៃទីផ្សារដោយគណៈកម្មការវាយតម្លៃអចលនទ្រព្យ ។
- ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទឮគឺជាពន្ធដែលអនុវត្តលើមធ្យោបាយដឹក ជញ្ជូន និង យានជំនិះគ្រប់ប្រភេទ។

## ២.២ ចំណូលដែលទទួលបានពីការប្រមូលពន្ធ

### ២.២.១ និយមន័យចំណូល

ចំណូល គឺការហូរចូលនូវសាច់ប្រាក់ឬកើនទ្រព្យសកម្ម ឬសំណងនៃបំណុលនៅក្នុងកំឡុងពេលណាមួយពីការទទួលបានឬផលិតទំនិញផ្គត់ផ្គង់សេវាកម្មឬសកម្មភាពផ្សេងៗ ដែលទាក់ទងនឹងប្រតិបត្តិការរបស់ក្រុមហ៊ុនហើយចំណូលអាចជាថ្លៃទំនិញដែលបានលក់តាមរយៈការផ្តល់សេវាកម្មនៅក្នុងកំឡុងពេលនៃខួបគណនេយ្យ[5]។

ចំណូល គឺជាការប្រមូលចំណូលសារពើពន្ធ ដែលអនុញ្ញាតឱ្យប្រមូលក្នុងលក្ខខណ្ឌនិងតាមបែបបទស្របតាមច្បាប់ហិរញ្ញវត្ថុ និងដោយនិតិកម្មព្រមទាំងបទបញ្ញាដោយមានជាធរមាន។

### ២.២.២ សារៈសំខាន់នៃចំណូល

អគ្គនាយកដ្ឋានពន្ធដារក្រសួងសេដ្ឋកិច្ចនិងហរិញ្ញវត្ថុលើសពីនេះទៅទៀតអគ្គនាយកដ្ឋានពន្ធដារបានបង្កើតពន្ធមួយចំនួនផ្សេងទៀត ដើម្បីយកអនុវត្តន៍ និងមានការបែងចែកច្បាប់ និងមាត្រាយ៉ាងច្បាស់លាស់។ ផ្អែកទៅលើមាត្រាទី៤ នៃច្បាប់សារពន្ធបានបង្កើតឡើងនូវការកំណត់របបពន្ធជាបីប្រភេទ៖ គឺរបបពិត របបម៉ៅការ របបបំព្រួញក៏ប៉ុន្តែបទប្បញ្ញត្តិស្តីពីរបបបំព្រួញមានចែងក្នុងក្រដាសមួយដាច់ដោយឡែក។ដែលជាវិធាននិងជានីតិវិធីដើម្បីចាត់បញ្ជូនអ្នកជាប់ពន្ធឱ្យស្ថិតនៅក្នុងរបបកំណត់ណាមួយនោះត្រូវកំណត់ដោយផ្អែកទៅទ្រង់ទ្រាយអាជីវកម្មនិងកម្រិតផលរបរ។ប៉ុន្តែនៅពេលបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជាយើងមានតែរបបពិត(ស្វ័យប្រកាស) តែមានប៉ុណ្ណោះ។

ការអនុវត្ត និងការកំណត់នៃរបបពិតរបស់សហគ្រាសដោយផ្អែកទៅលើទ្រង់ទ្រាយគតិយុត្តិនៃកម្រិតផលរបរប្រចាំឆ្នាំ និងប្រភេទសកម្មភាពអាជីវកម្ម។ទ្រង់ទ្រាយគតិយុត្តិមានន័យថារាល់សហគ្រាសដែលមិនមែនជា សហគ្រាសឯកបុគ្គលិកគឺត្រូវជាប់ពន្ធរបបពិត ទោះបីសហគ្រាសនោះមានអាជីវកម្មប្រភេទអ្វីឬមានកម្រិតផលរបរប្រចាំឆ្នាំប៉ុន្មានក៏ដោយ។ សហគ្រាសទាំងនោះមានដូចជាសហគ្រាសចម្រុះក្រុមហ៊ុនឯកជនសមូហភាពសាធារគណៈឬអង្គការឯកជនដែលធ្វើសកម្មភាពក្នុងលក្ខខណ្ឌប្រាក់ចំណូលដែលជាបេតិកភ័ណ្ឌរបស់ខ្លួន។ កម្រិតផលរបរប្រចាំឆ្នាំ គឺជាការកំណត់ពន្ធលើប្រាក់ចំណូលតាមរបបពិតដែលត្រូវអនុវត្តន៍ហើយចំពោះសហគ្រាសដែលមានផលរបរប្រចាំឆ្នាំចាប់ពី ៥០០ លានរៀលឡើងទៅចំណែកឯការផ្គត់ផ្គង់ចម្រុះដែលមានរបបរប្រចាំឆ្នាំចាប់ពី ២៥០លានរៀលឡើងទៅ។

រាល់សហគ្រាសដែលធ្វើការដេញថ្លៃ ប្រសិនបើសហគ្រាសទាំងនោះបានទទួលសញ្ញាធ្វើ ឬក៏ជាការផ្គត់ផ្គង់របស់អង្គការសាធារណៈដែលមានចំនួនទឹកប្រាក់ប្រចាំឆ្នាំសរុប ១២៤លានរៀល សកម្មភាពសេវាកម្មដូចជា សណ្ឋាគារ កន្លែងម៉ាស្សាវង្គសាល ភោជនីយ៍ដ្ឋាន កន្លែងកម្សាន្តនានាដែលចាត់ថ្នាក់ជាគ្រឹះស្ថានធើតសកម្មភាពអណ្តូតរ៉ែ និងអាជីវកម្មនេសាទ[6]។

ដើម្បីថែរក្សាផលប្រយោជន៍សាធារណៈទាំងអស់ចាំបាច់ត្រូវឲ្យមានការចូលរួមពីសំណាក់មហាជនតាមការស្រាវជ្រាវការកកើតពន្ធឬទ្រឹស្តីទាក់ទងនឹងពន្ធត្រូវបានគេរកឃើញថាបានកើតឡើងស្របជាមួយ

[5] វិទ្យាស្ថាន វ៉ាន់ដារបាយការស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១៩ទំព័រទី៦ របស់និស្សិតឈ្មោះម៉ែន វ៉ាន់នី

[6] វិទ្យាស្ថាន វ៉ាន់ដារបាយការស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១៩ទំព័រទី៧ របស់និស្សិតឈ្មោះម៉ែន វ៉ាន់នី

នឹងការកកើតឡើងនៃការប្រមូលផ្តុំគ្រប់គ្រងដំបូលនិងនៅពេលដែលមានការកើតចេញឡើងនូវទម្រង់អង្គការចាត់តាំងនៃសង្គមមនុស្ស។សង្គមមនុស្សជាហេតុផលដែលបង្ហាញពីភាពងាយស្រួលនៃការប្រមូលពន្ធ ដែលស្ថិតនៅលើរបត់មួយក៏យូរលង់ត្រូវបានឆ្ពោះមករកភាពសាំញ៉ាំ និងពិបាកមកដល់បច្ចុប្បន្ននេះ។

**២.២.៣ ប្រភេទចំណូលពន្ធ**

ប្រភេទចំណូលពន្ធមាន២ប្រភេទគឺ៖ ចំណូលថ្នាក់ក្រោមជាតិ ចំណូលថ្នាក់ក្រោមជាតិ

- ➢ ចំណូលថ្នាក់ក្រោមជាតិ
- ពន្ធប្រាក់ចំណេញ
- ពន្ធអប្បបរមា
- ពន្ធកាត់ទុកទូទៅ
- ពន្ធលើប្រាក់បៀវត្ស
- ពន្ធលើអាករតម្លៃបន្ថែម
- អាករពិសេស
- ពន្ធលើចំណេញមូលធន
- ➢ ចំណូលថ្នាក់ក្រោមជាតិ
- អាករលើការស្នាក់នៅ
- អាករសម្រាប់បំភ្លឺសាធារណៈ
- ពន្ធលើអចលនទ្រព្យ
- ពន្ធលើមធ្យោបាយដឹកជញ្ជូន
- ពន្ធលើផ្ទាំងផ្សព្វផ្សាយ
- ពន្ធប៉ាតង់
- ពន្ធប្រថាប់ត្រា
- ពន្ធលើដីធ្លីមិនបានប្រើប្រាស់
- ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ[7]។

**២.២.៤ ច្បាប់និងបទបញ្ញត្តិស្តីពីពន្ធដារពាក់ព័ន្ធការចុះបញ្ជីពន្ធដារ**

**មាត្រាទី១០១ នៃច្បាប់ស្តីពីសារពើពន្ធ**

ថ្ងៃ ក្រោយពីបុគ្គលនោះចាប់១៥ក្នុងកំឡុង បុគ្គលទាំងឡាយត្រូវទៅចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច។ ថ្ងៃក្រោយពីផ្លាស់ប្តូរឈ្មោះ១៥ត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានក្នុងកំឡុងអាសយដ្ឋាន ទ្រង់ទ្រាយ នាមករណ៍ កម្មវត្ថុអាជីវកម្ម ការផ្ទេរ ការបញ្ឈប់អាជីវកម្ម សមាសភាពអ្នកគ្រប់គ្រង ឬអ្នកទទួលបន្ទុកកិច្ចការពន្ធដាររបស់សហគ្រាស។

**មាត្រា៣នៃច្បាប់ស្តីពីសារពើពន្ធ(ថ្មី)**

[7] ដកស្រង់ចេញពីសៀវភៅពន្ធដារ ការប្រមូលពន្ធ និងប្រពន្ធពន្ធដារកម្ពុជានៅទំព័រទី៦ឆ្នាំ២០២២

«**នីតិបុគ្គល**» សំដៅដល់សហគ្រាស ឬអង្គភាពនានាដែលប្រកបអាជីវកម្ម ទោះបីបាន ឬមិនទាន់បានទទួលស្គាល់ជាផ្លូវការពីស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលក្តី។ ពាក្យ«**នីតិបុគ្គល**» រួមបញ្ចូលផងដែរនូវស្ថាប័នរដ្ឋាភិបាល អង្គការ សាសនា អង្គការសប្បុរសធម៌ ឬអង្គការមិនស្វែងរកប្រាក់ចំណេញ។ ចំពោះបុគ្គលអនិវាសនជន ពាក្យ **នីតិបុគ្គល** សំដៅដល់គ្រឹះស្ថានអចិន្ត្រៃយ៍នៅព្រះរាជាណាចក្រកម្ពុជា។ពាក្យ **នីតិបុគ្គល** ពុំរាប់បញ្ចូលទេនូវក្រុមហ៊ុនអាជីវកម្ម ឬសហគ្រាសឯកបុគ្គល។

**ប្រកាសលេខ៤៩៦ សហវ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការចុះបញ្ជីពន្ធដារ**

«**សកម្មភាពសេដ្ឋកិច្ច**» សំដៅដល់សកម្មភាពរបស់បុគ្គលដែលធ្វើជានិច្ចកាលជាប់បន្ត ឬមួយដងមួយគ្រា ដើម្បីរក ឬមិនរកប្រាក់ចំណេញ ក្នុងការផ្គត់ផ្គង់ ឬមានបំណងផ្គត់ផ្គង់ទំនិញ ឬសេវាកម្ម ឱ្យដល់បុគ្គលដទៃ ក្នុងគោលដៅដើម្បីបានអត្ថប្រយោជន៍អ្វីមួយ។

«**អាជីវកម្ម**» សំដៅដល់សកម្មភាពរបស់បុគ្គលដែលមានគោលដៅ ទាញយកប្រាក់ចំណូលពីការផលិត និងលក់ទំនិញ ការផ្គត់ផ្គង់សេវា កតិសន្យា ការជួល ឬការលក់ទ្រព្យសម្បត្តិ ឬសកម្មភាព ផ្សេងៗទៀត។

**ប្រកាសលេខ០២៥ សហវ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស**

**អ្នកជាប់ពន្ធតូច** គឺជាសហគ្រាសឯកបុគ្គល មានផលរបរប្រចាំឆ្នាំចាប់ពី២៥០លានរៀល ដល់៧០០លានរៀល (៦២,៥00$ -១៧៥,000$) ឬមានផលរបរ ឬរំពឹងថាផលរបរក្នុងរយៈពេលបីខែជាប់គ្នាណាមួយដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តចាប់ពី៦០លានរៀល (ប្រមាណ ១៥,000$)ឡើងទៅ។

**អ្នកជាប់ពន្ធមធ្យម** គឺជាសហគ្រាសមានផលរបរប្រចាំឆ្នាំលើសពី៧00លានរៀល ដល់៤,000លានរៀល (១៧៥,00$-១,000,000$)។

**អ្នកជាប់ពន្ធធំ** គឺជាសហគ្រាសមានផលរបរប្រចាំឆ្នាំលើសពី៤,000លានរៀល(១,000,000$) ឡើងទៅ។

**ការចុះបញ្ជីពន្ធដារចំពោះសកម្មភាពអាជីវកម្មដោយខ្សែក**

សំណុំឯកសារភ្ជាប់ទាំងអស់ ដែលជាច្បាប់ថតចម្លងដែលតម្រូវឱ្យភ្ជាប់សម្រាប់ការចុះបញ្ជីពន្ធដារ ត្រូវមានការបញ្ជាក់ «**ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**» ពីមន្ត្រីពន្ធដារ មានសមត្ថកិច្ច ឬពីក្រសួងពាក់ព័ន្ធ

- **សម្រាប់អ្នកជាប់ពន្ធតូច**

| ឯកសារតម្រូវ | |
|---|---|
| ១ | បំពេញពាក្យស្នើសុំចុះបញ្ជីពន្ធដារ ទម្រង់ )SO1) |
| ២ | អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ដែលមានសុពលភាព |
| ៣ | រូបថតបច្ចុប្បន្នមិនលើសពី ០៣ខែ ទំហំ៣៥ X ៤៥ មីលីម៉ែត្រ ផ្ទៃខាងក្រោយពណ៌ស ចំនួន០២សន្លឹក ដែលមានបញ្ជាក់ឈ្មោះម្ចាស់រូបថត និងចុះហត្ថលេខាទទួលខុសត្រូវ ដោយប្រធាន ឬតំណាងសមាគម ឬអង្គភាពនានា |
| ៤ | ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំងឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម |
| ឯកសារត្រូវភ្ជាប់បើមាន៖ | |

| | |
|---|---|
| ១ | លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ការចុះបញ្ជី ចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ |
| ២ | លិខិតបញ្ជាក់ការបង់ពន្ធលើអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ |
| ៣ | អាជ្ញាប័ណ្ណដែលចេញដោយក្រសួង ស្ថាប័ន មានសមត្ថកិច្ច។ |

- **សម្រាប់អ្នកជាប់ពន្ធមធ្យមធំ-**

| ឯកសារតម្រូវ | |
|---|---|
| ១ | បំពេញពាក្យស្នើសុំចុះបញ្ជីពន្ធដារ ១០១ទម្រង់)) |
| ២ | អត្តសញ្ញាណប័ណ្ណ ឬលិខិតបញ្ជាក់ការចុះបញ្ជី ចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ |
| ៣ | លក្ខន្តិកៈរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល |
| ៤ | ព័ត៌មានគណនីធនាគារសម្រាប់សកម្មភាពអាជីវកម្មដោយឡែក ដូចជាលិខិតបញ្ជាក់គណនីធនាគារ របាយការណ៍ធនាគារ ឬសៀវភៅធនាគារ ដែលចេញដោយធនាគារ |
| ៥ | អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែរ ដែលមានសុពលភាព |
| ៦ | រូបថតបច្ចុប្បន្នមិនលើសពី ០៣ខែ ទំហំ៣៥ X ៤៥ មីលីម៉ែត្រ ផ្ទៃខាងក្រោយពណ៌ស ចំនួន០២សន្លឹក ដែលមានបញ្ជាក់ឈ្មោះម្ចាស់រូបថត និងចុះហត្ថលេខាទទួលខុសត្រូវ ដោយប្រធាន ឬតំណាងសមាគម ឬអង្គភាពនានា |
| ៧ | លិខិតបញ្ជាក់ការបង់ពន្ធលើអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ |
| ៨ | អាជ្ញាប័ណ្ណដែលចេញដោយក្រសួង ស្ថាប័ន មានសមត្ថកិច្ច។ |

**បំពេញពាក្យស្នើសុំចុះបញ្ជីពន្ធដារ និងការការដាក់ពាក្យស្នើសុំនៅរដ្ឋបានសារពើពន្ធ**

ទម្រង់101(ធំ-អ្នកជាប់ពន្ធមធ្យម) ទម្រង់101(អ្នកជាប់ពន្ធ)






ទម្រង់អាករលើតម្លៃបន្ថែម ១០១ គឺជាពាក្យស្នើសុំចុះបញ្ជីសម្រាប់បុគ្គលជាប់អាករ ហើយក៏អាចប្រើជាពាក្យស្នើសុំចុះបញ្ជី ដោយស្ម័គ្រចិត្តផងដែរ។ ទម្រង់នេះត្រូវបានផ្តល់ជូនលោក/លោកស្រីដោយនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ។ លោក/លោកស្រីត្រូវបំពេញទម្រង់នេះនិងផ្តល់នូវព័ត៌មានបន្ថែមនានាទៅតាមការតម្រូវ ហើយយកទម្រង់ នេះទៅដាក់ជូន នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥នៃខែបន្ទាប់ពីខែដែលផលរបររបស់លោក/លោកស្រីមានការកើនឡើងលើសពីកំរិតអប្បបរមានៃផលរបរត្រូវចុះបញ្ជី។ចំពោះក្រុមហ៊ុនដើមទុនគ្រប់ប្រភេទអ្នកនាំចេញនាំចូលសហគ្រាសវិនិយោគ ឬអង្គភាពរបស់រដ្ឋត្រូវបំពេញទម្រង់ហើយយកទៅ ដាក់ជូននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំទៅមុនពេលចាប់ផ្តើមប្រកបអាជីវកម្ម។ ចំពោះការយឺតយ៉ាវក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីលោក/លោកស្រីនឹងត្រូវទទួលរងទោសទណ្ឌទៅតាមច្បាប់ស្តីពីសារពើពន្ធ។ នៅពេលដាក់ពាក្យស្នើសុំចុះបញ្ជី អគ្គនាយកដ្ឋានពន្ធដារនឹងផ្តល់ជូនលោក/លោកស្រីនូវលេខចុះបញ្ជីដែលជាលេខ អត្តសញ្ញាណកម្មអាករលើតម្លៃបន្ថែមរបស់លោក/លោកស្រី។វិញ្ញាបនប័ត្រចុះបញ្ជីត្រូវបានផ្តល់ជូនលោក/លោកស្រី ហើយត្រូវតាំងឬព្យួរវិញ្ញាបនប័ត្រនេះនៅទីកន្លែងអាជីវកម្មជាសំខាន់របស់ខ្លួន។ ប្រសិនបើការដាក់ពាក្យស្នើសុំចុះបញ្ជីត្រូវបានបដិសេធអគ្គនាយកដ្ឋានពន្ធដារនឹងជូនដំណឹងដល់លោក/លោកស្រីដោយភ្ជាប់ជាមួយនូវសេចក្តីដិសេធពន្យល់ផ្សេងៗដែលជាហេតុផលនៃការបេ[8]។

## ២.៣ នីតិវិធីនៃការប្រមូលចំណូលពន្ធ

### ២.៣.១ និយមន័យនីតិ

នីតិ គឺជាវិធានទាំងអស់ដែលគ្រប់គ្រងការរស់នៅក្នុងសង្គម ហើយដែលត្រូវអនុវត្តន៍ និងផ្តន្ទាទោសដោយអំណាចសាធារណៈ។

នីតិ វាខុសពីប្រពៃណីទំនៀមទម្លាប់ សីលធម៌និងសាសនាព្រោះ នីតិត្រូវបានជានាការអនុវត្តដោយអំណាចរដ្ឋ។

នីតិ កើតឡើងពីឆន្ទៈរួម ដែលចង់រស់នៅដោយសុខសាន្ត និងមានសិទ្ធិសេរីភាព[9]។

### ២.៣.២ ប្រភេទនីតិ

នីតិមានប្រភពច្រើន ក្នុងនោះរួមមាន៖

តាមការវិវត្តរបស់សង្គមសហគមន៍

- ការរស់នៅហួសព្រំដែននៃសេរីភាពរបស់មនុស្ស
- មនុស្សចង់មានចង់បានហួសហេតុ
- មនុស្សមានជម្លោះរវាងគ្នានិងគ្នាឈានទៅរកការមានជម្លោះ
- នៅក្នុងសង្គមនោះមានសមាជិកច្រើនៗការផ្គត់ផ្គង់មិនគ្រប់គ្រាន់តាមតម្រូវការ
- ការប្រើប្រាស់អំណាចផ្តាច់ការឈានទៅដល់ការបង្កើនបទដ្ឋានដែលមានលក្ខណៈទំនើប
- ហើយបទដ្ឋានទំនើបទាំងនោះ ដើម្បីរក្សាសណ្តាប់ធ្នាប់របៀបរៀបរយសេចក្តីថ្លៃថ្នូរនិងសន្តិភាពទើបមានការកើតនូវនីតិឡើង

[8] វិទ្យាស្ថាន វ៉ាន់ដារបាយការស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១៩ទំព័រទី១០ របស់និស្សិតឈ្មោះម៉ែន វ៉ាន់ឌី

[9] https://www.ccc.gov.kh/admin/uploads/A-012-Constitutional.pdf

- ម៉្យាងវិញទៀតការកកើតនូវនីតិ គឺមិនមានលក្ខណៈវណ្ណៈ និងជាឧបករណ៍របស់វណ្ណៈខ្លាំង ឬ ខ្សោយណាមួយទេ
- ជាស្មារតីទូទៅច្បាប់តែងតែលើកតម្កើងដល់តម្លៃសីលធម៌សេដ្ឋកិច្ចនិងនយោបាយរបស់សង្គម ជាតិយើង
- ដោយហេតុនេះ ហើយទើបគេសង្កេតឃើញថាច្បាប់ពីប្រទេសមួយទៅប្រទេសមួយទៀតតែងតែមានលក្ខណៈខុសៗគ្នា
- តួយ៉ាងដូចជាច្បាប់នៅក្នុងបណ្តាប្រទេសដែលគោរពនិងប្រកាន់សាសនាឥស្លាមដូចជាប្រទេសអ៊ីរ៉ង់ ប្រទេសប៉ាគីស្ថានប្រទេសឥណ្ឌូនេស៊ី
- តែងតែមានលក្ខណៈខុសប្លែកគ្នាពីបណ្តាប្រទេសដែលប្រកាន់តាមសាសនាព្រះពុទ្ធសាសនាកាទូលិកដូចជាប្រទេសថៃ ប្រទេសអ៊ីតាលី ប្រទេសម៉ិកស៊ិក..ជាដើម។ ច្បាប់ដែលមានប្រជាពលរដ្ឋ ភាគច្រើនមានក្រុមជាតិសាសន៍ដូចគ្នា ដូចជាប្រទេសវៀតណាមអាចមានលក្ខណៈខុសប្លែកពី បណ្តាប្រទេសដែលប្រកាន់សាសនាខុសៗគ្នា ដូចជាប្រទេសកាណាដា ប្រទេសឥណ្ឌា។
- ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយក្នុងករណីដែលតម្លៃសង្គមមានការផ្លាស់ប្តូរពេលនោះច្បាប់ក៏ ត្រូវមានការផ្លាស់ប្តូរផងដែរ។
- តាមផ្លូវច្បាប់ និងតាមការស្រាវជ្រាវកន្លងមក នីតិមានប្រភពសំខាន់ៗ ២ យ៉ាងគឺ៖
  ១. ប្រភពសរសេរជាលាយលក្ខណ៍អក្សរ (Written)
  ២. និងប្រភពមិនសរសេរជាលាយលក្ខណ៍អក្សរ (Unwritten) [10]។

**២.៣.៣ តួនាទីនីតិ**

តួនាទីជាច្រើនដូចខាងក្រោម៖

- គ្រប់គ្រងសាខាពន្ធដារខេត្ត-ខណ្ឌ
- គ្រប់គ្រងនិងប្រមូលពន្ធពីអ្នកជាប់តូចនិងមធ្យម
- ផ្តល់សេវាដល់អ្នកជាប់ពន្ធដើម្បីពង្រឹងការគោរពបទប្បញ្ញត្តិស្តីពីពន្ធដារ
- គ្រប់គ្រង និងចាត់ចែងការដាក់លិខិតប្រកាសសារពើពន្ធរបស់អ្នកជាប់ពន្ធតូចនិងមធ្យម
- រៀបចំ និងអនុវត្តកម្មវិធីសវនម្មលើឯកសារ និងសវនកម្មមានកម្រិត និងសវនកម្មបង្វិល សង
- រៀបចំផែនការ និងអនុវត្តការទារបំណុលពន្ធ
- ចុះបញ្ជីអ្នកជាប់ពន្ធ ចេញប័ណ្ណប៉ាតង់ កាន់កាប់ថែរក្សាបញ្ជីអ្នកជាប់ពន្ធ ចុះបញ្ជីពន្ធ អចលនទ្រព្យ និងចេញវិញ្ញាបនបត្រចុះបញ្ជី តាមប្រភេទពន្ធនានាដែលតម្រូវដោយច្បាប់និងកត់ត្រាទិន្នន័យបច្ចុប្បន្នភាពអ្នកជាប់ពន្ធក្នុងប្រព័ន្ធកុំព្យូទ័រ
- ទទួលបន្ទុកក្នុងការប្រមូលពន្ធមានជាអាទិ៍ពន្ធប្រថាប់ត្រាលើកិច្ចសន្យាផ្គត់ផ្គង់ទំនិញឬសេវាដែលប្រើប្រាស់ថវិការរដ្ឋនិង លើការផ្ទេរភាគហ៊ុនពាក់ព័ន្ធពន្ធតូចនិងមធ្យមពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ពន្ធលើអចលនទ្រព្យ ពន្ធលើអចលនទ្រព្យ ពន្ធលើឈ្នួលផ្ទះ និងដី និងពន្ធតែមប្រ៊ី
- សហការ និងចូលរួមចំណែកក្នុងការងារនានាពាក់ព័ន្ធនឹងពន្ធដារ។

[10] វិទ្យាស្ថាន វ៉ាន់ដារបាយការស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១៩ទំព័រទី១០-១១ របស់និស្សិតឈ្មោះម៉ែន វ៉ាន់ឌី

- បណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាពមន្ត្រីក្នុងសាខា
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនទីចាត់ការពន្ធដាររាជធានីភ្នំពេញសម្រាប់សាខាពន្ធដារខេណ្ឌ និងជូនអគ្គនាយកគ្រប់គ្រងអ្នកជាប់ពន្ធ តូច និងមធ្យម
- បំពេញភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់អគ្គនាយកដ្ឋាននៃអគ្គនាយកដ្ឋានពន្ធដារ
- យល់ដឹងអំពីសិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ
- យល់ដឹងឲ្យកាន់តែច្បាស់អំពីច្បាប់សារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា
- ស្គាល់អំពីនីតិវិធីនៅក្នុងការប្រមូលពន្ធ
- យល់ដឹងអំពីការធ្វើសវនកម្មរបស់ពន្ធដារ
- យល់ដឹងអំពីនីតិវិធីនៃការទូទាត់ និងទារបំណុល
- យល់ដឹងអំពីនីតិវិធីនៃការដាក់លិខិតប្រកាសពន្ធប្រចាំខែ និងឆ្នាំ
- ផ្តល់ជាឯកសារសម្រាប់និស្សិតជំនាន់ក្រោយ ក្នុងការសិក្សាស្រាវជ្រាវបន្ថែមទៅលើ
- ប្រធានបទដែលទាក់ទងទៅនឹងនីតិវិធីនៃការប្រមូលពន្ធ
- អាចទទួលបាននូវបទពិសោធន៍ជាក់ស្តែង ដើម្បីយកទៅអនុវត្តក្នុងសកម្មភាពការងារជាក់ស្តែង។
- ធ្វើឱ្យមានរបៀបរៀបរយល្អក្នុងសង្គម ជៀសវាងជម្លោះ ដោះស្រាយដោយសន្តិវិធី
- ធ្វើឱ្យមានការប្រាស្រ័យទាក់ទងគ្នារវាងមនុស្ស និងមនុស្ស
- កំណត់នូវព្រំដែនអំណាច និងអំពើរបស់អ្នកដឹកនាំ និងសម្រួលខ្នាតតម្លៃសីលធម៌
- មិនឱ្យអ្នកដឹកនាំធ្វើអ្វីតាមអំពើចិត្ត
- ការពារអ្នកទន់ខ្សោយ លើកស្ទួយយុត្តិធម៌សង្គម
- ជួយសម្រួលឱ្យមានការចូលរួមពីប្រជាជន
- ការពារ និងផ្តល់សេរីភាពដល់បុគ្គលម្នាក់ៗ[11]។

[11] វិទ្យាស្ថាន វ៉ាន់ដារបាយការស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១៩ទំព័រទី១១ របស់និស្សិតឈ្មោះម៉ែន វ៉ាន់ឌី

# ជំពូកទី ៣
# ចំណូលពីការប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ

## ៣.១ ស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ

### ៣.១.១ សញ្ញាសម្គាល់

ខាងក្រោមនេះគឺជាសញ្ញាសម្គាល់របស់អគ្គនាយកដ្ឋានពន្ធដារ

រូបភាពទី១៖ សញ្ញាសម្គាល់




### ៣.១.២ ប្រវត្តិ និងទីតាំងភូមិសាស្ត្រ

រូបភាពទី២៖ អគ្គនាយកដ្ឋានពន្ធដារ



អគ្គនាយកដ្ឋានពន្ធដារដំបូងឡើយមានឈ្មោះថា នាយកដ្ឋានពន្ធដារ បានបង្កើតឡើងក្នុងឆ្នាំ ១៩៥៣ តែត្រូវបានលុបបំបាត់វិញក្នុងរបបប្រល័យពូជសាសន៍ក្នុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ក្រោយរបបប្រល័យពូជសាសន៍ត្រូវបានដួលរលំនាយកដ្ឋានពន្ធដារបានបង្កើតឡើងវិញក្នុងឆ្នាំ១៩៨០ បន្ទាប់មកនាយកដ្ឋានពន្ធដារបានដំឡើងឈ្មោះទៅជាអគ្គនាយកដ្ឋានពន្ធដារក្នុងឆ្នាំ២០១១ រហូតមកដល់បច្ចុប្បន្នស្ថិតក្រោមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

សរុបរួមប្រវត្តិរបស់អង្គភាពពន្ធដារ

-1953: ត្រូវបានបង្កើតឡើងជានាយកដ្ឋានពន្ធដារ

-1975ដល់ 1979: ពន្ធដារត្រូវលុបបំបាត់ចោលដោយរបបប៉ុលពត

-1980: នាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើងវិញ

- 2008: នាយកដ្ឋានពន្ធដារបានដំឡើងទៅជាអគ្គនាយកដ្ឋានពន្ធដារដោយសាលាជាតិ

មានទីតាំងបច្ចុប្បន្ននេះនៅអគារកែងមហាវិថីសហព័ន្ធរុស្ស៊ី(១១០)និងម៉ៅសេទុង(២៤៥)សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោករាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា។ អាចទំនាក់ទំនងបានតាមរយៈ លេខទូរសព្ទ(+885)23 886 725 ទូរសារ: (+885)23 886 725,Email: dea@tax.gov.kh, website: www.tax.gov.kh

**៣.១.៣ អគ្គនាយកដ្ឋានពន្ធដារតួនាទី និងភារកិច្ច**

អគ្គនាយកដ្ឋានពន្ធដារមានភារកិច្ចជាអាទ៍ដូចតទៅ៖

- រៀបចំគោលនយោបាយសារពើពន្ធ និងការប្រមូលពន្ធគ្រប់ប្រភេទបង់ចូលថវិកាជាតិ
- រៀបចំសេចក្តីព្រាងច្បាប់លិខិតបទដ្ឋាននានាស្តីពីពន្ធដារ កំណត់បញ្ជីឯកសារចាំបាច់នានា និងលិខិតយុត្តិការ ដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវកាន់កាប់រក្សារទុក និងផ្តល់ជូនរដ្ឋបាលសារពើពន្ធ
- កំណត់មូលដ្ឋានគិតពន្ធគិតពន្ធលើអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកដោយផ្អែកលើការអង្កេតនិងផ្តុំព័ត៌មាន
- គណនា និងប្រមូលប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងចំណូលផ្សេងៗ
- កសាងកម្មវិធី និងអនុវត្តការងារសវនកម្មចំពោះអ្នកជាប់ពន្ធ
- ទទួលបន្ទុកសហការប្រតិបត្តិការអន្តរជាតិក្នុងផ្នែកពន្ធ
- អនុវត្តទោសទណ្ឌតាមច្បាប់ចំពោះអ្នកជាប់ពន្ធ និងភ្នាក់ងារកាត់ទុក ដែលល្មើសបទប្បញ្ញត្តិនានាស្តីពីពន្ធដារចូលរួមរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំដើម្បី បញ្ជូនទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ។ អគ្គនាយកដ្ឋានពន្ធដើម្បីបង្កើនប្រសិទ្ធិភាពកិច្ច ដំណើរការការងារនិងប្រព័ន្ធការងារដែលមានភាពច្បាស់លាស់ទំនើបទៅនិង មានការទទួលខុសត្រូវខ្ពស់ចំពោះការងាររបស់ខ្លួនក្នុងការគ្រប់គ្រងតាមរយៈគោលនយោបាយ។

**៣.១.៤ រចនាសម្ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ**

**រចនាសម្ព័ន្ធនៃការគ្រប់គ្រង**

ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

ឯកឧត្តម **អ៊ុំ សីហា** អគ្គនាយករង

ឯកឧត្តម **ជាប ជាវុធ** អគ្គនាយករង

ឯកឧត្តម **ម៉ិញ បានកុសល** អគ្គនាយករង

ឯកឧត្តម **កែន សម្បត្តិ** អគ្គនាយករង

ឯកឧត្តម **ហេង សុខណាង** អគ្គនាយករង

លោកជំទាវ **ប៊ុន នារី** អគ្គនាយិការង

លោក **លឹម ដឹលុច្ប** អគ្គនាយករង

**នាយកដ្ឋាននៃអគ្គនាយកដ្ឋានពន្ធដារ**

1. នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
2. នាយកដ្ឋានហិរញ្ញវត្ថុ និងបុគ្គលិក
3. នាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ
4. នាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ
5. នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
6. នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ
7. នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
8. នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូច និងមធ្យម
9. នាយកដ្ឋានសវនកម្មសហគ្រាស
10. សាលាជាតិពន្ធដារ
11. ទីចាត់ការពន្ធដាររាជធានីភ្នំពេញ

**សាខាពន្ធដារខណ្ឌ-ខេត្ត**

1. សាខាពន្ធដារខណ្ឌ ឫស្សីកែវ
2. សាខាពន្ធដារខណ្ឌ ដូនពេញ
3. សាខាពន្ធដារខណ្ឌ ៧មករា
4. សាខាពន្ធដារខណ្ឌ មានជ័យ
5. សាខាពន្ធដារខណ្ឌ ចំការមន
6. សាខាពន្ធដារខណ្ឌ ទួលគោក
7. សាខាពន្ធដារខណ្ឌ ដង្កោ
8. សាខាពន្ធដារខណ្ឌ សែនសុខ
9. សាខាពន្ធដារខណ្ឌ ពោធិ៍សែនជ័យ
10. សាខាពន្ធដារខេត្ត កណ្ដាល
11. សាខាពន្ធដារខេត្ត កំពង់ចាម
12. សាខាពន្ធដារខេត្ត បាត់ដំបង
13. សាខាពន្ធដារខេត្ត ព្រៃវែង

14. សាខាពន្ធដារខេត្ត សៀមរាប
15. សាខាពន្ធដារខេត្ត កំពង់ធំ
16. សាខាពន្ធដារខេត្ត តាកែវ
17. សាខាពន្ធដារខេត្ត ស្វាយរៀង
18. សាខាពន្ធដារខេត្ត ពោធិ៍សាត់
19. សាខាពន្ធដារខេត្ត កំពង់ឆ្នាំង
20. សាខាពន្ធដារខេត្ត កំពង់ស្ពឺ
21. សាខាពន្ធដារខេត្ត កំពត
22. សាខាពន្ធដារខេត្ត ព្រះសីហនុ
23. សាខាពន្ធដារខេត្ត កោះកុង
24. សាខាពន្ធដារខេត្ត ព្រះវិហារ
25. សាខាពន្ធដារខេត្ត ក្រចេះ
26. សាខាពន្ធដារខេត្ត រតនគីរី
27. សាខាពន្ធដារខេត្ត មណ្ឌលគីរី
28. សាខាពន្ធដារខេត្ត បន្ទាយមានជ័យ
29. សាខាពន្ធដារខេត្ត ស្ទឹងត្រែង
30. សាខាពន្ធដារខេត្ត កែប
31. សាខាពន្ធដារខេត្ត ប៉ៃលិន
32. សាខាពន្ធដារខេត្ត ឧត្តរមានជ័យ
33. សាខាពន្ធដារខេត្ត ត្បូងឃ្មុំ

## តារាងទី១៖ រចនាសម្ព័ន្ធ



### ៣.១.៥ ទស្សនវិស័យ និង បេសកកម្ម

❖ **ទស្សនវិស័យ**

ចំពោះទស្សនវិស័យរបស់អគ្គនាយកដ្ឋានពន្ធដារ គឺធ្វើឱ្យមានការទទួលស្គាល់និងគោរពពីសំណាក់អ្នកជាប់ពន្ធចំពោះភាគីត្រឹមត្រូវនិងគុណភាពនៃការគ្រប់គ្រងគោលដៅនាពេលអនាគតរបស់ អគ្គនាយកដ្ឋាន គឺធ្វើយ៉ាងណាដើម្បីឱ្យប្រមូលពន្ធគ្រប់ផែនការ ឬលើសផែនការ ឬធ្វើការប្រមូល ពន្ធឱ្យអស់លទ្ធភាព។

❖ **បេសកកម្ម**

អគ្គនាយកដ្ឋានពន្ធដារ មានបេសកកម្មធ្វើឱ្យសម្រេចការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារតាមការៈ

- ផ្តល់សេវាដល់អ្នកជាប់ពន្ធរួមមានការផ្តល់ព័ត៌មានអប់រំពន្យល់ណែនាំ ដើម្បីឱ្យអ្នកជាប់ពន្ធប្រតិបត្តិតាមត្រឹមត្រូវ តាមច្បាប់និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- អនុវត្តតាមកម្មវិធីចាប់បង្ខំដោយធ្វើសវនកម្មការអនុវត្តវិធានការតឹងទារ និងអនុវត្តទោសទណ្ឌតាមការកំណត់នៃបទប្បញ្ញត្តិស្តីពីពន្ធដារចំពោះអ្នកជាប់ពន្ធដែល មិនបានប្រតិបត្តិត្រឹមត្រូវតាមច្បាប់និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- ប្រមូលចំណូលពន្ធ តាមការអនុវត្តត្រឹមត្រូវនូវច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ និងបង់គ្រប់គ្រាន់ចូលថវិកាជាតិ
- ផ្តល់សេវា និងការអប់រំអ្នកជាប់ពន្ធ ដើម្បីធានាឱ្យច្បាប់នានាស្តីពីពន្ធដារត្រូវបានគោរព និងអនុវត្តត្រឹមត្រូវ
- អនុវត្តតាមកម្មវិធីចាប់បង្ខំ ដោយប្រសិទ្ធភាព មានការទទួលខុសត្រូវខ្ពស់ និងស្មើភាពគ្នាចំពោះអ្នកជាប់ពន្ធដែលមិនគោរពច្បាប់ និងបទបញ្ញត្តិស្តីពីសារពើពន្ធ
- អនុវត្តគោលការណ៍យុត្តិធម៌ក្នុងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ដើម្បីបង្កើនការជឿទុកចិត្តចំពោះរដ្ឋបាលសារពើពន្ធ
- បន្ថយការចំណាយរបស់រដ្ឋបាលសារពើពន្ធ ក្នុងការរៀបចំកម្មវិធី និងកិច្ចដំណើរការរបស់ខ្លួនធ្វើឱ្យមានភាពសាមញ្ញចំពោះតម្រូវការផ្សេងៗ និងបន្ថយការចំណាយរបស់អ្នកជាប់ពន្ធ
- បង្កើនសមត្ថភាព ចំណេះដឹងដល់មន្ត្រីពន្ធដារជាប្រចាំ ដើម្បីបំពេញការងារឱ្យមានប្រសិទ្ធភាព
- បង្កើនសមត្ថភាពចំណេះដឹងដល់មន្ត្រីពន្ធដារជាប្រចាំ ដើម្បីបំពេញការងារឱ្យមានភាពប្រសើរឡើងនិងមានប្រសិទ្ធភាព បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងតាមរយៈ គោលនយោបាយ កិច្ចដំណើរការការងារ និងប្រព័ន្ធការងារដែលមានភាពច្បាស់លាស់ទំនើបនិងមានការទទួលខុសត្រូវខ្ពស់ចំពោះការងាររបស់ខ្លួន។

## ៣.២ ការនៃការប្រមូលរបស់អគ្គនាយកដ្ឋានពន្ធ

### ៣.២.១ ការប្រមូលចំណូលពន្ធដារ

ការប្រមូលចំណូលពន្ធដារចែកចេញជាពីរប្រភេទ ៖ ចំណូលថ្នាក់ជាតិ និង ចំណូលថ្នាក់ក្រោមជាតិ

#### ៣.២.១.១ ចំណូលថ្នាក់ជាតិ

១. ពន្ធលើប្រាក់ចំណូល

ពន្ធលើប្រាក់ចំណូលត្រូវបានកំណត់លើអ្នកជាប់ពន្ធនិវាសនជន ចំពោះប្រាក់ចំណូលប្រភពកម្ពុជា និងប្រាក់ចំណូលប្រភពបរទេស។ សម្រាប់អ្នកជាប់ពន្ធអនិវាសនជនពន្ធលើប្រាក់ចំណេញ កំណត់តែលើប្រាក់ចំណូលប្រភពកម្ពុជាប៉ុណ្ណោះ។ ប្រាក់ចំណេញជាប់ពន្ធ គឺជាប្រាក់ចំណេញសុទ្ធបានមកពីលទ្ធផលទាំងអស់នៃប្រតិបត្តិការអាជីវកម្ម គ្រប់ប្រភេទរួម បញ្ចូលទាំងចំណេញមូលធនដែលសម្រេចបានក្នុងពេលកំពុងប្រកបអាជីវកម្ម ឬនៅពេលបញ្ចប់អាជីវកម្មព្រមទាំងប្រាក់ចំណូលពីទ្រព្យសកម្មហិរញ្ញវត្ថុ ឬទ្រព្យសកម្មវិនិយោគការប្រាក់ថ្លៃឈ្នួលនិងសួយសារផង។ប្រាក់ចំណេញជាប់ពន្ធក៏រួមបញ្ចូលផងដែរនូវចំណេញមូលធនទាំងអស់ពីអចលនទ្រព្យទ្រព្យហិរញ្ញវត្ថុឬទ្រព្យវិនិយោគ ដែលសម្រេចបានមកពីប្រតិបត្តិការនានាក្រៅពីប្រតិបត្តិការអាជីវកម្ម។

អត្រាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំមានដូចតទៅ៖

ក- ២០ភាគរយ ចំពោះប្រាក់ចំណេញដែលសម្រេចបានដោយនីតិបុគ្គល

ខ- ៣០ភាគរយ ចំពោះប្រាក់ចំណេញដែលសម្រេចបានក្រោមកិច្ចសន្យាបែងចែកផលិតផលប្រេងកាត និងឧស្ម័ន ធម្មជាតិ ឬសម្រេចបានពីការធ្វើអាជីវកម្មលើធនធានធម្មជាតិរួមទាំង ព្រៃឈើ រ៉ែ មាស ឬត្បូង ថ្មមានតម្លៃនានា

គ- ៩ភាគរយ ចំពោះប្រាក់ចំណេញរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែល ទទួលស្គាល់ដោយ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាសម្រាប់រយៈពេលអន្តរកាល៥ឆ្នាំ ដោយគិតចាប់ផ្តើមពីប្រកាស ឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃ ព្រះរាជាណាចក្រកម្ពុជា

ឃ- ០ភាគរយ ចំពោះប្រាក់ចំណេញរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលស្ថិត នៅក្នុងរយៈ ពេលលើកលែងពន្ធដែលកំណត់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ង- តាមតារាងអត្រាពន្ធកំណើនតាមថ្នាក់ខាងក្រោមចំពោះប្រាក់ចំណេញដែលសម្រេចបានដោយរូប វន្តបុគ្គល និងចំណែកដែលត្រូវបែងចែកឱ្យសមាជិកម្នាក់ៗរបស់ក្រុមអាជីវកម្មដែលមិនត្រូវបានចាត់ទុកជា នីតិបុគ្គលៈ ភាគនៃប្រាក់ចំណេញប្រចាំឆ្នាំដែលត្រូវជាប់ពន្ធ អត្រាពន្ធ

ពី ០ ៛ ដល់ ៦.០០០.០០០៛ 0%

ពី ៦.០០០.០០១ ៛ ដល់ ១៥.០០០.០០០ ៛ ៥%

ពី ១៥.០០០.០០១ ៛ ដល់ ១០២.០០០.០០០ ៛ ១០%

ពី ១០២.០០០.០០១ ៛ ដល់ ១៥០.០០០.០០០ ៛ ១៥%

លើសពី ១៥០.០០០.០០០ ៛ ២០%

ច- ចំពោះសហគ្រាសដែលមានសកម្មភាពជាសំខាន់ក្នុងការធានារ៉ាប់រងឬ ធានារ៉ាប់រងបន្តលើជីវិត ទ្រព្យសម្បត្តិ ឬហានិភ័យផ្សេងៗ ពន្ធលើប្រាក់ចំណេញត្រូវបានកំណត់ខាងក្រោម៖

- ៥% នៃបុព្វលាភធានារ៉ាប់រងដុលដែលទទួលបាននៅក្នុងឆ្នាំជាប់ពន្ធ ចំពោះការធានារ៉ាប់រង ឬ ធានារ៉ាប់រងបន្ត នូវហានិភ័យនៅព្រះរាជាណាចក្រកម្ពុជា សហគ្រាស និង

- តាមអត្រាទាំងឡាយដូចមានចែងក្នុងចំណុច ១-២-៣-៤និង៥ ខាងលើ ចំពោះសកម្មភាពដទៃ ទៀត ដែលមិនមែនជាការធានារ៉ាប់រង ឬធានារ៉ាប់រងបន្តប្រាក់រំដោះពន្ធលើប្រាក់ចំណេញ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស រួមទាំងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលជាប់ពន្ធលើប្រាក់ចំណេញតាមអត្រា៩% ត្រូវមានកាតព្វកិច្ចបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញប្រចាំខែតាមអត្រា ១% នៃផលរបរគិតរួមបញ្ចូលទាំងពន្ធអាករទាំងអស់វៀរលែងតែអាករលើតម្លៃបន្ថែមដែលសម្រេច បានក្នុងខែមុន យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ នៃខែបន្ទាប់។ ផលរបរនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលស្ថិតក្នុងរយៈពេលលើកលែងពន្ធត្រូវបានលើកលែងពីការបង់ប្រាក់រំដោះនេះ។ ប្រាក់រំដោះពន្ធលើប្រាក់ចំណេញនឹងត្រូវបានយកទៅកាត់កងពីពន្ធលើប្រាក់ចំណេញ នៅពេលធ្វើការទូទាត់ប្រចាំឆ្នាំ។

ពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ

នៅពេលបែងចែកភាគលាភ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវបង់ពន្ធលើប្រាក់ចំណេញបន្ថែមលើការបែង ចែកភាគលាភដូចតទៅៈ

- ពន្ធលើប្រាក់ចំណេញបន្ថែមត្រូវបង់ក្នុងចំនួនស្មើនឹង ២០ភាគរយ នៃទឹកប្រាក់ត្រូវបែងចែកចំពោះ :
  - ការបែងចែកប្រាក់ចំណេញរក្សាទុកឬប្រាក់ចំណេញប្រចាំឆ្នាំក្រោយការបង់ពន្ធលើប្រាក់ចំណេញ ប្រសិនបើអ្នកជាប់ពន្ធធ្វើការបែងចែកប្រាក់ចំណេញរក្សាទុកឬប្រាក់ចំណេញប្រចាំឆ្នាំ ដែលបានបង់ពន្ធលើ ប្រាកប់ចំណេញ តាមអត្រា ០ភាគរយ
  - ការបែងចែកដទៃទៀត វៀរលែងតែការបែងចែកដែលបានកំណត់ក្នុងចំណុច២និង ៣ ខាងក្រោម នេះ និងការបង់សងវិញនូវមូលធន
- ពន្ធលើប្រាក់ចំណេញបន្ថែមត្រូវបង់ក្នុងចំនួនស្មើនឹង ១១ភាគ៨១ នៃទឹកប្រាក់ត្រូវបែងចែកចំពោះការបែងចែកប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំក្រោយការបង់ពន្ធលើប្រាក់ចំណេញ ប្រសិនបើអ្នកជាប់ពន្ធធ្វើការបែងចែក ប្រាក់ចំណេញរក្សាទុក ប្រាក់ចំណេញប្រចាំឆ្នាំ ដែលបានបង់ពន្ធលើប្រាក់ ចំណេញ តាមអត្រា ៩ភាគរយ
- ពន្ធលើប្រាក់ចំណេញបន្ថែមមិនត្រូវអនុវត្តទេចំពោះការ បែងចែកប្រាក់ចំណេញរក្សាទុកឬប្រាក់ចំណេញប្រចាំឆ្នាំក្រោយការបង់ពន្ធលើប្រាក់ចំណេញប្រសិនបើអ្នកជាប់ពន្ធធ្វើការបែងចែកប្រាក់ចំណេញរក្សាទុកឬប្រាក់ចំណេញប្រចាំឆ្នាំដែលបានបង់ពន្ធលើប្រាក់ចំណេញតាមអត្រា ២០ភាគរយ ឬអត្រា ៣០ ភាគរយ។

- ពន្ធកាត់ទុកលើនិវាសនជន អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្មដែលបានធ្វើការទូទាត់ជាសាច់ប្រាក់ឬជាវត្ថុឱ្យដល់អ្នកជាប់ពន្ធ និវាសនជនត្រូវកាត់ទុកនិងបង់ប្រាក់ពន្ធទៅតាមអត្រាដូចខាងក្រោមលើចំនួនទូទាត់មុនការកាត់ ទុកប្រាក់ពន្ធ

ក. អត្រា ១៥% ចំពោះ៖

- ប្រាក់ចំណូលដែលរូបវន្តបុគ្គលបានទទួលពីការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់ឬសេវាប្រហាក់ប្រហែល
- សួយសារចំពោះទ្រព្យអរូបបីនិងភាគកម្មក្នុងធនធានរ៉ែ ហើយនិងការប្រាក់ដែលអ្នកជាប់ពន្ធនិវាសនជន ដែលប្រកបអាជីវកម្មដែលមិនមែនជាធនាគារឬស្ថាប័នសញ្ញ័យធនក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន

ខ. អត្រា ១០% ចំពោះប្រាក់ចំណូលពីការឱ្យជួលចលនឬអចលនទ្រព្យ

គ. អត្រា៦% ចំពោះការប្រាក់ដែលធនាគារឬស្ថាប័នសញ្ញ័យធនក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធ និវាសនជនដែល មានគណនីបញ្ញើមានកាលកំណត់

ឃ. អត្រា៤%ចំពោះការប្រាក់ដែលធនាគារឬស្ថាប័នសញ្ញ័យធនក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជនដែល មានគណនីសន្សំគ្មានកាលកំណត់ ការកាត់ទុកខាងលើនេះ មិនត្រូវអនុវត្តទេចំពោះការប្រាក់ដែលបង់ទៅឱ្យធនាគារនិងស្ថាប័នសញ្ញ័យធនក្នុង ស្រុកនិងការទូទាត់ចំពោះប្រាក់ចំណូលលើកលែងពន្ធដូចមានចែងក្នុងមាត្រា៩ថ្មីនៃច្បាប់ស្តីពីសារពើពន្ធ។

### ២ ពន្ធកាត់ទុកលើមនិវាសនជន

អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្មដែលធ្វើការទូទាត់ប្រាក់ចំណូលដូចខាងក្រោមនេះ ឱ្យទៅអ្នកជាប់ពន្ធ អនិវាសនជនត្រូវកាត់ទុកនិងបង់នូវប្រាក់ពន្ធតាមអត្រា ១៤% នៃទឹកប្រាក់ត្រូវបើក៖

ក. ការប្រាក់

ខ. សួយសារ ថ្លៃឈ្នួល និងប្រាក់ចំណូលផ្សេងៗទាក់ទិននិងការប្រើប្រាស់ទ្រព្យសម្បត្តិ

គ. ការទូទាត់ចំពោះសេវាគ្រប់គ្រង និងសេវាបច្ចេកទេសនានា

ឃ.ភាគលាភសហគ្រាសក្រុមហ៊ុនត្រូវដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធដែលបានកាត់ទុកក្នុងរយៈពេល ១៥ថ្ងៃ ក្រោយដំណាច់ខែដែលមានការទូទាត់។ ពេលកាត់ទុកគឺជាពេលដែលចំណាយត្រូវបានកត់ត្រាក្នុងបញ្ជីគណនេយ្យ។

- ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ

សហគ្រាសដែលជាប់ពន្ធលើប្រាក់ចំណេញ តាមរបបពិតរួមទាំងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលជាប់ពន្ធលើប្រាក់ចំណេញតាមអត្រា៩%មានកាតព្វកិច្ចបង់ប្រាក់រំដោះប្រចាំខែសម្រាប់ពន្ធលើប្រាក់ចំណេញតាមអត្រា១% នៃផលរបរគិតរួមបញ្ចូលទាំងពន្ធអាករទាំងអស់វៀរលែងតែអាករលើតម្លៃបន្ថែមដែលសម្រេចបានក្នុងខែមុន។ ប្រាក់រំដោះនឹងត្រូវបានយកមកកាត់កងពីពន្ធលើប្រាក់ចំណេញនៅពេលធ្វើការទូទាត់ប្រចាំឆ្នាំ។

## ៣ ពន្ធអប្បបរមា

ពន្ធអប្បបរមាជាពន្ធមួយដាច់ដោយឡែកនិងផ្សេងៗពីពន្ធលើប្រាក់ចំណេញ។ ពន្ធនេះត្រូវបង់ដោយអ្នកជាប់ ពន្ធតាមរបបស្វ័យប្រកាសលើកលែងតែគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ តាមអត្រា១ភាគរយលើផលរបរប្រចាំឆ្នាំរួមបញ្ចូលទាំងពន្ធអាករនានាវៀរលែងតែអាករលើតម្លៃបន្ថែម។ ពន្ធនេះត្រូវបង់នៅពេលទូទាត់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ហើយអាចត្រូវបានកាត់បន្ថយដោយពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ។

## ៤ ពន្ធកាត់ទុក

ពន្ធកាត់ទុកទូទៅត្រូវបានកំណត់ដូចតទៅៈ

- អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្មដែលបានធ្វើការទូទាត់ជាសាច់ប្រាក់ឬជាវត្ថុឱ្យដល់អ្នកជាប់ពន្ធនិវាសនជន ត្រូវកាត់ទុកនិងបង់ប្រាក់ពន្ធទៅតាមអត្រាកំណត់ដូចខាងក្រោមលើការទូទាត់មុនការកាត់ទុកប្រាក់ពន្ធ
- អត្រា ១៥ ភាគរយចំពោះ ប្រាក់ចំណូលដែលរូបវន្តបុគ្គលបានទទួលពីការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់ ឬសេវាប្រហាក់ប្រហែល សួយសារចំពោះទ្រព្យអរូបីនិងភាគកម្មក្នុងធនធានរ៉ែ ហើយនិងការប្រាក់ដែលអ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្មដែលមិនមែនជាធនាគារ ឬស្ថាប័នសញ្ញ័យធនក្នុងស្រុកបង់ឱ្យទៅ អ្នកជាប់ពន្ធនិវាសនជន
- អត្រា ១០ ភាគរយ ចំពោះប្រាក់ចំណូលពីការឱ្យជួលចលន ឬអចលនទ្រព្យ
- អត្រា ៦ ភាគរយ ចំពោះការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ញ័យក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសន ជនដែល មានគណនីបញ្ញើមានការកំណត់
- អត្រា ៤ ភាគរយ ចំពោះការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ញ័យក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសន ជនដែល មានគណនីសន្សំគ្មានការកំណត់
- ការកាត់ទុកក្នុងមាត្រានេះមិនត្រូវអនុវត្តទេចំពោះការប្រាក់ ដែលបង់ឱ្យធនាគារនិងស្ថាប័នសញ្ញ័យធនក្នុងស្រុកនិងការទូទាត់ចំពោះប្រាក់ចំណូល លើកលែងពន្ធដូចមានចែងក្នុងមាត្រា៩ថ្មីនៃច្បាប់នេះ។

- អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ដែលបានទូទាត់ប្រាក់ចំណូលខាងក្រោមនេះ ឱ្យទៅអ្នកជាប់ ពន្ធអនិវាសនជន ត្រូវកាត់ ទុកនិងបង់នូវប្រាក់ពន្ធ ចំនួន ១៤ ភាគរយនៃទឹកប្រាក់ត្រូវបើក
- ការប្រាក់
- សួយសារ ថ្លៃឈ្នួល និងប្រាក់ចំណូលផ្សេងៗ ទាក់ទិននឹងការប្រើប្រាស់ទ្រព្យសម្បត្តិ
- ការទូទាត់ចំពោះសេវាគ្រប់គ្រង និងសេវាបច្ចេកទេសនានា ដែលនិងត្រូវកំណត់ដោយប្រកាសរបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ភាគលាភ

- ពន្ធកាត់ទុកលើការទូទាត់ឱ្យដល់អ្នកជាប់ពន្ធនិវាសនជនតាមមាត្រា ២៥ថ្មី នៃច្បាប់នេះនិងពន្ធការទុកលើការទូទាត់ឱ្យដល់អនិវាសនជនតាមមាត្រា ២៦ថ្មីនៃច្បាប់នេះ ត្រូវចាត់ទុកថាជាពន្ធចុងក្រោយសម្រាប់អ្នក ទទួលការទូទាត់ដែលមានបញ្ជាក់ក្នុង មាត្រាទាំង២ ខាងលើនេះ។

## ៥ ពន្ធលើប្រាក់បៀវត្ស

ពន្ធលើប្រាក់បៀវត្ស គឺជាពន្ធប្រចាំខែកំណត់លើប្រាក់បៀវត្សដែលរូបវន្តបុគ្គលបានទទួលក្នុង ក្របខ័ណ្ឌនៃការ បំពេញសកម្មភាពបំរើការងារ។ រូបវន្តបុគ្គលនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់ពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជានិងប្រាក់បៀវត្សប្រភពបរទេស។រូបវន្តអនិវាសនជនត្រូវជាប់ពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជា។ សហគ្រាសដែលជានិយោជក ត្រូវមាន កាតព្វកិច្ចកាត់ទុកពន្ធលើប្រាក់បៀវត្សនៅមុនពេល បើកប្រាក់បៀវត្សឱ្យដល់និយោជិត និងបង់ប្រាក់ពន្ធនេះ ជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតនៅថ្ងៃទី១៥នៃខែបន្ទាប់ ពីខែដែលប្រាក់បៀវត្សត្រូវបានបើក។ សម្រាប់និយោជិតនិវាសនជន ប្រាក់ពន្ធត្រូវបង់ត្រូវកំណត់លើប្រាក់បៀវត្សជាប់ពន្ធប្រចាំខែនិងត្រូវកាត់ទុក តាមអត្រា កំណើនតាមថ្នាក់ដូចតទៅៈ

ភាគបៀវត្សប្រចាំខែត្រូវជាប់ពន្ធ អត្រាពន្ធ

ពី ០ ៛ ដល់ ១,៥០០,០០០ ៛០%

ពី ១,៥០០,០០១ ៛ ដល់ ២,០០០,០០០ ៛ ៥%

ពី ២,០០០,០០១ ៛ ដល់ ៨,៥០០,០០០ ៛ ១០%

ពី ៨,៥០០,០០១ ៛ ដល់ ១២,៥០០,០០០ ៛ ១៥%

លើសពី ១២,៥០០,០០០ ៛ ២០%

សម្រាប់និយោជិតអនិវាសនជន ពន្ធលើប្រាក់បៀវត្សត្រូវបានកាត់ទុកតាមអត្រា ២០% នៃទឹកប្រាក់ត្រូវបើកឱ្យមុនការកាត់ទុក ពន្ធកាត់ទុកនេះគឺជាពន្ធចុងក្រោយនៃប្រាក់បៀវត្សសម្រាប់អនិវាសនជនជាអ្នក

ទទួល ប្រាក់បៀវត្ស។ ចំពោះអត្ថប្រយោជន៍បន្ថែមជារៀងរាល់ខែសហគ្រាសក្រុមហ៊ុនត្រូវកាត់ទុកនិងបង់ប្រាក់ពន្ធតាមអត្រា ២០% នៃតម្លៃសរុបរបស់អត្ថប្រយោជន៍បន្ថែម ដែលបានផ្តល់ឱ្យនិយោជិតទាំងអស់តម្លៃនៃ

អត្ថប្រយោជន៍បន្ថែមគឺជាតម្លៃទីផ្សាររួមទាំងពន្ធអាករទាំងអស់។

## ៦. អាករលើតម្លៃបន្ថែម

អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលធ្វើការផ្គត់ផ្គង់ជាប់អាករ ត្រូវមានកាតព្វកិច្ចចុះបញ្ជីអាករលើតម្លៃបន្ថែម និងប្រមូលអាករលើតម្លៃបន្ថែមលើការផ្គត់ផ្គង់ទំនិញឬសេវាឱ្យអតិថិជន។ ទំនិញសំដៅដល់ទ្រព្យរូបីក្រៅពីដីធ្លីនិងប្រាក់កាស រីឯសេវា សំដៅដល់ការផ្តល់អ្វីមួយដែលមានតម្លៃ ក្រៅពីទំនិញ ដីធ្លី និងប្រាក់កាស។ ការផ្គត់ផ្គង់ជាប់អាករសំដៅដល់៖

- ការផ្គត់ផ្គង់ទំនិញឬសេវាដោយបុគ្គលជាប់អាករនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ការដកយកទំនិញមកប្រើប្រាស់ផ្ទាល់ខ្លួនដោយបុគ្គលជាប់អាករ
- ការផ្តល់ជាអំណោយឬការផ្គត់ផ្គង់ក្រោមតម្លៃពិត នូវទំនិញឬសេវាដោយបុគ្គលជាប់អាករ
- ការនាំចូលទំនិញមកក្នុងតំបន់ត្រួតពិនិត្យគយនៃព្រះរាជាណាចក្រកម្ពុជា ការផ្គត់ផ្គង់មិនជាប់អាករមានដូចតទៅ
- សេវាប្រៃសណីយ៍សាធារណៈ
- សេវារបស់មន្ទីរពេទ្យនិងគ្លីនិក សេវាខាងវេជ្ជសាស្ត្រនិងទន្តសាស្ត្រនិងការលក់ទំនិញបន្ទាប់បន្សំខាងវេជ្ជសាស្ត្រ និងទន្តសាស្ត្រដែលទាក់ទិននិងការបំពេញសេវាទាំងនេះ
- សេវាដឹកជញ្ជូនអ្នកដំណើរដោយប្រព័ន្ធដឹកជញ្ជូនសាធារណៈដែលជាកម្មសិទ្ធិទាំងស្រុងរបស់រដ្ឋ
- សេវាធានារ៉ាប់រង
- សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ការនាំចូលសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនដែលរួចពន្ធគយ ក្នុងកម្រិតតម្លៃដែលត្រូវកំណត់ដោយប្រកាសរបស់ ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សកម្មភាពមិនស្វែងរកចំណេញដើម្បីបំរើផលប្រយោជន៍សាធារណៈ ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ការនាំចូលនិងការទិញទំនិញ សម្រាប់ឬដោយបេសកកម្មទូតនិងកុងស៊ុលបរទេសអង្គការអន្តរជាតិនិងទីភ្នាក់ងា រសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានាសម្រាប់យកមកប្រើនៅក្នុងការបំពេញមុខងាររដា ផ្លូវការរបស់ខ្លួន។

អត្រាអាករលើតម្លៃបន្ថែមមាន៖

- ១០% សម្រាប់ការនាំចូលឬការផ្គត់ផ្គង់ទំនិញឬសេវាក្នុងព្រះរាជាណាចក្រកម្ពុជា
- ០% សម្រាប់ការនាំចេញ

ការគណនាប្រាក់អាករត្រូវបង់

- ប្រាក់អាករដែលបានបង់នៅពេលនាំចូលទំនិញ ឬប្រាក់អាករដែលបានបង់លើការទិញទំនិញ ឬសេវា សម្រាប់ ប្រកបអាជីវកម្ម ហៅថា "អាករលើធាតុចូល"
- ប្រាក់អាករដែលបានគិតយកពីអតិថិជនពីការផ្គត់ផ្គង់ទំនិញឬសេវាហៅថា "អាករលើធាតុចេញ"
- ប្រាក់អាករត្រូវបង់ = អាករលើធាតុចេញ - អាករលើធាតុចូល

អាករលើធាតុចូលដែលមិនអាចកាត់កងបានៈ

អាករលើធាតុចូលដែលមិនអាចកាត់កងបានរួមមានប្រាក់អាករដែលបានបង់លើ

- ចំណាយទទួលភ្ញៀវការកំសាន្ត ឬការសម្រាកលំហែ លើកលែងតែបុគ្គលជាប់អាករមានអាជីវកម្មជាអ្នកផ្គត់ផ្គង់ការទទួលភ្ញៀវការកំសាន្ត ឬការសម្រាកលំហែ
- ការទិញឬការនាំចូលរថយន្ត លើកលែងតែបុគ្គលជាប់អាករប្រកបអាជីវកម្មជាអ្នកលក់ ឬជួលរថយន្ត
- ការទិញឬការនាំចូលផលិតផលតេលសិលាមួយចំនួនលើកលែងតែបុគ្គលជាប់អាករប្រកបអាជីវកម្មជាអ្នកផ្គត់ផ្គង់ផលិតផលតេលសិលា ទាំងនោះអ្នកជាប់ពន្ធដែលធ្វើការផ្គត់ផ្គង់ជាប់អាករនូវទំនិញឬសេវាត្រូវទទួលខុសត្រូវក្នុងការបង់ប្រាក់អាករជូនរដ្ឋបាលសារ ពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលមាន ការផ្គត់ផ្គង់។

**៧ អាករពិសេស**

អាករពិសេសត្រូវបានកំណត់លើទំនិញនិងសេវាមួយចំនួន។ ទំនិញដែលជាប់អាករនេះមានភេសជ្ជៈស្រាស្រាបៀរ (២០%) និង បារី (១៥%)។ សេវាមួយចំនួនមានសេវាលំហែកំសាន្ត (១០%) ការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាស (១០%) និងសេវាទូរស័ព្ទ(៣%) ។ អ្នកជាប់ពន្ធដែលផលិតទំនិញ ឬផ្គត់ផ្គង់សេវាទាំងនេះត្រូវ ទទួលខុសត្រូវក្នុងការបង់ប្រាក់អាករនេះជូនរដ្ឋបាលសារពើពន្ធយ៉ាង យឺតបំផុតត្រឹមថ្ងៃទី១៥ នៃខែបន្ទាប់ពីខែដែលមាន ការផ្គត់ផ្គង់។

**៣.២.១.២ ចំណូលថ្នាក់ក្រោមជាតិ**

**១.អាករលើការស្នាក់នៅ**

អាករលើការស្នាក់ត្រូវបានកំណត់តាមអត្រា ២% លើការស្នាក់នៅក្នុងសណ្ឋាគារ ផ្ទះសំណាក់ ក្នុងព្រះរាជាណាចក្រ។ អ្នកជាប់ពន្ធដែលធ្វើការផ្គត់ផ្គង់សេវាស្នាក់នៅត្រូវទទួលខុសត្រូវក្នុងការបង់ប្រាក់អាករនេះជូនរដ្ឋ បាលសារពើពន្ធ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ នៃខែបន្ទាប់ពីខែដែលមានការផ្គត់ផ្គង់។

**២.អាករសម្រាប់បំភ្លឺសាធារណៈ**

អាករសម្រាប់បំភ្លឺសាធារណៈ ត្រូវបានកំណត់តាមអត្រា ៣% លើការផ្គត់ផ្គង់គ្រប់ដំណាក់កាលនូវសុរាមេរ៉ៃ និង បារី។ អ្នកជាប់ពន្ធដែលធ្វើការផ្គត់ផ្គង់ផលិតផលទាំងនេះត្រូវទទួលខុសត្រូវក្នុងការបង់ប្រាក់អាករនេះ ជូនរដ្ឋបាលសារ ពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ នៃខែបន្ទាប់ពីខែដែលមានការផ្គត់ផ្គង់។

**៣.ពន្ធលើអចលនទ្រព្យ**

ពន្ធលើអចលនទ្រព្យ គោលបំណងវិចារណាភាវូបនីយកម្មក្នុងការប្រើប្រាស់ដី និងដើម្បីជាប្រយោជន៍ដល់ថវិការដ្ឋបាល ថ្នាក់ក្រោមជាតិ ត្រូវបង្កើតពន្ធលើអចលនទ្រព្យស្ថិតនៅក្នុងភូមិសាស្រ្តរដ្ឋបាលរាជធានីនិងខេត្ត នៃព្រះរាជាណាចក្រកម្ពុជា។ ពន្ធដែលត្រូវប្រមូលពីអចលនទ្រព្យទាំងអស់នេះតម្រូវតែលើអចលនទ្រព្យដែលមានតម្លៃលើសពី១០០,០០០,០០០(មួយរយលាន)រៀលសម្រាប់គោលដៅនៃពន្ធនេះពាក្យអចលនទ្រព្យសំដៅដល់ ដី ផ្ទះ អគារ និងសំណង់ផ្សេងៗដែលសង់ភ្ជាប់ នឹង ដីនោះ។ ពន្ធនេះត្រូវប្រមូលប្រចាំឆ្នាំតាមអត្រា ០,១% (សូន្យក្បៀសមួយភាគរយ) លើតម្លៃអចលនទ្រព្យ។ មូលដ្ឋានគិតពន្ធ គឺជាតម្លៃ ដី ផ្ទះអគារនិងសំណង់ផ្សេងៗ ដែលសង់ភ្ជាប់នឹងដីនោះដោយកាត់បន្ថយនូវទឹកប្រាក់ចំនួន ១០០,០០០,០០០ (មួយរយលាន) រៀល។ តម្លៃ ដី ផ្ទះ អគារ និងសំណង់ផ្សេងៗដែលសង់ភ្ជាប់នឹងដីនោះ ត្រូវកំណត់តាមតម្លៃទីផ្សារដោយ គណកម្មាការវាយតម្លៃអចលនទ្រព្យដែរបង្កើតដោយ ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**៤.ពន្ធលើមធ្យោបាយដឹកជញ្ជូន**

ពន្ធនេះត្រូវអនុវត្តទៅលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទអត្រាពន្ធនិងរយៈពេលត្រូវបង់ពន្ធត្រូវកំណត់តាមការប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**៥.ពន្ធលើផ្ទាំងផ្សព្វផ្សាយ**

ពន្ធលើផ្ទាំងផ្សព្វផ្សាយកំណត់លើលិខិតរដ្ឋបាលលិខិតតុលាការលិខិតក្រៅតុលាការនិងលើប័ណ្ណប្រកាស។ រាជរដ្ឋាភិបាលកំណត់ដែនអនុវត្តនិងតារាងពន្ធតែមប្រ៊ីដោយអនុក្រឹត្យ ហាមភ្នាក់ងារអាជ្ញាធរមានសមត្ថកិច្ចទទួល ឬចេញលិខិតត្រូវជាប់ពន្ធតែមប្រ៊ីដែលមិនទាន់បានបង់ពន្ធ។ ពន្ធតែមប្រ៊ីត្រូវបង់តាមការបិទសន្លឹកតែមប្រ៊ីឬតាមការបង់ប្រាក់ផ្ទាល់ដោយចេញបង្កាន់ដៃ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកំណត់បែបបទ និងលក្ខខ័ណ្ឌអនុវត្តការប្រមូលពន្ធតែមប្រ៊ីដោយប្រកាស។សន្លឹកតែមប្រ៊ីនីមួយៗមានតម្លៃ ១០០ រៀល ២០០រៀល ៥០០រៀល ១,០០០រៀល ២,០០០រៀល។ ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុគឺជាអង្គការមានសមត្ថកិច្ចតែមួយគត់ក្នុងការធ្វើការបោះពុម្ពសន្លឹកតែមប្រ៊ី។

**៦.ពន្ធប៉ាតង់**

ពន្ធប៉ាតង់ ពន្ធប៉ាតង់ជាពន្ធកំណត់លើផលរបរសរុបប្រចាំឆ្នាំ ដែលត្រូវបង់ក្នុងអំឡុងពេលចាប់ពីថ្ងៃទី០១ ខែមករាដល់ថ្ងៃទី៣១ ខែមីនាជារៀងរាល់ឆ្នាំអ្នកជាប់ពន្ធដែលទើបចាប់ផ្តើមប្រកបអាជីវកម្មត្រូវបង់ពន្ធប៉ាតង់ពេញមួយឆ្នាំប្រសិនបើចាប់ផ្តើមប្រកបអាជីវកម្មក្នុងរយៈពេល១២ខែដើមឆ្នាំ។ ករីណបង់ប្រាក់ពន្ធប៉ាតង់ពាក់កណ្តាលឆ្នាំ ប្រសិនបើចាប់ផ្តើមប្រកបអាជីវកម្ម ក្នុងរយៈពេល ៦ខែចុងឆ្នាំ។ អ្នកជាប់ពន្ធដែលមានសាខាឃ្លាំងរោងចក្ររោងជាង សម្រាប់មុខរបរអាជីវកម្មតែមួយនៅក្នុងខេត្ត/ក្រុងតែមួយមិនចាំបាច់បង់ពន្ធ

ប៉ាតង់ផ្សេងៗគ្នាទេប៉ុន្តែបើមានមុខរបរអាជីវកម្មខុសៗគ្នាឬស្ថិតនៅក្នុងខេត្ត/ ក្រុងផ្សេងៗគ្នាត្រូវបង់ពន្ធប៉ាតង់ទៅតាមមុខរបរនីមួយៗ និងទៅតាមខេត្ត/ក្រុងដោយឡែកៗពីគ្នា។ អ្នកជាប់ពន្ធត្រូវដាក់តាំងឬ ព្យួរប័ណ្ណប៉ាតង់នៅទីកន្លែងប្រកប អាជីវកម្មជាគោលដើមរបស់ខ្លួន។

## ៧.ពន្ធប្រថាប់ត្រា

- ពន្ធប្រថាប់ត្រាត្រូវកំណត់តាមអត្រា ៤% ចំពោះការផ្ទេរកម្មសិទ្ធិអចលនទ្រព្យ ឬ ការការផ្ទេរសិទ្ធិកាន់កាប់ដីដែលគ្មានសំណង់ក្រោមរូបភាពជាការលក់ការដោះដូរការទទួលអំណោយ ការដាក់ភាគទុនក្រុមហ៊ុន។
- ត្រូវជាប់ពន្ធប្រថាប់ត្រាតាមអត្រាសមាមាត្រ៤%ចំពោះការផ្ទេរកម្មសិទ្ធិមធ្យោបាយដឹកជញ្ជូននិងយាន ជំនិះដូចខាងក្រោម៖
  - រថយន្តដឹក ទំនិញធុនធ្ងន់ រថយន្តដឹកទំនិញធុនស្រាល រថយន្ត ទោចក្រយានយន្ត
  - កាណូត សាឡង់ កប៉ាល់
- លិខិតមានលក្ខណៈគតិយុត្តិដូចខាងក្រោម ត្រូវជាប់ពន្ធប្រថាប់ត្រា៖
  - លិខិតស្តីពីការបង្កើតក្រុមហ៊ុន ១,០០០,០០០ រៀល
  - លិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ១,០០០,០០០ រៀល
  - លិខិតស្តីពីការបិទក្រុមហ៊ុន ១,០០០,០០០ រៀល
- ០,១% នៃតម្លៃចុះកិច្ចសន្យាចំពោះកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវាដែលប្រើប្រាស់ថវិការដ្ឋ
- ០,១% នៃតម្លៃភាគហ៊ុនចំពោះការផ្ទេរចំណែកណា មួយឬទាំងស្រុងនៃភាគហ៊ុនរបស់ក្រុមហ៊ុនពន្ធប្រថាប់ត្រាត្រូវបានបង់ដោយអ្នកទទួលកម្មសិទ្ធិ ទទួលសិទ្ធិកាន់កាប់ដីធ្លីដែលគ្មានសំណង់គិតជាសមាត្រលើតម្លៃពិតប្រាកដនៃទ្រព្យសម្បត្តិនាថ្ងៃផ្ទេរកម្មសិទ្ធិនិងសិទ្ធិកាន់កាប់។ ប៉ុន្តែដើម្បីឱ្យមានភាពងាយស្រួលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចកំណត់តម្លៃសម្រាប់រយៈកាលនីមួយៗ ដើម្បីធ្វើជាមូលដ្ឋាន សម្រាប់ការគិតគូរប្រាក់ពន្ធដែល ត្រូវបង់។

## ៨.ពន្ធលើដីធ្លីមិនបានប្រើប្រាស់

ពន្ធលើដីធ្លីមិនបានប្រើប្រាស់ពន្ធនេះកំណត់លើដីដែលគ្មានសំណង់ និងដីដែលមានសំណង់បោះបង់ស្ថិតក្នុងទីក្រុងនានា និងក្នុងតំបន់ទាំងឡាយដែលកំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់។ ពន្ធដីធ្លីលើដីមិនបានប្រើប្រាស់ត្រូវបង់ដោយកម្មសិទ្ធិករមូលដ្ឋានកំណត់ពន្ធគឺជាថ្លៃដីគិតតាមថ្លៃទីផ្សារតាមទីក្រុង និងតាមតំបន់នីមួយៗដែលវាយតម្លៃទៅតាមតម្លៃគិត ក្នុងមួយម៉ែត្រក្រឡាកំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់យ៉ាងយឺតបំផុតនៅថ្ងៃទី៣០ ខែមិថុនានៃឆ្នាំប្រមូលពន្ធ។ពន្ធនេះត្រូវកំណត់តាមអត្រា២%លើមូលដ្ឋានកំណត់ពន្ធដែលបានចែងក្នុងមាត្រា៣០។ កម្មសិទ្ធិករនៃដីធ្លីជាប់ពន្ធមានភារកិច្ចត្រូវគណនាប្រាក់ពន្ធតាមគំរូលិខិតប្រកាសពន្ធនិងត្រូវបង់យ៉ាងយឺតបំផុតនៅថ្ងៃទី៣០ខែកញ្ញា នៃឆ្នាំនីមួយៗជូនទៅផ្នែកពន្ធនៅកន្លែងដែលដីធ្លីជាប់ពន្ធស្ថិតនៅដីធ្លីជាប់ពន្ធនីមួយៗត្រូវធ្វើលិខិតប្រកាស០១ច្បាប់។

## ៩.ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ

ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យត្រូវកំណត់យកលើប្រាក់ឈ្នួលដែលបានមកពីការជួល៖

- អាគារដែលសង់លើដីដូចជាៈ ផ្ទះ រោងចក្រ សណ្ឋាគារ ការិយាល័យ ។ល។
- ហេត្ថបករណ៍ដែលជាប់ជាមួយគ្រឹះស្ថានឧស្សាហកម្ម
- ឋាបនភ័ណ្ឌពាណិជ្ជកម្ម ឧស្សាហកម្ម ដែលនៅនឹងមួយកន្លែង អាគារធំៗដែលទុកដាក់ជាតុរាវ ឬផលិតផលផ្សេងៗ ដូចជា ប្រេងឥន្ធនៈ កៅស៊ូចាក់ថ្នល់ គ្រាប់ធញ្ញជាតិ
- ផ្ទះអណ្តែតទឹក កប៉ាល់សម្រាប់ធ្វើជាលំនៅដ្ឋាន ឬ ដើម្បីប្រកបអាជីវកម្មផ្សេងៗ
- ដីធ្លីដែលគ្មានសំណង់ ដោយរាប់បញ្ចូលទាំងកន្លែងយកថ្ម យករ៉ែ ធ្យូងថ្ម បឹងបួរ ស្រែអំបិល។

ពន្ធនេះត្រូវប្រមូលពីកម្មសិទ្ធិករឬសិទ្ធិវន្តរបស់កម្មសិទ្ធិករអត្រាពន្ធលើឈ្នួលផ្ទះ និងដីត្រូវបានកំណត់ស្មើនឹង ១០%នៃប្រាក់ឈ្នួលដុល គឺជាប្រាក់ឈ្នួល ដែលបានចុះកិច្ចសន្យា ឬបានព្រមព្រៀងជាមួយអ្នកជួល។ ចំណូលពន្ធដារដែលប្រមូលបានតាមអង្គភាព( គិតជាភាគរយ )៖

## តារាងទី២ៈក្រាហ្វិកពន្ធលើឈ្នួលផ្ទះ




## តារាងទី៣ៈក្រាហ្វិកចំណូលប្រចាំឆ្នាំ
## លទ្ធផលប្រមូលចំណូលពន្ធដារធៀបនិងផែនការប្រចាំឆ្នាំ(២០២១-២០២២)




| ឆ្នាំ | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 (៧ខែ) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូល (ប៊ីលានរៀល) | 2,360.05 | 2,962.13 | 3,525.48 | 4,251.16 | 5,196.80 | 5,988.71 | 7,754.81 | 8,791.40 | 11,277.32 | 11,700.52 | 11,266.79 | 13,993.20 | 9,367.44 |
| ចំណូល (លានដុល្លារ) | $590.01 | $731.39 | $870.49 | $1,049.67 | $1,283.16 | $1,478.69 | $1,914.77 | $2,197.85 | $2,819.33 | $2,889.02 | $2,781.92 | $3,455.11 | $2,312.95 |
| ផែនការ (ប៊ីលានរៀល) | 2,655.37 | 2,944.43 | 3,463.61 | 3,975.16 | 4,659.50 | 5,686.26 | 6,863.30 | 7,693.50 | 9,153.63 | 11,543.31 | 9,084.42 | 11,419.13 | 14,465.39 |
| ផែនការ (លានដុល្លារ) | $663.84 | $736.11 | $865.90 | $993.79 | $1,164.88 | $1,421.56 | $1,715.83 | $1,923.38 | $2,288.41 | $2,850.20 | $2,243.07 | $2,819.54 | $3,571.70 |
| %ភាគរយនៃចំណូល | 88.88% | 100.60% | 101.80% | 106.94% | 111.53% | 105.32% | 113.00% | 114.27% | 123.20% | 101.36% | 124.02% | 122.54% | 64.76% |

ប្រភពៈលទ្ធផលប្រមូលចំណូលពន្ធប្រចាំខែកក្កដានិងរយៈពេល៧ខែ ឆ្នាំ២០២៣ របស់អគ្គនាយកដ្ឋានពន្ធដារ

## តារាងទី៤៖ក្រាហ្វិកឆ្នាំ២០២២ ធៀបនិងឆ្នាំ២០២១
## ចំណូលពន្ធដារតាមប្រភេទអ្នកជាប់ពន្ធ ឆ្នាំ២០២២ ធៀបនិងឆ្នាំ ២០២១




| ចំណូល | អ្នកជាប់ពន្ធធំ | អ្នកជាប់ពន្ធមធ្យម | អ្នកជាប់ពន្ធតូច | ផ្សេងៗ (ពន្ធឈ្នួលផ្ទះ,ពន្ធលើអចលនទ្រព្យ និងផ្សេងៗ) |
|---|---|---|---|---|
| ឆ្នាំ២០២២ | 10,297.67 | 2,165.08 | 63.08 | 1,467.38 |
| | 73.59% | 15.47% | 0.45% | 10.49% |
| ឆ្នាំ២០២១ | 8,225.46 | 1,676.77 | 43.83 | 1,320.75 |
| | 73.01% | 14.88% | 0.39% | 11.72% |

ប្រភព÷ របាយការណ៍លទ្ធផលប្រមូលចំណូលពន្ធដារប្រចាំឆ្នាំ២០២២ របស់អគ្គនាយកដ្ឋានពន្ធដារ

## តារាងទី៥៖ក្រាហ្វិកប្រចាំឆ្នាំ២០២៣
## ចំណូលពន្ធតាមប្រភេទអ្នកជាប់ពន្ធ ប្រចាំឆ្នាំ២០២៣




| ចំណូល | អ្នកជាប់ពន្ធធំ | អ្នកជាប់ពន្ធមធ្យម | អ្នកជាប់ពន្ធតូច | ផ្សេងៗ (ពន្ធឈ្នួលផ្ទះ,ពន្ធលើអចលនទ្រព្យ និងផ្សេងៗ) |
|---|---|---|---|---|
| កក្កដា-២៣ | 707.31 | 173.08 | 6.49 | 86.88 |
| | 72.64% | 17.77% | 0.67% | 8.92% |
| កក្កដា-២២ | 682.26 | 177.66 | 4.57 | 105.64 |
| | 70.33% | 18.31% | 0.47% | 10.89% |

| ចំណូល | អ្នកជាប់ពន្ធធំ | អ្នកជាប់ពន្ធមធ្យម | អ្នកជាប់ពន្ធតូច | ផ្សេងៗ (ពន្ធឈ្នួលផ្ទះ,ពន្ធលើអចលនទ្រព្យ និងផ្សេងៗ) |
|---|---|---|---|---|
| ០៧ខែ-២៣ | 7,413.40 | 1,389.85 | 53.32 | 510.86 |
| | 79.14% | 14.84% | 0.57% | 5.45% |
| ០៧ខែ-២២ | 6,988.47 | 1,290.96 | 37.13 | 634.64 |
| | 78.07% | 14.42% | 0.41% | 7.09% |

ប្រភព៖ លទ្ធផលប្រមូលចំណូលពន្ធប្រចាំខែកក្កដានិងរយៈពេល៧ខែ ឆ្នាំ២០២៣ របស់អគ្គនាយកដ្ឋានពន្ធដារ។

## ៣.៣ នីតិវិធីនៃការប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ

### ៣.៣.១ នីតិវិធីនៃការប្រមូលចំណូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ

អ្នកជាប់ពន្ធត្រូវរៀបចំលិខិតប្រកាសពន្ធដោយខ្លួនឯងក្រោយពីរៀបចំលិខិតប្រកាសពន្ធ អ្នកជាប់ពន្ធត្រូវទៅបង់ប្រាក់ពន្ធនៅធនាគារ។នៅពេលដែលអ្នកជាប់ពន្ធទទួលបានបង្កាន់ដៃបង់ ប្រាក់ពីធនាគារ អ្នកជាប់ពន្ធត្រូវភ្ជាប់បង្កាន់ដៃបង់ប្រាក់ពន្ធជាមួយនឹងលិខិតប្រកាសពន្ធចំនួនបីច្បាប់មកកាន់ការិយាល័យលិខិតប្រកាស។ ប្រសិនបើអ្នកជាប់ពន្ធយកឯកសារមកដាក់ប្រកាស មុនថ្ងៃទី២០ (ចំពោះលិខិ ពោះលិខិតប្រកាសពន្ធប្រចាំខែ) និង មុនថ្ងៃទី៣១ ខែមីនា (ចំពោះលិខិតប្រកាស ពន្ធប្រចាំឆ្នាំ) នៅពេលដែ ពេលដែលមិនសូវមានអតិថិជនច្រើន នោះមន្ត្រីពន្ធនិងធ្វើការត្រួតពិនិត្យទៅលើ លិខិតប្រកាសពន្ធរបស់អ្នកជាប់ពន្ធថា តើទិន្នន័យនិងការគណនាប្រាក់ពន្ធរបស់អ្នកជាប់ពន្ធធ្វើការបំពេញបានត្រឹមត្រូវមត្រូវឬទេ។ បន្ទាប់មកមន្ត្រីនឹងធ្វើការបញ្ចូលព័ត៌មានទៅក្នុងប្រព័ន្ធបន្ទាប់ពី មន្ត្រីបានបញ្ចូលព័ត៌មាន មានទៅក្នុងប្រព័ន្ធរួច អ្នកជាប់ពន្ធត្រូវចាំទទួលលិខិតបញ្ជាក់ការបង់ពន្ធ។ ជាការប្រមូលពន្ធសំរាប់ថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទាក់ទងទៅនិងការប្រមូលពន្ធប្រភេទពន្ធទាំងអស់មាន១៦ប្រភេទពន្ធពីព្រោះប្រភេទពន្ធខ្លះត្រូវបានប្រមូលចំណូលដោយអគ្គនាយកដ្ឋានពន្ធដារឬទីចាត់ការអ្នកប្រមូពន្ធសម្រាប់អ្នកជាប់ពន្ធធំនិង សាខាពន្ធដារខណ្ឌ/ ខេត្តធ្វើការប្រមូលពន្ធទៅលើអ្នកជាប់ពន្ធតូច និងពន្ធមធ្យមសំរាប់សហគ្រាសរូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រកបអាជីវកម្មនៅអគ្គនាយកដ្ឋានពន្ធដារ។ ការប្រមូលពន្ធរបស់សាខាពន្ធដារខណ្ឌ/ខេត្តធ្វើការប្រព្រឹត្តទៅតាមការិយាល័យនីមួយៗ។ ប៉ុន្តែទន្ទឹមនេះនិងការប្រមូលពន្ធបានគឺពាក់ព័ន្ធជាមួយនិងធនជានមនុស្សនិងការផ្តល់សេវា ដោយធនជានមនុស្សដែលនៅក្នុងឆ្នាំ២០២២ មានចំនួនតែ ៥៥ ទៅ ៥៦ នាក់ដែលគួបផ្សំទៅនិងនីតិវិធីនៃការ ប្រមូលពន្ធរបស់ការិយាល័យនីមួយៗ។

- **ការិយាល័យសេវាអ្នកជាប់ពន្ធនិងចុះបញ្ជី**

ការិយាល័យសេវាអ្នកជាប់ពន្ធនិងចុះបញ្ជីនិងផ្តល់សេវាជូនអ្នកជាប់ពន្ធធ្វើការងារ ប្រមូលពន្ធទៅលើប្រភេទពន្ធចំនួន៤គឺពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទពន្ធ ប្រថាប់ត្រាឯកសារគតិយុត្តិ (មិនប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិទេផ្ទេរកម្មសិទ្ធិ ក៏ប្រថាប់ត្រាដែរប៉ុន្តែអគ្គនាយកដ្ឋានពន្ធដារជាអ្នកទទួលខុសត្រូវ) ពន្ធលើអចលនទ្រព្យ និង ពន្ធលើឈ្នួលផ្ទះ និងដី។

**១.នីតិវិធីនៃការចុះបញ្ជី**

ការិយាល័យសេវាអ្នកជាប់ពន្ធនិងចុះបញ្ជី ធ្វើការចុះបញ្ជីនិងផ្តល់សេវាជូនអ្នកជាប់ពន្ធប្រមូលពន្ធទៅលើប្រភេទពន្ធចំនួន ៤ គឺ ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ពន្ធប្រថាប់ត្រាឯកសារគតិយុត្តិ (មិនប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិទេផ្ទេរកម្មសិទ្ធិក៏ប្រថាប់ត្រា ដែរប៉ុន្តែអគ្គនាយកដ្ឋានពន្ធដារជាអ្នកទទួលខុសត្រូវ) ពន្ធលើអចលនទ្រព្យ និង ពន្ធលើឈ្នួលផ្ទះ និងដី។

**២.នីតិវិធីនៃការចុះបញ្ជី**

ចំពោះសហគ្រាសដែលទើបតែករកើតថ្មីសហគ្រាសនោះតម្រូវមានកាតព្វកិច្ចមកធ្វើការចុះបញ្ជីនៅការិយាល័យសេវាអ្នកជាប់ពន្ធនិងចុះបញ្ជី។

- ចំពោះអ្នកជាប់ពន្ធតូច

 * ត្រូវភ្ជាប់មកនូវជាមួយឯកសារដូចជា៖

. លិខិតបញ្ជាក់ការចុះបញ្ជីដែលចេញដោយក្រសួងពាណិជ្ជកម្ម ឬក្រសួងស្ថាប័ន ពាក់ព័ន្ធ (ប្រសិនបើមាន)

· អត្តសញ្ញាណប័ណ្ណសញ្ញាត្តិខ្មែរ ឬ លិខិតឆ្លងដែន

· រូបថតបច្ចុប្បន្នរបស់ម្ចាស់សហគ្រាស

- ចំពោះអ្នកជាប់ពន្ធមធ្យម
    - ❖ ឯកសារភ្ជាប់រួមមាន
- លិខិតបញ្ជាក់ការចុះបញ្ជីដែលចេញដោយក្រសួងពាណិជ្ជកម្ម ឬក្រសួង ស្ថាប័ន ពាក់ព័ន្ធ
- លក្ខន្តិកៈក្រុមហ៊ុន (សហគ្រាសនីតិបុគ្គល)
- លិខិតបញ្ជាក់ការតម្កល់ដើមទុនចុះបញ្ជីនៅធនាគារ
- អត្តសញ្ញាណប័ណ្ណសញ្ញាត្តិខ្មែរ ឬ លិខិតឆ្លងដែន
- សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅ
- លិខិតបញ្ជាក់ការស្នាក់នៅ ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច (សម្រាប់ ជនបរទេស)
- ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម
- លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធលើអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ
- វិញ្ញាបនបត្រចុះបញ្ជីរបស់គណៈកម្មាធិការវិនិយោគកម្ពុជា ឬគណៈកម្មាធិការ តំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ឬអនុកម្មធិការវិនិយោគរាជធានី-ខេត្ត
- អាជ្ញាប័ណ្ណដែលចេញដោយក្រសួង ស្ថាប័ន មានសមត្ថកិច្ច

* ចំពោះសហគ្រាសដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មហើយត្រូវយកឯកសារ មកដាក់ឲ្យបានមុនរយៈពេល ១៥ថ្ងៃនៃថ្ងៃធ្វើការ

- ចំពោះអ្នកជាប់ពន្ធធំ
    - ❖ ឯកសារភ្ជាប់រួមមាន
- លិខិតបញ្ជាក់ការចុះបញ្ជីដែលចេញដោយក្រសួងពាណិជ្ជកម្ម ឬក្រសួង ស្ថាប័ន ពាក់ព័ន្ធ
- លក្ខន្តិកៈក្រុមហ៊ុន (សហគ្រាសនីតិបុគ្គល)
- លិខិតបញ្ជាក់ការតម្កល់ដើមទុនចុះបញ្ជីនៅធនាគារ
- អត្តសញ្ញាណប័ណ្ណសញ្ញាត្តិខ្មែរ ឬ លិខិតឆ្លងដែន
- សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅ
- លិខិតបញ្ជាក់ការស្នាក់នៅ ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច (សម្រាប់ ជនបរទេស)
- ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម
- លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធលើអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ

- វិញ្ញាបនបត្រចុះបញ្ជីរបស់គណៈកម្មាធិការវិនិយោគកម្ពុជា ឬគណៈកម្មាធិការ តំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ឬអនុកម្មធិការវិនិយោគរាជធានី-ខេត្ត
- អាជ្ញាប័ណ្ណដែលចេញដោយក្រសួងស្ថាប័នមានសមត្ថកិច្ច

* ចំពោះសហគ្រាសដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មហើយត្រូវយកឯកសារ មកដាក់ឱ្យបានមុនរយៈពេល ១៥ថ្ងៃនៃថ្ងៃធ្វើការ

**តារាងទី៦៖ ដំណើរនៃការចុះបញ្ជីរបស់សហគ្រាស**

| |
|---|
| ចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម |
| ↓ |
| ឯកសារភ្ជាប់ |
| ↓ |
| ចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារ |
| ↓ |
| បង់ប្រាក់ពន្ធ |
| ↓ |
| បង្កាន់ដៃបង់ប្រាក់ពន្ធ |

**៣.៣.២ តួនាទីនៃការប្រមូលពន្ធ**

❖ ការិយាល័យរដ្ឋបាល

ការិយាល័យរដ្ឋបាលមានភារកិច្ចដូចតទៅ៖

- ➢ រៀបចំផែនការយុទ្ធសាស្ត្រ និងគោលដៅនានាពាក់ព័ន្ធ សវនកម្មពន្ធដាររបស់អគ្គនាយកដ្ឋានពន្ធដារ
- ➢ ស្រាវជ្រាវនិងកំណត់ហានិភ័យតាមវិស័យនិងតាមអ្នកជាប់ពន្ធនីមួយៗដើម្បីរៀបចំកម្មវិធីសវនកម្ម
- ➢ រៀបចំកម្មវិធីសវនកម្មរបស់សាខាពន្ធដារប្រចាំត្រីមាសប្រចាំត្រីមាសនិងប្រចាំឆ្នាំដោយផ្អែកលើការកំណត់ហានិភ័យ
- ➢ តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីសវនកម្ម
- ➢ ថែរក្សាសំណុំឯកសារមន្ត្រីពន្ធដាររបស់ពន្ធដារ
- ➢ ពិនិត្យ និងតាមដានការប្រតិបត្តិការងាររបស់មន្ត្រីពន្ធដារ
- ➢ រៀបចំសំណើរជូនថ្នាក់ដឹកនាំស្តីពីការជ្រើសរើស តែងតាំង ផ្លាស់ប្តូរ និងលើកទឹកចិត្តដល់ មន្ត្រីក្នុង ពន្ធដារ
- ➢ រៀបចំផែនការ និងលើកសំណើរបណ្តុះបណ្តាលឬអភិវឌ្ឍសមត្ថភាពមន្ត្រីក្នុងពន្ធដារ
- ➢ គ្រប់គ្រងនិងសម្របសម្រួលការងាររដ្ឋបាលរបស់ពន្ធដារ
- ➢ គ្រប់គ្រង និងបែងចែកឯកសារលិខិតស្នាមចេញ ចូលរបស់ពន្ធដារ
- ➢ គ្រប់គ្រង ថែរក្សាការពារនិងស្នើសុំជួសជុលសម្ភារៈបរិក្ខារការិយាល័យរបស់ពន្ធដារ
- ➢ ស្នើសុំ និងបើកផ្តល់ថវិការសម្រាប់ផ្គត់ផ្គង់រាល់មធ្យោបាយ និងសម្ភារៈបរិក្ខារចាំបាច់

- សម្រាប់បំពេញការងារដល់គ្រប់ការិយាល័យរបស់ពន្ធដារ
- រៀបចំគម្រោងចំណាយ និងសម្ភារៈបរិក្ខារសម្រាប់សំណើរការការងាររបស់ពន្ធដារ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស និង ឆ្នាំ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់ពន្ធដារ។

❖ ការិយាល័យសេវាអ្នកជាប់ពន្ធ

- អនុវត្តយន្តការផ្តល់សេវាដល់អ្នកជាប់ពន្ធ ប្រកបដោយគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព
- ផ្តល់សេវាពាក់ព័ន្ធកាតូកិច្ចពន្ធដារ ជូនអ្នកជាប់ពន្ធជាអាទិ៍ ការផ្តល់ប្រឹក្សា និងការផ្តល់ ព័ត៌មាន និងឯកសារពាក់ព័ន្ធនឹងពន្ធដារ
- សហការរៀបចំសិក្ខាសាលា ការបណ្តុះបណ្តាល និងផ្សព្វផ្សាយជូនអ្នកជាប់ពន្ធ អំពីបទ ប្បញ្ញត្តិស្តីពីពន្ធដារ
- រៀបចំក្រុមពិភាក្សាជាមួយអ្នកជាប់ពន្ធតាមវិស័យសំខាន់ៗ ដើម្បីទទួលបាននូវសំណូម ពរនិងសេចក្តីត្រូវការរបស់អ្នកជាប់ពន្ធ
- ចុះបញ្ជីអ្នកជាប់ពន្ធ ចេញប័ណ្ណប៉ាតង់ កាន់កាប់ថែរក្សាបញ្ជីអ្នកជាប់ពន្ធ ចុះបញ្ជីពន្ធ អចលនទ្រព្យ និងចេញវិញ្ញានបត្រចុះបញ្ជីតាមប្រភេទពន្ធនានា ដែលតម្រូវដោយច្បាប់ និងកត់ត្រាទន្នន័យបច្ចុប្បន្នភាពអ្នកជាប់ពន្ធក្នុងប្រព័ន្ធកុំព្យូទ័រ
- បញ្ចូលទិន្នន័យរបស់អ្នកជាប់ពន្ធ ទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ
- រៀបចំស្ថិតិអ្នកជាប់ពន្ធ និងវាស់ស្ទង់មតិអ្នកជាប់ពន្ធទាក់ទិននឹងគុណភាពសេវាដែល បានផ្តល់ឱ្យ
- ទទួលបន្ទុកក្នុងការប្រមូលពន្ធ មានជាអាទិ៍ ពន្ធប្រថាប់ត្រាលើកិច្ចសន្យាផ្គត់ផ្គង់ទំនិញឬ សេវាដែលប្រើប្រាស់ថវិការរដ្ឋនិងលើការផ្ទេរភាគហ៊ុនពាក់ព័ន្ធអ្នកជាប់ពន្ធតូចនិងមធ្យម ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទពន្ធលើអចលនទ្រព្យពន្ធលើ ឈ្នួលផ្ទះនិងដី និងពន្ធតែមប្រើដោយឡែកចំពោះសាខាពន្ធដារខេត្តត្រូវបានបន្ថែមភារកិច្ចឱ្យប្រមូលពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធ ឬសិទ្ធកាន់កាប់អចលនទ្រព្យនិង អចលនទ្រព្យ និងពន្ធលើដីធ្លីមិនបានប្រើប្រាស់
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស និង ឆ្នាំ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់ពន្ធដារ

❖ ការិយាល័យចាត់ចែងលិខិតប្រកាស

ការិយាល័យចាត់ចែងលិខិតប្រកាសមានភារកិច្ចដូចតទៅ

- រៀបចំ និងអនុវត្តទទួលលិខិតប្រកាសសារពើពន្ធឱ្យមានប្រសិទ្ធភាព
- ទទួល និងពិនិត្យផ្ទៀងផ្ទាត់លិខិតប្រកាសសារពើពន្ធពីអ្នកជាប់ពន្ធ ដើម្បីធានាថាលិខិត
- ប្រកាសសារពើពន្ធត្រូវបានបំពេញគ្រប់ខ្ទង់ គ្រប់និទ្ទេស និងគណនាបានត្រឹមត្រូវ
- រៀបចំ និងរក្សាទុកសំណុំឯកសារលិខិតប្រកាសសារពើពន្ធរបស់អ្នកជាប់ពន្ធនិងផ្តល់ សំណុំឯកសារនេះឱ្យអង្គភាពពាក់ព័ន្ធពិនិត្យលើភាពមិនប្រក្រតីនៃលិខិតប្រកាសសារពើពន្ធដើម្បីធ្វើសវនកម្មឬលើកសំណើរ ធ្វើសវនកម្ម
- ផ្ទៀងផ្ទាត់ការបង់ប្រាក់ពន្ធជាមួយនឹងប្រកាសឥណទានប្រកាសឥណទាននិងរបាយការណ៍សមតុល្យគណនីដែលទទួលបានពីធនាគារ

- បញ្ចូលទិន្នន័យនៃការប្រមូលចំណូលសារពើពន្ធទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យដើម្បីធ្វើ គណនេយ្យកម្មចំណូលសារពើពន្ធ ដោយរៀបចំនិងផ្ញើសលាកបត្របង់ប្រាក់ចូលថវិកា
- រៀបចំបញ្ជីឈ្មោះអ្នកជាប់ពន្ធ ដែលស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែមដាក់លិខិតប្រកាសយឺតយ៉ាវ ឬដាក់លិខិតប្រកាសដោយពុំបង់ប្រាក់ពន្ធ និងមិនដាក់លិខិតប្រកាសពន្ធ ដើម្បីអនុវត្តតាមមុខងារ
- រដ្ឋ និងរបាយការណ៍ពាក់ព័ន្ធចំណូលសារពើពន្ធជូនអគ្គនាយកនៃអគ្គ នាយកដ្ឋានពន្ធដារ
- ធ្វើចំណាត់ថ្នាក់និងការវាយតម្លៃឥរិយាបថរបស់អ្នកជាប់ពន្ធ ដើម្បីផ្តល់សៅអប់រំអំពីបទ ប្បញ្ញត្តិស្តីពីពន្ធដារឬអនុវត្តវិធានការចាប់បង្ខំ ឬស្នើសុំការផ្តល់ការលើកទឹកចិត្តចំពោះអ្នក ជាប់ពន្ធដែលគោរពច្បាប់បានល្អ
- កំណត់មុខសញ្ញាអ្នកជាប់ពន្ធ ដើម្បីអនុវត្តនីតិវិធីលុបចេញពីបញ្ជី ឬដកវិញ្ញាបនបត្រអាករ លើតម្លៃបន្ថែម
- ធ្វើរបារការណ៍ស្តីពីសកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនប្រធានសាខា
- បំពេញភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់ពន្ធដារ។

❖ ការិយាល័យសវនកម្មពន្ធ

ការិយាល័យសវនកម្មពន្ធមានភារកិច្ចដូចតទៅ

- អនុវត្តផែនការយុទ្ធសាស្ត្រ និងគោលដៅនានាពាក់ព័ន្ធសវនកម្មពន្ធដារ
- ចូលរួមរៀបចំ និងអនុវត្តកម្មវិធីសវនកម្មលើឯកសារនិងសវនកម្មមានកម្រិត ដើម្បីឱ្យអ្នក
- ជាប់ពន្ធគោរពប្រតិបត្តិតាមច្បាប់ស្តីពីសារពើពន្ធ
- រៀបចំផែនការសវនកម្មលើសំណុំឯកសារនីមួយៗ និងពិនិត្យសំណុំឯកសារឡើងវិញ
- ដើម្បីរកឱ្យឃើញនូវហានិភ័យដែលពាក់ព័ន្ធនឹងសំណុំឯកសារទាំងនោះធ្វើសវនកម្មលើឯកសារ និងសវនកម្មមានកម្រិតលើអ្នកជាប់ពន្ធឱ្យបានទាន់ពេលវេលា
- ប្រកបដោយប្រសិទ្ធិភាពស្របតាមផែនការយុទ្ធសាស្ត្ររបស់អគ្គនាយកដ្ឋានពន្ធដារនិងដោយអនុលោមតាមនីតិវិធីសវនកម្មជាធរមាន
- ជូនដំណឹងលម្អិតដល់អ្នកជាប់ពន្ធស្តីពីលទ្ធផល ឬការផ្លាស់ប្តូរលទ្ធផលសវនកម្ម
- ធ្វើរបាយការណ៍បញ្ចប់លទ្ធផលសវនកម្មលើអ្នកជាប់ពន្ធនីមួយៗ និងបញ្ចូលសំណុំឯក
- សារសវនកម្មទៅក្រុមពិនិត្យការងារសវនកម្មឡើងវិញ ដែលក្រុមនេះមានភារកិច្ចពិនិត្យ ឡើងវិញរាល់ការងារសវនកម្ម ដើម្បីធានានូវអនុលោមភាពជាមួយនីតិវិធីសវនកម្មនិងផែនការយុទ្ធសាស្ត្រ និងសុក្រឹតភាពនៃការកំណត់ពន្ធឡើងវិញព្រមទាំងវាយតម្លៃលទ្ធផលការងាររបស់មន្ត្រីសវនកម្មនិងរៀបចំតម្រូវការបណ្តុះបណ្តាលមន្ត្រីសវនកម្មផ្តល់លទ្ធផលនៃការកំណត់ពន្ធឡើងវិញ ឬការកំណត់ពន្ធដាឯកតោភាគីចំពោះអ្នកជាប់ពន្ធទៅការិយាល័យចាត់ចែងលិខិតប្រាកាសនិងការិយាល័យបំណុល
- គ្រប់គ្រងព័ត៌មាន តាមដាន និងត្រួតពិនិត្យការងាររបស់មន្ត្រីសវនកម្មនីមួយៗ
- កំណត់បញ្ហាដើម្បីកែលម្អយុទ្ធសាស្ត្រផែនការកម្មវិធីសបនកម្មនិងនីតិវិធីនៃការជ្រើសរើសអ្នកជាប់ពន្ធ
- កំណត់បញ្ហាប្រឈមក្នុងការធ្វើសវនកម្ម ដើម្បីរកដំណោះស្រាយឱ្យបានទាន់ពេល
- កំណត់តម្រូវការបណ្តុះបណ្តាល ដើម្បីអភិវឌ្ឍសមត្ថភាពជំនាញរបស់មន្ត្រីសវនកម្ម
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ

- បំពេញភារកិច្ចផ្សេងៗទៀតតាមការកំណត់ពន្ធដារ។

❖ ការិយាល័យបំណុល

ការិយាល័យបំណុលពន្ធមាភារកិច្ចដូចតទៅ

- អនុវត្តផែនការយុទ្ធសាស្ត្រពាក់ពន្ធនឹងការប្រមូលបំណុលពន្ធ
- អនុវត្តវិធានការទារបំណុលពន្ធ អនុលោមតាមបទប្បញ្ញត្តិជាធរមាន
- រៀបចំបញ្ជីឈ្មោះអ្នកជំពាក់បំណុលពន្ធ តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យ ដោយមានការ
- ផ្ទៀងផ្ទាត់ជាមួយការិយាល័យចាត់ចែងលិខិតប្រកាស និងការិយាល័យសវនកម្មពាក់ព័ន្ធរៀបចំសំណុំឯកសាររបស់អ្នកជាប់ពន្ធដែលជំពាក់បំណុលពន្ធ និងបញ្ជូនមកនាយកដ្ឋាន គ្រប់គ្រងសាខាពន្ធដារខេត្ត -ខណ្ឌ
- រៀបចំ និងអនុវត្តផែនការសកម្មភាពប្រមូលបំណុលពន្ធ និងដាក់ចេញនូវវិធានការប្រមូល បំណុលពន្ធប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- រៀបចំ និងផ្ញើលិខិតទារបំណុលពន្ធ និងលិខិតរំលឹកការទារបំណុលទៅឱ្យអ្នកជាប់ពន្ធ អនុលោមតាមបទប្បញ្ញត្តិជាធរមាន
- ជ្រើសរើសអ្នកជំពាក់បំណុលពន្ធដើម្បីអនុវត្តបិធានការទារបំណុលពន្ធដោយផ្អែកលើហា
- ហានិភ័យការប្រមូលពត៌មានពី អ្នកជំពាក់បំណុលពន្ធតាមរយៈអ្នកជំពាក់បំណុលពន្ធផ្ទាល់និងតាមមធ្យោបាយផ្សេងៗ
- ពិនិត្យ និងតាមដានវឌ្ឍនភាពនៃស្ថានភាពបំណុលពន្ធរបស់អ្នកជំពាក់បំណុលពន្ធនិង សំណុំឯកសាររបស់អ្នកជំពាក់បំណុលពន្ធ ដើម្បីជាមូលដ្ឋានក្នុងការចាត់វិធានការទារ
- បំណុលពន្ធ ចុះជួប និងជូនដំណឹងដល់អ្នកជាប់បំណុលពន្ធអំពីវិធានការទារបំណុលពន្ធដែលនឹងត្រូវអនុវត្ត
- កត់ត្រានិងតាមដានការវិវឌ្ឍនៃការអនុវត្តវិធានការទារបំណុលពន្ធនិងរក្សាទុកក្នុងសំណុំឯកសាររបស់អ្នកជំពាក់បំណុលពន្ធ
- ស្វែងរកនិងទទួលព័ត៌មានហិរញ្ញវត្ថុថ្មីៗពីអង្គភាពពាក់ព័ន្ធនានា អ្នកជាប់ពន្ធនិងតតិយជនដើម្បីវិភាគអំពីលទ្ធភាពរបស់អ្នកជាប់ពន្ធក្នុងការទូទាត់បំណុលពន្ធ
- រៀបចំលិខិតសម្រាប់ផ្ញើជូនក្រសួងស្ថាប័នរដ្ឋនិង ឯកជនដែលពាក់ពន្ធដើម្បីស្នើសុំកិច្ចសហការក្នុងការអនុវត្តវិធានការតឹងទារបំណុលពន្ធ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស និង ឆ្នាំជូនប្រធានសាខា
- បំពេញភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់ប្រធានសាខាពន្ធដារ។

**តារាងទី៧៖ និតិវិធីនៃការប្រមូលពន្ធ**

អ្នកជាប់ពន្ធគណនាបង់ប្រាក់ពន្ធ និងរៀបចំ
លិខិតប្រកាសពន្ធដោយខ្លួនឯង

↓

បង់ប្រាក់ពន្ធនៅធនាគារ

↓

ដាក់នៅការិយាល័យចាត់ចែងលិខិតប្រកាស
យកលិខិតប្រកាសបន្ទ និងឯកសារភ្ជាប់ទៅ

↓

មន្ត្រីពន្ធត្រួតពិនិត្យលិខិតប្រកាសពន្ធនិង
បញ្ជូនព័ត៌មាន

↓

ទទួលលិខិតបញ្ជាក់ការបង់ប្រាក់ពន្ធពី
មន្ត្រីពន្ធដារ

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ ទៅលើចំណូលពីការប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ រួចមកនាងខ្ញុំបានរកឃើញនូវចំណុចខ្លាំង និងចំណុចខ្សោយ មួយចំនួនដូចជា៖

## ៤.១ ការវិភាគលើចំណុចខ្លាំង

- យល់ដឹងបន្ថែមពីដើមហេតុនិងហេតុផលនៃការប្រមូលចំណូលពន្ធដារសម្រាប់កសាងប្រទេសជាតិកាន់តែរីកចំរើន
- មានច្បាប់ បទបញ្ញត្តិ បទដ្ឋានគតិយុត្តិគ្រប់គ្រាន់ដោះស្រាយបញ្ហាពេលកើតមានឡើង
- មានចែងពីសិទ្ធិអំណាចនិងការរបស់រដ្ឋបាលសារពើពន្ធបង្ហាញ ឱ្យយើងឃើញនៃការប្រមូលពន្ធដារពិតជាអនុវត្តន៍ស្របទៅតាមច្បាប់ជាអ្នកកំណត់
- ស្គាល់ពីឧបសម្ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធអគ្គនាយកដ្ឋានពន្ធដារ មានការកើនឡើងជាលំដាប់
- ប្រសិទ្ធិភាពនៃការប្រមូលចំណូលពន្ធ មានការរីក ចម្រើននៃជីវភាពរបស់ប្រជាជន
- យល់ដឹងអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋ ក៏ដូចជា សហគ្រាសផងដែរ
- យល់ដឹងអំពីប្រភេទពន្ធនៅកម្ពុជាដែលជាប្រភពនៃការប្រមូលចំណូលពន្ធដារការចូលរួមការកសាងប្រទេសជាតិបានល្អប្រសើរជានេះទៅទៀត
- ដឹងថាចំណូលដែលពន្ធដារប្រមូលបាន បានចូលរួមអភិវឌ្ឍប្រទេសជាតិលើវិស័យអ្វីខ្លះ

យោងតាមការសិក្សាកន្លងមកនាងខ្ញុំសង្កេតឃើញថាការប្រមូលចំណូលពន្ធដារ នៅអគ្គនាយកដ្ឋានពន្ធដារ មានការកើនឡើងជាលំដាប់ដោយសារតែមូលហេតុមួយចំនួនដូចជា ការកើនឡើងនៃចំនួនអ្នកជាប់ពន្ធ ការពង្រឹងការអនុវត្តវិធានការប្រមូលពន្ធប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពការរីក ចម្រើននៃជីវភាពរបស់ប្រជាជនដែលធ្វើការប្រើប្រាស់មានការកើនឡើង។ ទោះបីជានៅឆ្នាំ២០២១ ធៀបនឹងឆ្នាំ២០២២ ចំនួននៃអ្នកជាប់ពន្ធមានការថយចុះក៏ពិតមែនប៉ុន្តែមើលចំនួនទឹកប្រាក់ពន្ធដែល ត្រូវប្រមូលបាននៅតែមានការកើនឡើងជាលំដាប់ដែលនេះបង្ហាញឱ្យយើងឃើញថាវិធានការនៃការប្រមូលពន្ធពិតជា មានប្រសិទ្ធភាពមួយវិញទៀតជីវភាពរបស់ប្រជាជនក៏មានការកើនឡើងផងដែរដែលមានGDPរហូតដល់ទៅ១.១៦៣,១៩ USD នៅឆ្នាំ២០២២ នេះបើតាម World Bank national accounts data, and OECD National Accounts data files។ អ្វីដែលសំខាន់នោះយើងឃើញថាចំនួនអ្នកជាប់ពន្ធដែលធ្វើការបង់ប្រាក់ពន្ធជូនរដ្ឋមានចំនួនច្រើនដែលអាចបញ្ជាក់ថាអ្នកជាប់ពន្ធមានការយល់ដឹងច្រើនពីកាតព្វកិច្ចរបស់ខ្លួនក្នុងការចូលរួមការសាងប្រទេសជាតិបានល្អ។ ទាំងនេះក៏ដោយសារការយល់ដឹងច្រើនពីកាតព្វកិច្ច របស់ខ្លួនក្នុងការចូលរួមកសាងប្រទេសជាតិទាំងនេះក៏ដោយសារការខិតខំប្រឹងប្រែង របស់ថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋាន ដែលតែងតែបង្កើតនូវសិក្ខា សាលាណែនាំ ដល់អ្នកជាប់ពន្ធឱ្យយល់ដឹងពីកាតព្វកិច្ច និងសិទ្ធិរបស់ពួកគេចំពោះរដ្ឋក៏ដូចជាចំណេះដឹងទាក់ទងនឹងពន្ធដារ ដើម្បីធ្វើការបង់ប្រាក់និងដាក់លិខិតប្រកាសពន្ធឱ្យបានត្រឹមត្រូវ។ ម្យ៉ាងវិញទៀតសមិទ្ធិផលនេះក៏ដោយសារតែយុទ្ធសាស្ត្ររបស់អគ្គនាយកដ្ឋានពន្ធដារក្នុងការផ្ដល់ជាការបង្រៀនបន្ថែមដល់មន្ត្រីពន្ធ ក្នុងការផ្ដល់សេវាកម្មពន្ធដារ និងការផ្ដល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធ

តាមរយៈការធ្វើកំណែទម្រង់ពាក់ព័ន្ធនឹងការធ្វើទំនើបកម្មបច្ចេទេសវិទ្យាររួមមានការបង្ហោះច្បាប់អនុក្រឹត្យប្រកាសនិងពត៌មានផ្សេងៗទាក់ទងនឹងពន្ធដារនៅលើគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារធ្វើ ការចុះបញ្ជីនិងប្រកាសបង់ប្រាក់ពន្ធតាមOnline ជាដើម។

## ៤ ២.ការវិភាគលើចំណុចខ្សោយ

ទន្ទឹងនឹងរកឃើញនូវចំណុចខ្លាំងមួយចំនួនខាងលើនាងខ្ញុំក៏អាចរកឃើញនូវចំណុចខ្សោយមួយចំនួនផងដែរ ដែលបានរាំងដល់ការធ្វើសវនកម្មរបស់អគ្គនាយកដ្ឋានពន្ធដារ។ ចំណុចខ្សោយទាំងនោះគឺមានដូចខាងក្រោម៖

- ប្រព័ន្ធនៃការគ្រប់គ្រងការប្រមូលពន្ធនៅមានកំរិតនៅឡើយដូចជា ការប្រមូលពន្ធលើអចលនទ្រព្យមិនបានអនុវត្តជាទូទៅក្នុងប្រទេសនៅឡើយ
- ការយល់ដឹង និងការគោរពច្បាប់ស្តីពីសារពើពន្ធនៅមានកម្រិត
- ដោយសារប្រទេសយើងជាប្រទេសកំពុងអភិវឌ្ឍន៍ យើងនូវមិនទាន់អាចពង្រីកមូលដ្ឋាននៃប្រភេទហើយពន្ធមួយចំនួនត្រូវបានលប់បំបាត់ដូចជាពន្ធលើទោចក្រយានុយន្តនិងពន្ធសត្តឃាដ
- អ្នកជាប់ពន្ធពុំទាន់យល់ច្បាស់ពីសារៈសំខាន់ក្នុងការបង់ពន្ធ
- ចំនួនមន្ត្រីពន្ធដារមានតិចក្នុងការប្រមូលចំណូលពន្ធ។

ទន្ទឹមនឹងការទទួលបានជោគជ័យក្នុងការសម្រេចផែនការក៏ពិតមែន ប៉ុន្តែយើងសង្កេតឃើញថាអគ្គនាយកដ្ឋានពន្ធដារនៅមានចំណុចខ្វះខាតមួយចំនួនផងដែរ។ ជាក់ស្តែងយើងសង្កេតឃើញថាការប្រមូលចំណូលពន្ធរបស់អគ្គនាយកដ្ឋានដារនៅមិនទាន់អស់លទ្ធភាពនៅឡើយ មានអាជីវកម្មដ្ឋានមួយចំនួននៅមិនបានចុះបញ្ជីត្រឹមត្រូវ។ម្យ៉ាងទៀតការផ្តល់សេវាជូនអ្នកជាប់ពន្ធនៅមានភាពខ្វះចន្លោះនៅឡើយមន្ត្រីផ្តល់សេវាមួយចំនួនពុំមានសីលធម៌វិជ្ជាជីវគ្រប់គ្រាន់ទន្ទឹមនឹងនេះ ភាពវិជ្ជមានដែលលើកឡើងខាងលើតាមរយៈការសិក្សាស្រាវជ្រាវរបស់នាងខ្ញុំក៏មើលឃើញពីកង្វះខាតមួយចំនួនដែលតម្រូវឱ្យមានការយកចិត្ត ទុកដាក់បន្ថែមដើម្បីឱ្យការប្រមូលចំណូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារកាន់តែប្រសើរ ឡើងដូចជាកង្វះមន្ត្រីពន្ធដារក្នុងការផ្តល់សេវាដល់អ្នកជាប់ពន្ធជាពិសេសនៅពេលដែលចំនួនអ្នកមកប្រកាសពន្ធមានចំនួនច្រើនពួកគេត្រូវចាំរយៈពេលយូហើយមន្ត្រីទទួលលិខិតប្រកាសមិនមានពេលភ្លាមៗ ក្នុងការបញ្ចូលទិន្នន័យនៅក្នុងលិខិតប្រកាសទៅក្នុងប្រព័ន្ធកត់ត្រាផ្ទៃក្នុងរបស់ពន្ធដារដែលធ្វើឱ្យពួកគាត់មិនអាចដឹងភ្លាមៗ ថាការគណនាពន្ធរបស់អ្នកជាប់ពន្ធត្រឹមត្រូវដែរឬទេហើយបើមានកំហុសឆ្គងក្នុងការគណនាក្រោយពេលមន្ត្រីពន្ធបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធកត់ត្រាផ្ទៃក្នុងហើយទើបដឹងហើយមន្ត្រីពន្ធធ្វើការជូនដំណឹង ឱ្យអ្នកជាប់ពន្ធមកធ្វើការកែតម្រូវដែលធ្វើឱ្យអ្នកជាប់ពន្ធត្រូវចំណាយពេលច្រើនក្នុងដំណើរការដាក់លិខិតប្រកាសមួយឱ្យបានត្រឹមត្រូវ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

ក្រោយពីការធ្វើកិច្ចការស្រាវជ្រាវយើងពិនិត្យឃើញថាចំណូលពន្ធដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានមានការកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ។ សម្រាប់ប្រទេសកម្ពុជាដែលជាប្រទេសកំពុងអភិវឌ្ឍន៍ ចំណូលពន្ធគឺជាសសរគ្រឹះដ៏រឹងមាំដើម្បីទ្រទ្រង់សេដ្ឋកិច្ចជាតិ និងដើម្បីអភិវឌ្ឍន៍ប្រទេសអោយមានភាពជឿនលឿន និងកាន់តែសំបូរបែបថែមទៀត។ ដូច្នេះការជំរុញការបង់ពន្ធនៅតែជាកត្តាចម្បងសម្រាប់រាជរដ្ឋាភិបាល ដើម្បីសម្រេចបានតាមផែនការដែលបានដាក់ចេញ។

ឆ្លងកាត់តាមការស្រាវជ្រាវមួយនេះថ្វីត្បិតតែមិនបានក្បោះក្បាយក៏ ដោយតែក៏អាចបង្ហាញឱ្យយើងដឹងថាចំណូលពន្ធដារបានដើរតួយ៉ាងសំខាន់ដល់ថវិការដ្ឋក្នុងការអភិវឌ្ឍជាតិ។ ឆ្លងតាមលទ្ធផលស្រាវជ្រាវការវិភាគចំនុចខ្លាំង និងចំនុចខ្សោយខាងលើ ឃើញថាអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានការកែទម្រង់យ៉ាងខ្លាំងជាលទ្ធផលក្នុងរយៈពេល៦ឆ្នាំជាប់ៗ គ្នាចុងក្រោយនេះអគ្គនាយកដ្ឋានពន្ធដារបានប្រមូលចំណូលពន្ធអាករ សម្រេចបានលើសផែនការ ដែលកំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ រហូតដល់មានឆ្នាំខ្លះ ទទួលបានសន្ទុស្សន៍កំណើន៣ខ្ទង់។ ជាក់ស្តែង នៅឆ្នាំ២០២១ ការប្រមូលពន្ធ អាករសម្រេចបានលើសផែនការប្រចាំឆ្នាំ៧៣.០១%និងបន្តលើសផែនការជាបន្តបន្ទាប់ដែលក្នុងឆ្នាំ ២០២១ និង២០២២ សម្រេចបានលើសផែនការប្រមាណ ៣៥% ហើយក្នុងឆ្នាំ២០២៣ មានការកើនឡើងបន្ថែមទៀតហូតដល់៤២,២%។ សមិទ្ធផលទាំងនេះកើតចេញពីការចូលរួមយ៉ាងសកម្មរបស់មន្ត្រីពន្ធដារទាំងអស់ក្រោមការគាំទ្រយ៉ាងពេញ ទំហឹងនិងការណែនាំចង្អុលបង្ហាញពីថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ក្នុងការតម្រង់ទិសដៅលើកិច្ចការងារប្រមូលចំណូលពន្ធ។ សន្ទុស្សន៍និងនិរន្តរភាពនៃការប្រមូលចំណូលពន្ធឱ្យស្របតាមការកើនឡើងឥតឈប់ឈរនៃតម្រូវការថវិកាជាតិសម្រាប់បន្តអភិវឌ្ឍន៍ប្រទេសនិងឆ្លើយតបទៅនឹងការកើនឡើងនៃបញ្ហាប្រឈមថ្មីៗដែលកើតចេញពីការវិវឌ្ឍន៍បរិយាកាសធុរកិច្ច ជាតិនិងអន្តរជាតិ អគ្គនាយកដ្ឋានពន្ធដារត្រូវតែបង្កើនការយកចិត្តទុកដាក់ និងខិតខំពុះពារបន្ថែមទៀត ក្នុងការដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពខ្ពស់ក្នុងការផ្តល់សេវាប្រកបដោយគុណភាពដល់អ្នកជាប់ពន្ធនិងបង្ការការពារនិងដោះស្រាយនូវរាល់បញ្ហាប្រឈមដូចជាហានិភ័យនានាដែលអាចជះឥទ្ធិពលអវិជ្ជមានដល់ការប្រមូលចំណូលពន្ធស្របតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ ព្រមទាំងវិវឌ្ឍន៍ខ្លួនជារដ្ឋបាលសារពើពន្ធដែលប្រមូលចំណូលតាមរយៈ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានយោងតាមការសិក្សាកន្លងមកនាងខ្ញុំសង្កេតឃើញថាការប្រមូលចំណូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារមានការកើនឡើងជាលំដាប់ដោយសារចំនួនអ្នកជាប់ពន្ធមានការពង្រឹងការអនុវត្តវិធានការប្រមូលចំណូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារប្រកបដោយតម្លាភាព និងប្រសិទ្ធភាពការរីកចម្រើននៃការមើលទៅលើជីវភាពរបស់ប្រជាជនដែលធ្វើការប្រើប្រាស់មានការកើនឡើង។ទោះបីជានៅឆ្នាំ ២០២១ ធៀបនឹង ២០២២ ចំនួននៃអ្នកជាប់ពន្ធមានការកើនចុះក៏ពិតមែនប៉ុន្តែចំនួនប្រាក់ពន្ធដែលប្រមូលបាននៅតែមានឆ្នាំការកើនឡើងជាលំដាប់ដែលនេះអាចបង្ហាញ ឱ្យយើងឃើញថាវិធានការនៃការប្រមូលពន្ធពិតជាមានប្រសិទ្ធភាព។ នីតិវិធីនៃការប្រមូល

ចំណូលពន្ធតាមការបង់ពន្ធមានលក្ខណៈស្មុគស្មាញខ្លាំងភាពវិជ្ជមាននៃកំណើតប្រាក់ពន្ធ កំណើននៃការប្រើប្រាស់កំណើននៃការផលិតការខិតខំប្រឹងប្រែងនិងគោរពច្បាប់របស់ភាគី ដែលពាក់ព័ន្ធដែលមានភាពប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ តាមរយៈ ការវិភាគនូវលទ្ធផលជាគំរូរបស់អគ្គនាយកដ្ឋានពន្ធដារខាងលើនិងកត្តាផ្សេងៗ ទៀតដែលជះឥទ្ធិពលដល់បម្រែបម្រួលភាគីដែលពាក់ព័ន្ធដែលមានភាពប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំតាមរយៈ ការវិភាគ នឹងក្លាយជាផ្នែកមួយដ៏សំខាន់ដែលជំរុញឱ្យសេដ្ឋកិច្ចប្រទេសកម្ពុជាមានការអភិវឌ្ឍន៍ដោយសារតែរាជរដ្ឋាភិបាលអាចមាននូវថវិកាគ្រប់គ្រាន់ដើម្បីទ្រទ្រង់ដល់ការចំណាយផ្សេងៗនៅក្នុងប្រទេស។

## ៥.២ ការផ្តល់អនុសាសន៍

ដោយយោងតាមការបកស្រាយខាងលើនិងការស្រាវជ្រាវមកឃើញថាអគ្គនាយកដ្ឋានពន្ធដារបានដើរតាមគោលនយោបាយរាជរដ្ឋាភិបាលបានយ៉ាងប្រសើរជាពិសេសគឺការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវយុទ្ធសាស្ត្រកៀរគរចំណូលយ៉ាងមានប្រសិទ្ធភាពទាំងតាមរយៈ ការបង្រៀបចំណេះដឹងនិងផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធ តាមរយៈការវិវត្តនូវបច្ចេកវិជ្ជាថ្មីភ្ជាប់នៅលើគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ។ នាងខ្ញុំសូមគាំទ្រនិងលើកទឹកចិត្តដល់មន្ត្រីខាងអគ្គនាយកដ្ឋានពន្ធដារ ក្នុងការបន្តនូវបេសកកម្មរបស់ខ្លួនក្នុងការអភិវឌ្ឍន៍

បច្ចេកវិទ្យា និងពង្រឹងនីតិវិធីឱ្យកាន់តែមានភាពប្រសើរឡើងថែមទៀត។មួយវិញទៀតយើងសង្កេតឃើញថាដំណើរការនៃការបង់ពន្ធនៅតែមានភាពយឺតយ៉ាវនៅឡើយដោយសារតែប្រតិបត្តិការនៃ ការបង់ពន្ធនៅមានភាពមិនច្បាស់ពីបែបបទនិងវិធីសាស្ត្រនៃការគណនាលើសពីនេះទៅទៀតអ្នកប្រកាសពន្ធតែងធ្វើប្រកាសពន្ធនៅកំឡុងពេលជិតផុតថ្ងៃកំណត់នៃការបង់ប្រាក់ពន្ធ ដែលជាហេតុធ្វើឱ្យមានភាពកកស្ទះខ្លាំងនៅប៉ុន្មានថ្ងៃចុងក្រោយនៃការបង់ពន្ធ។ដូចនេះយើងសង្ឃឹមថាខាងអគ្គនាយកដ្ឋានពន្ធដារនឹងរកវិធីសាស្ត្រយ៉ាងណាដើម្បីឱ្យអ្នកជាប់ពន្ធមកដាក់លិខិតប្រកាស ឱ្យបានលឿនជាងនេះជៀសវៀងការដាក់លិខិតប្រកាសនៅយឺតពេលដោយធ្វើការផ្តល់ជាបណ្ណសរសើទៅដល់សហគ្រាសណា ដែលធ្វើការបង់ប្រាក់ពន្ធលឿននិងត្រឹមត្រូវជាងគេប្រចាំឆ្នាំព្រមទាំងបន្ថែមចំនួនមន្ត្រីពន្ធដើម្បីឱ្យការទទួល លិខិតប្រកាសពន្ធប្រកបដោយភាពរលូតនិងរហ័សទាន់ចិត្តសម្រាប់អ្នកជាប់ពន្ធ។ ក្នុងនោះដែរអ្នកជាប់ពន្ធទាំងឡាយក៏គួរតែចូលរួមសហការនិងមានមនសិការដាស់តឿនខ្លួនឯងពីភារកិច្ចដែលខ្លួនត្រូវ បំពេញដើម្បីឆ្លើយតបទៅនឹងការខិតខំប្រឹងប្រែងរបស់មន្ត្រីពន្ធដារដូចគ្នាម៉្យាងទៀតដើម្បីបណ្តុះគំនិតដល់ក្មេងជំនាន់ក្រោយខាងអគ្គនាយកដ្ឋានពន្ធដារគួរតែស្នើសុំដល់ក្រសួងអប់រំយុវជននិងកីឡាក្នុងការដាក់បញ្ចូលនូវមុខវិជ្ជាពន្ធដារនេះទៅក្នុងកម្មវិធីសិក្សាដើម្បីឱ្យពួកគេមានការយល់ដឹងពីពន្ធដារពេសេសគឺដឹងពីគោលបំណងនិងសារៈប្រយោជន៍នៃការប្រមូលពន្ធព្រមទាំងភាពជាពលរដ្ឋក្នុងការចូលរួមគោរពច្បាប់ទាក់ទងនឹងការបង្កើតអាជីវកម្មផ្សេងៗនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ លើសពីនេះទៅទៀតអគ្គនាយកដ្ឋានពន្ធដារគួរតែបង្ហាញនូវទិន្នន័យនៃការប្រមូលប្រាក់ពន្ធធៀបនឹងចំណាយផ្សេងៗប្រចាំឆ្នាំដើម្បីផ្តល់ជាទំនុកចិត្តដល់អ្នកជាប់ពន្ធ ដើម្បីជៀសវាងការយល់ច្រឡំនិងមានគំនិតក្នុងការគេចពន្ធដែលនាំឱ្យមានការខាតបង់ដល់ចំណូលជាតិទាំងមូលដែលដាក់ឱ្យប្រើប្រាស់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីសម្រេចបាននូវគម្រោងថវិកាជាតិដែលបានព្រៀងទុកទោះជាយ៉ាងនេះ ក្តីអគ្គនាយកដ្ឋានពន្ធដារគួរតែ

បន្តបង្កើតយុទ្ធសាស្ត្រក្នុងការលើកទឹកចិត្តអ្នកជាប់ពន្ធដើម្បីទាក់ទាញអ្នកវិនិយោគឱ្យចូលមកបង្កើតក្រុមហ៊ុនសកម្មភាពសេដ្ឋកិច្ចក្នុងប្រទេសឱ្យបានច្រើនម៉្យាងវិញ ទៀតការធ្វើទំនើបកម្មសារពើពន្ធគឺជាកត្តាមួយសំខាន់ដែរក្នុងការបង្កើនចំណូលពន្ធព្រោះបើប្រព័ន្ធពន្ធដារបានផ្តល់ ភាពងាយស្រួលដល់អ្នកជាប់ពន្ធយ៉ាងនោះអ្នកជាប់ពន្ធនឹងមានភាពរីករាយក្នុងការបំពេញកាតព្វកិច្ច ជាប្រជាពលរដ្ឋម្នាក់ការផ្តល់សេវាដល់អ្នកជាប់ពន្ធក៏ជាចំណុចមួយដែលអគ្គនាយកដ្ឋានពន្ធដារគួរតែផ្តោចទៅលើផងដែរទាក់ទងនឹងភាពរួសរាយរបស់មន្ត្រីផ្តល់សេវា។ដើម្បីពង្រឹងការប្រមូលចំណូលពន្ធអោយបានអស់លទ្ធភាព អគ្គនាយកដ្ឋានពន្ធដារត្រូវ មានវិធានការចំពោះសហគ្រាសទាំងឡាយណាដែលមិនទាន់បានចុះបញ្ជី អោយបានចុះបញ្ជីទាំងអស់រួមទាំងអាជីវកម្មដ្ឋានតូចៗផងដែរ។ ទោះបីជាសហគ្រាសទាំងនោះមិនទាន់ដល់កម្រិតផលរបរ ត្រូវជាប់ពន្ធក៏ដោយ ការដែលប្រមូលផ្តុំព័ត៌មាននៅក្នុងប្រព័ន្ធតែមួយ គឺងាយស្រួលក្នុងការគ្រប់គ្រង ផ្តល់នូវគណនេយ្យភាព និងតម្លាភាពសម្រាប់អ្នកជាប់ពន្ធផងដែរ។ ម្យ៉ាងវិញទៀតអគ្គនាយកដ្ឋានពន្ធដារត្រូវពង្រឹងបន្ថែមលើការផ្តល់សេវាឱ្យបានប្រសើរឡើងផងដែរទន្ទឹមនឹងនេះ ដែរដើម្បីសម្រេចបំណងនិងគោលដៅដែលបានដាក់ចេញក្នុងផែនការយុទ្ធសាស្ត្រនិងមានការប្រមូលចំណូលពន្ធដារផ្ទៃក្នុងឱ្យកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ចាំបាច់ឱ្យថ្នាក់ដឹកនាំនិងអ្នកចូលរួមអនុវត្តន៍ទាំងអស់មានឆន្ទៈ មុះមុតមានការលះបង់និងការទទួលខុសត្រូវខ្ពស់សំដៅអនុវត្តការងារក្នុងស្មារតីបុរេសកម្ម និងតម្កល់ផលប្រយោជន៍ជាតិនិងអង្គភាពជាធំ។ ក្នុងន័យនេះថ្នាក់ដឹកនាំនិងមន្ត្រីរាជការពន្ធដារគ្រប់លណដាប់ថ្នាក់ត្រូវតែប្រកាន់ខ្ជាប់នូវគុណតម្លៃនៃគោលការណ៍សំខាន់ៗចំនួន៣ គឺ៖ រដ្ឋបាលកិច្ចល្អ ប្រសិទ្ធភាពនៃភាពជាអ្នកដឹកនាំ និងជាពិសេសគុណធិបតេយ្យដែលសំដៅលើការឱ្យតម្លៃខ្ពស់លើទេព្យកោសល្យ សមត្ថភាពការខិតខំប្រឹងប្រែង និងលទ្ធផលការងារលើសពីនេះការខិតខំប្រឹងប្រែងអនុវត្តន៍ការងារក៏ត្រូវតែអនុលោមតាមអភិក្រមការងារ ៤ប្រការ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលរួមមាន៖

១. អនុវត្តការងារដោយវិជ្ជា ជីវៈ និងគោរពក្រមសីលធម៌វិជ្ជាជីវៈ

២. អនុវត្តការងារជាក្រុម

៣. អនុវត្តការងារដោយប្រកាន់ខ្ជាប់ ស្មារតីបុរេសកម្ម និង

៤. មិនត្រូវមើលរំលងកំហុសខ្លួនឯង និងកែតម្រូវកំហុសរបស់ខ្លួន ដោយ អនុលោមតាមអភិក្រមការងារ

៥. យ៉ាងរបស់ប្រមុខរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា គឺ "ឆ្លុះកញ្ចក់ ងូតទឹក ដុះក្អែល ព្យាបាល និងវះកាត់៕

# ឯកសារយោង


១ .A comprehensive study on tax administration, tax policy and impact of tax revenue on economic growth of Cambodia, Build Bright University, 2018

២. គង់ ប៊ុនធីបណ្ណាគារច្បាប់កម្ពុជា ,នីតីសារពើពន្ធធុរកិច្ច .

៣. ហង់ ជួន ណារ៉ុន២០១៥ ,សេដ្ឋកិច្ចកម្ពុជា .

៤. កម្រងលិខិតបទដ្ឋានគតិយុត្តពន្ធដារកម្ពុជា ២០១៦

៥. http://tax.gov.kh

៦ .វិទ្យាស្ថាន វ៉ាន់ដារបាយការណ៍ស្រាវជ្រាវថ្នាក់បរិញ្ញបត្រជាន់ខ្ពស់ជំនាន់១៩របស់និស្សិតឈ្មោះ ម៉ែន វ៉ាន់ឌី

៧. www.tax.gov.kh( 21-10-2023 )

៨. រៀបរៀងដោយសាស្ត្រចារ្យ វ៉ែន ឈុនហួត

# ឧបសម្ព័ន្ធ



## មេរៀនទី១ សញ្ញាណទូទៅនៃពន្ធដារ

I. **លក្ខណៈពិសេស នៃពន្ធដារ**

ផ្តើមចេញពីពេលដែលសង្គមមនុស្ស ត្រូវបានបែងចែកជាវណ្ណៈ មានការតស៊ូវណ្ណៈ និងមានការកើតឡើងនៃរដ្ឋាភិបាល ដើម្បីគ្រប់គ្រងចេនាសម្ព័ន្ធនៃប្រទេសមួយ រហូតមកដល់បច្ចុប្បន្ន ពន្ធដារ ត្រូវបានគេអនុវត្តច្រើនបែបយ៉ាង ហើយកាន់តែទូលំទូលាយ ។

**ពន្ធដារគឺជាអ្វី** ? What is taxation?

១. ពន្ធ គឺជារូបភាពនៃការបែងចែកឡើងវិញ នូវចំណូលជាតិ ដែលរដ្ឋាភិបាលបានប្រើប្រាស់ដើម្បីប្រមូលចំណូល មួយផ្នែកពីគ្រប់សមាសសភាពសេដ្ឋកិច្ច ដូចជា ក្រុមហ៊ុន សហគ្រាស អាជីវកម្ម សិប្បកម្ម ពាណិជ្ជកម្ម...និងប្រជាពលរដ្ឋ ដើម្បីបម្រើឲ្យ តំរូវការរួមរបស់សង្គមជាតិទាំងមូល។

២. ពន្ធ គឺជារូបធាតុ នៃការប្រមូលចំណូលមួយ ដែលផ្សារភ្ជាប់ ជាមួយនិង សិទ្ធអំណាច នយោបាយរបស់រដ្ឋាភិបាល ដែលក្រិត្យច្បាប់បើជាកំណត់ ។

៣. ពន្ធ គឺជាការបង់កាតព្វកិច្ចនូវកាតព្វកិច្ច របស់គ្រប់សមាសភាពសេដ្ឋកិច្ច ដែលរួមទាំងរូបវន្តបុគ្គល និង និតិបុគ្គល ជូនរដ្ឋាភិបាលដែលមានច្បាប់កំណត់។

ពន្ធមានលក្ខណៈបង្ខំ ហើយមិនសងឲ្យវិញផ្ទាល់ឡើយ ប៉ុន្តែនឹងអាចសងឲ្យវិញជាលក្ខណៈរូបភាពប្រយោល ទៅតាមគោលនយោបាយរដ្ឋាភិបាលប្រទេសនីមួយៗ ។ គ្រប់អង្គភាពអាជីវកម្ម ផលិតកម្ម សេវាកម្ម ដែលចំណុះឲ្យគ្រប់សមាសភាពសេដ្ឋកិច្ច ត្រូវមានកាតព្វកិច្ច និងទំនួលខុសត្រូវ ចំពោះមុខច្បាប់រដ្ឋ ក្នុងការអនុវត្តឲ្យបានគ្រប់គ្រាន់ក្នុងនូវពន្ធទាំងឡាយដែលបានកំណត់ ។ និងមានសិទ្ធស្មើៗគ្នា ក្នុងការទទួលមកវិញនូវផលប្រយោជន៍ ពីរដ្ឋាភិបាលដែលប្រកបដោយយុត្តិធម៌ និង ត្រូវបានរដ្ឋាភិបាលបង្កលក្ខណៈងាយស្រួលមកវិញតាមរយៈគោលនយោបាយ ដែលមានចែងក្នុងច្បាប់ ។

ពន្ធបានធ្វើឲ្យមានការផ្លាស់ប្តូរកម្មសិទ្ធនៃប្រភពចំណូលដែលបានប្រមូល ។បន្លាស់ប្តូរកម្មសិទ្ធិនៃប្រភពចំណូលនេះបានកំណត់ដោយមុខងារគ្រប់គ្រងសេដ្ឋកិច្ចរបស់រដ្ឋាភិបាល ហើយបានស្វែងឡើងការឯកភាពគ្នា អំពីគោលចែកផលប្រយោជន៍របស់រដ្ឋជាមួយ និងផលប្រយោជន៍ របស់ក្រុមហ៊ុនអាជីវកម្ម សេវាកម្ម និងប្រជាជនគ្រប់រូប។ នៅក្នុងសេដ្ឋកិច្ចទីផ្សារ ដែលមានសមាសភាពសេដ្ឋកិច្ចច្រើនគោលនយោបាយពន្ធដារត្រូវយកមកប្រើប្រាស់ជាចាំបាច់ ជាទូទៅពន្ធត្រូវបានចាត់ទុកជា ឧបករណ៍ហិរញ្ញវត្ថុមួយយ៉ាងមានប្រសិទ្ធភាព ក្នុងការគ្រប់គ្រងសេដ្ឋកិច្ចហិរញ្ញវត្ថុរបស់រដ្ឋាភិបាល ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសជាតិ ។

II. **លក្ខខណ្ឌ សំខាន់ៗនៃពន្ធដារ**

**ក. ចំពោះការគ្រប់គ្រង**

ពន្ធដារ បានចូលរួមក្នុងការកសាងរបបសេដ្ឋកិច្ចជាតិទាំងមូល ដែលបានគ្រប់គ្រងដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ធ្វើការណែនាំឧបត្ថម្ភចំពោះគ្រប់សមាសភាពសេដ្ឋកិច្ចដោយសារ មូលហេតុនេះហើយរដ្ឋាភិបាល មានលទ្ធភាពគ្រប់គ្រាន់ និងចាំបាច់បែងចែកចំណូលមួយផ្នែក របស់បណ្តាគ្រប់សមាសភាពសេដ្ឋកិច្ច ក្នុងគោលបំណងអនុវត្តន៍នូវគោលការណ៍សេដ្ឋកិច្ចរបស់រដ្ឋាភិបាល ។

**ខ. តំណាក់តំណងរបស់ពន្ធដារ**

គឺជាទំនាក់ទំនងរវាងកាតព្វកិច្ច និងសិទ្ធអំណាចសង្គម ។ ប្រការនេះទាមទារឲ្យគ្រប់សមាសភាព សេដ្ឋកិច្ច និងបុគ្គលមានកាតព្វកិច្ចចំពោះរដ្ឋាភិបាល ។ កាតព្វកិច្ចនោះនៅក្នុងទំនាក់ទំនងហិរញ្ញវត្ថុត្រូវបានអនុវត្តដោយមាត់ បង់ភាគទានមួយផ្នែកប្រាក់ចំណូលដែលពលកម្មភាពរបស់គេបានបង្កើតឡើង។

### គ. លក្ខខណ្ឌចាំបាច់ នៃពន្ធដារ

លក្ខណៈសត្យានុម័ត: ក្រៅពីប្រមូលចំណូលថវិកាជាតិ ពន្ធគឺជាឧបករណ៍ដែលមានប្រសិទ្ធភាពក្នុងការណែនាំ ផលិតកម្ម អាជីវកម្ម សេវាកម្ម ។ បំណែងចែកការប្រើប្រាស់ រួមចំណែកឡើងវិញនូវបញ្ហាការផលិតកម្ម បញ្ហាការសមាសមាត្រចំណូលកាន់តែសមស្រប ។

លក្ខណៈអន្តនោម័ត: អនុវត្តការទប់ស្កាត់ សម្របសម្រួលចំណូលរវាងបណ្តាស្រទាប់ប្រជាជនបុគ្គល ក្នុងការគ្រប់គ្រងសេដ្ឋកិច្ចទីផ្សារ គ្រប់គ្រងបញ្ជីការហិរញ្ញវត្ថុ ថវិកាជាតិ ធ្វើឲ្យមានស្ថេរភាពថ្លៃ និង ចរាចរណ៍ហិរញ្ញវត្ថុ ។

### ឃ. អត្ថប្រយោជន៍ នៃពន្ធដារ

ពន្ធដារមិនត្រឹមតែជាប្រភពចំណូលដ៏សំខាន់របស់ថវិកាជាតិតែមួយមុខប៉ុណ្ណោះនោះទេ ប៉ុន្តែពន្ធដារបានផ្សារភ្ជាប់ជាមួយបញ្ហាទាំងឡាយអំពីការបង្កើនល្បឿនអភិវឌ្ឍសេដ្ឋកិច្ចអំពីសមាសភាពក្នុងការបែងចែកនិងស្ថេរភាពសង្គម។

ប្រសិនបើគោលនយោបាយពន្ធខុសឆ្គង អាចនាំឲ្យមានភាពអន់ថយដល់ល្បឿនសេដ្ឋកិច្ចសង្គម ផ្ទុយទៅវិញបើគោលនយោបាយពន្ធត្រឹមត្រូវ នាំឲ្យមានភាពរុងរឿងសំបូរ និងមានស្ថេរភាពយូរអង្វែងឲ្យប្រទេសជាតិយើង ។

## III. តួនាទីជាមូលដ្ឋានរបស់ពន្ធដារ

ពន្ធដារមានតួនាទីជាមូលដ្ឋានដូចខាងក្រោម ៖

### ១. បង្កើតប្រភពចំណូលថវិកាជាតិ

ឆ្លងតាមរយៈក្រិត្យច្បាប់នានា ច្បាប់សារពើពន្ធ ច្បាប់គ្រប់គ្រងហិរញ្ញវត្ថុ ស្តីអំពីកម្រិតកំណត់អត្រាពន្ធដែលក្រុមហ៊ុន សាជីវកម្ម សេវាកម្ម និង ប្រជាពលរដ្ឋ ដែលជាប់ពន្ធ ត្រូវបង់ពន្ធជូនរដ្ឋហើយប្រាក់នេះ ត្រូវបញ្ចូនចូលក្នុងថវិកាជាតិ តាមប្រភពជាក់ស្តែងផ្សេងៗគ្នា ។ នេះគឺជាតួនាទីសំខាន់ៗរបស់ពន្ធដារ ។ តួនាទីនេះចាប់ផ្តើមពីចំណុចពិសេសអំពីសិទ្ធអំណាចរបស់រដ្ឋាភិបាលក្នុងសង្គម ។ រដ្ឋាភិបាលបានប្រើប្រាស់ សិទ្ធអំណាចខាងរដ្ឋបាល បានដាក់ចេញនូវពន្ធដែលមានចែងបណ្តា ប្រភេទពន្ធ កម្រិតពន្ធ អត្រាពន្ធ ការណែនាំអនុវត្ត និងការកែសម្រួលផ្សេងៗ។

ក្នុងគោលនយោបាយពន្ធរបស់រដ្ឋាភិបាលនៃបណ្តាប្រទេសភាគច្រើន ជាទូទៅបានដាក់ចេញនូវ សំណួរចំនួនបីដែលត្រូវឆ្លើយតប ហើយរាល់ក្រិត្យច្បាប់ ច្បាប់សារពើពន្ធ ត្រូវតែតាមដានថ្លឹងថ្លែងជាប្រចាំដើម្បីឆ្លើយតបនូវសំណួរទាំងឡាយ ។

**ក.** សំណួរពេលបង្កើតប្រភពចំណូលឲ្យថវិកាជាតិ ត្រូវបានស្វែងរកឡើងនូវបរិមាណពន្ធ ដែលប្រមូលបាន និង លទ្ធភាពឆ្លើយតបរបស់វា រាល់តម្រូវការចំណាយរបស់រដ្ឋាភិបាល។

**ខ.** ដើម្បីបង្កើនប្រភពចំណូលថវិកាជាតិ ត្រូវតែកសាងប្រព័ន្ធពន្ធមួយឲ្យបានសមស្រប គ្រប់ជ្រុងជ្រោយ ទៅតាមស្ថានភាពជាក់ស្តែងរបស់សេដ្ឋកិច្ចជាតិ និង ទៅតាមតំបន់សេដ្ឋកិច្ច ។

**គ.** ទន្ទឹមនោះ រដ្ឋាភិបាលត្រូវតែលើកកំពស់ប្រសិទ្ធភាពនៃប្រព័ន្ធក្បាលម៉ាស៊ីនគ្រប់គ្រង និងប្រមូលពន្ធប្រឆាំងនឹងការគេចពន្ធ លួចបន្លំពន្ធ ស៊ីសំណូក ពុករលួយ និងការប្រមូលពន្ធមិនគ្រប់ជ្រុងជ្រោយ ។

### ២. ជំរុញបង្កើនល្បឿនអភិវឌ្ឍន៍សេដ្ឋកិច្ច ហិរញ្ញវត្ថុ

ត្រូវបានស្វែងឡើង នូវការសាងប្រព័ន្ធសមស្របមួយ និងស្វែងរកឡើងនូវបណ្តាការអនុវត្តន៍ដ៏ប្រពៃរបស់ពន្ធដារ ។ នៅបណ្តាប្រទេសដែលកំពុងអភិវឌ្ឍន៍ និងអន់ថយមួយចំនួន ពីមុនក្នុងរយៈពេលដែលនិតន៍លើកកម្ពស់អត្រាពន្ធនៃប្រភពមួយចំនួនដូចជា ៖ **អាករលើផលរបរ ពន្ធលើចំណូលបុគ្គលិក ពន្ធលើប្រាក់ចំណេញ អាករពិសេស**

**លើទំនិញ** និងសេវាមួយចំនួន...ប៉ុន្តែមិនបានយកចិត្តទុកដាក់ដល់ ប្រភេទពន្ធមួយចំនួនទៀតដូចជា: **ពន្ធលើធនធាន ពន្ធលើដីធ្លី**... ដែលនាំឲ្យមានការប្រើប្រាស់ធនធានពាសវាលពាសកាល ឥតសណ្តាប់ធ្នាប់ និងខ្ជះខ្ជាយ ។ ឧទាហរណ៍: ព្រៃឈើត្រូវបានគេកាប់បំផ្លាញ និងខ្ជះខ្ជាយ ធនធាន ហើយដែលជាហេតុបណ្តាលឲ្យនៃធនធានធម្មជាតិដែលជាសម្បត្តិរបស់រដ្ឋ និងអាចបណ្តាលឲ្យមានគ្រោះធម្មជាតិចំពោះប្រទេសជាតិ។

### ៣. ធប់សម្រួលចំណូលរបស់ប្រជាពលរដ្ឋនៅក្នុងសង្គម

-ពន្ធមានតួនាទីយ៉ាងសំខាន់ ក្នុងការរក្សាសមាមាត្ររវាងអ្នកមាននិងអ្នកក្រ កុំឲ្យឃ្លាតឆ្ងាយពីគ្នាពេក ។ មានន័យថា ពន្ធជាចេនកាត់បន្ថយចំណូលរបស់អ្នកដែលមានទ្រព្យធនច្រើន និងបង្កើនប្រភពចំណូលថវិកា ដើម្បីធ្វើការបែងចែកឡើងវិញឲ្យអ្នកក្រីក្រ ដោយខ្លួនកាត់តាមគោលនយោបាយចំណាយរបស់រដ្ឋាភិបាល ។

-រវាងអាជីវករដែលមានទ្រព្យសម្បត្តិ និងចំណូលខ្ពស់ ជាមួយនិងពលរដ្ឋក្រីក្រ ក៏មានទំនាក់ទំនងចំណុះ ឲ្យគ្នា ដើម្បីមានស្ថេរភាពក្នុងសង្គម ។ មានន័យថា នៅពេលដែលមានព្រំដែនមួយនៃការបែងចែកឡើងវិញហើយដែលកម្រិតយល់ដឹងយ៉ាងទាបហើសរបស់អាជីវករ នោះអាជីវករ ប្រជាពលរដ្ឋទាំងអស់បានត្រៀមជាស្រេច រួមវិភាគទានមួយផ្នែកចំណូលរបស់ខ្លួន ឲ្យរាល់សំណូមពររបស់សង្គម។ គេអាចកំណត់ក្របខណ្ឌព្រំដែននោះដោយ ឆ្លងកាត់តាមប្រតិកម្មរបស់បណ្តាអង្គភាពអាជីវកម្ម ផលិតកម្ម សិប្បកម្ម សេវាកម្មនីមួយៗ ។

ដើម្បីទប់ស្កាត់លំចំណូល និងការបែងចែកឡើងវិញនូវចំណូល រវាងបណ្តាលស្រទាប់វណ្ណៈផ្សេងៗគ្នានៅក្នុងសង្គម ជាទូទៅ រដ្ឋាភិបាលបានបង្កើតពន្ធប្រយោល ចំពោះប្រភេទទំនិញ ឬសេវាមួយចំនួន របស់មុខសញ្ញាណាដែលមានចំណូលខ្ពស់ ជំនួសឲ្យការយកពន្ធដោយផ្ទាល់ ។ វិធីសាស្ត្រនេះល្អក្នុងវិស័យគ្រប់គ្រង និងទាំងវិស័យចិត្តសាស្ត្រ ហើយងាយស្រួលនឹងបានទទួលស្គាល់ ។

## IV. មណ្ឌាកត្តារួមផ្សំរបស់ពន្ធ

គោលនយោបាយពន្ធមួយរបស់រដ្ឋាភិបាល ជាទូទៅមានកត្តារួមផ្សំដូចខាងក្រោម៖

### ១.បុគ្គលជាប់ពន្ធ( TAX PAPER)

បុគ្គលជាប់ពន្ធគឺជារូបវន្តបុគ្គល( Natural person ) ឬ នីតិបុគ្គល( legal entities ) ទាំងឡាយដែលបានកត់ត្រាចូលក្នុងបញ្ជី ផលិតកម្ម អាជីវកម្ម សេវាកម្ម...របស់រដ្ឋាភិបាល ហើយពល់សកម្មភាពផ្សេងៗ ត្រូវបានផ្តល់ទទួលស្គាល់ជាសាធារណៈ និងបានកំណត់កាតព្វកិច្ចបង់ពន្ធ ជូនរដ្ឋាភិបាលទៅតាមការកំណត់របស់អង្គការពន្ធ។

-បុគ្គលជាប់ពន្ធគឺជាបុគ្គលដែលទទួលរងពន្ធដោយផ្ទាល់ និងមានកាតព្វកិច្ចត្រូវបង់ពន្ធដោយផ្ទាល់ទៅអង្គការពន្ធទៅតាមច្បាប់ដែលបានកំណត់។

-បុគ្គលទទួលរងពន្ធគឺជាបុគ្គលដែលមានចំណូល ហើយទទួលការជះឥទ្ធិពលដោយប្រយោលពីពន្ធ។

### ២.មូលដ្ឋានគិតពន្ធ( THE BASIS OF TAXES)

មូលដ្ឋានគិតពន្ធ គឺជាទំហំចំណូលទាំងឡាយដែលចំណុះឲ្យសកម្មភាព ផលិតកម្ម អាជីវកម្ម សេវាកម្ម សិប្បកម្ម ពាណិជ្ជកម្ម និងសកម្មភាពផ្សេងៗទៀត ដែលត្រូវបានចាត់ទុកជាមូលដ្ឋាន ដើម្បីគណនាពន្ធអាករ។ មូលដ្ឋានគិតពន្ធប្រែប្រួលទៅតាមប្រភេទពន្ធនីមួយៗ។

គេអាចកំណត់ប្រភេទពន្ធនីមួយៗ ផ្សេងៗគ្នា ដោយផ្អែកលើ មូលដ្ឋានគិតពន្ធខុសៗគ្នា។ ឧទាហរណ៍: ពន្ធកសិកម្ម អាករលើផលរបរ ពន្ធលើប្រាក់ចំនេញ អាករពិសេសលើទំនិញ និងសេវាមួយចំនួន ពន្ធសត្តឃាត។

### ៣.អត្រាពន្ធ( TAX RATE)

អត្រាពន្ធគឺ ជាកម្រិតដែលកំណត់ទៅលើមូលដ្ឋានគិតពន្ធ ដើម្បីធ្វើជា បង្អែកក្នុងការគណនាប្រាក់ពន្ធអាករ។ អត្រាពន្ធ គឺជាកម្រិតដែលបានកំណត់ ត្រូវតែបង់ពន្ធជូនរដ្ឋាភិបាល នៅលើមួយឯកតាមូលដ្ឋានគិតពន្ធ។

អត្រាពន្ធបែកចេញជាច្រើនប្រភេទដូចជា:

ក. អត្រាពន្ធគិតតាមសមាមាត្រជាភាគរយ គឺជាអត្រាពន្ធ ប្រមូលតាមសមាមាត្រជាភាគរយ ទៅលើមូលដ្ឋានគិតពន្ធ នៃប្រភេទ ពន្ធនីមួយៗ ។

ខ. អត្រាពន្ធកំណើនតាមថ្នាក់ គឺជាអត្រាពន្ធដែលគណនាទៅតាមសមាមាត្រជាភាគរយ ហើយដែលកើនឡើងជាបន្តបន្ទាប់ ព្រមជាមួយនឹងការកើនឡើងនៃចំណូលជាប់ពន្ធ របស់បុគ្គលជាប់ពន្ធ។

គ. កម្រិតប្រមូលថេរ គឺជាកម្រិតប្រមូលថេរ ទៅលើឯកតាផលិតផលទំនិញ អចលនទ្រព្យផ្សេងៗ ដែលត្រូវជាប់ពន្ធ។

**៤.ឯកតាគិតពន្ធ**( THE UNIT OF TAX)

ឯកតាគិតពន្ធ គឺជាឯកតាដែលត្រូវបានប្រើប្រាស់ដើម្បីធ្វើជាមធ្យោបាយទូទាត់ពន្ធ។ យោងតាមប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រឹតច្បាប់ និងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ ឯកតាគិត ពន្ធត្រូវបានគិតជាប្រាក់រៀល និងប្រាក់ដុល្លារ ប៉ុន្តែមានប្រភេទសមួយចំនួនអាចគិតជា វត្ថុ ឧទាហរណ៍ គិតជាគីឡូក្រាម។

**៥.តម្លៃគិតពន្ធ**

តម្លៃគិតពន្ធគឺជាថ្លៃទីផ្សារ ឬថ្លៃ CIF(Cost Insurance and Freight) FOB(Free On Board) ដែលមានកត់ត្រានៅក្នុងវិក័យប័ត្រ ដោយខ្លួនកាត់តាម SGS(Societe Generale de Surveillance) ឬជាតម្លៃដែល ត្រូវបានកំណត់ឡើងដោយ អង្គការគយ ចំពោះប្រភេទទំនិញ ដែលត្រូវបានអនុញ្ញាតិ ឲ្យ ធ្វើការនាំចេញ នាំចូលដោយខ្លួនកាត់តាមព្រំដែន។

តម្លៃគិតពន្ធ គឺជាថ្លៃទីផ្សារ ឬជាតម្លៃដែលកំណត់ដោយក្រសួងហិរញ្ញវត្ថុ ទៅលើទ្រព្យសម្បត្តិ ផលិតផលទំនិញ ឬសេវា និងមធ្យោបាយដឹកជញ្ជូន ដែលត្រូវជាប់ពន្ធ របស់បុគ្គលជាប់ពន្ធ។

**៦.ការលើកពន្ធ**( TAX EXEMPTION)

ការលើកលែងពន្ធ គឺជាការកំណត់ទាំងឡាយរបស់រដ្ឋាភិបាលដែលមានចែងក្នុងច្បាប់ អំពីការជៀសបង់ពន្ធដែលជាផលប្រយោជន៍ដល់បុគ្គលជាប់ពន្ធ។

-ពល់ករណីដែលត្រូវបានលើកលែងពន្ធទាំងស្រុង ឬក៏ត្រូវបានលើកលែងពន្ធមួយផ្នែក អាស្រ័យទៅតាមលក្ខណៈសម្បត្តិរបស់អាជីវកម្ម។

-ការលើកលែងពន្ធបានស្នែងតាមរយៈគោលនយោបាយរបស់រដ្ឋាភិបាល ចំពោះបុគ្គលជាប់ពន្ធ ដើម្បីលើកទឹកចិត្តដល់អ្នកវិនិយោគ ក្នុងស្រុក និងបរទេស ផលិតកម្ម អាជីវកម្ម សេវាកម្ម និង អនុវត្តន៍ សមភាពសង្គម។

**៧.របបបង់ពន្ធ**

របបបង់ពន្ធ គឺជាការកំណត់ទទួលខុសត្រូវជាធរមាន និងរបៀបផែននៃការបង់ពន្ធចូលថវិការដ្ឋ របស់បុគ្គលជាប់ពន្ធ។ គឺជារបបបទ ធ្វើលិខិតប្រកាស ជូនទៅអង្គការពន្ធ តាមកាលកំណត់ នៃប្រភេទពន្ធនីមួយៗ និងជាវិធីសាស្ត្រប្រមូលប្រាក់ពន្ធ ដែលភ្ជាប់ជាមួយក្របខណ្ឌនៃសិទ្ធអំណាច ការទទួលខុសត្រូវនៃស្ថាប័នទាំងឡាយ ដែលមានការពាក់ព័ន្ធ ។


សាងសង់សាលារៀន
For building schools
សាងសង់ផ្លូវ
For building roads
ការពារព្រំដែន
For defending borders & heritages
បើកប្រាក់ខែជូនកងទ័ព និងកម្លាំងប្រដាប់អាវុធ
For paying salary for soldiers and armed forces
ចំណាយទូទៅ សង្គមកិច្ច សេដ្ឋកិច្ច និងអភិវឌ្ឍ
General expenditure, Social affairs, Economic and Development
បើកប្រាក់ខែជូនមន្ត្រីរាជការ
For paying salary for civil servants
សាងសង់មន្ទីរពេទ្យ
For building hospitals
សាងសង់ស្ពាន
For building bridges
ចំណូលពន្ធដារ ដើម្បី
Tax Revenues for


ចំណូលពីពន្ធដារ
សម្រាប់ការអភិវឌ្ឍគ្រប់វិស័យ
បើកប្រាក់ខែជូនមន្ត្រីរាជការ
For paying salary for civil servants
សាងសង់មន្ទីរពេទ្យ
For building hospitals
បើកប្រាក់ខែជូនកងទ័ព និងកម្លាំងប្រដាប់អាវុធ
For paying salary for soldiers and armed forces
សាងសង់ផ្លូវ
For building roads
ចំណូលពី ពន្ធដារ TAXES សម្រាប់ការអភិវឌ្ឍគ្រប់វិស័យ
សាងសង់ស្ពាន
For building bridges
ការពារព្រំដែន
For defending borders & heritages
ចំណាយទូទៅ សង្គមកិច្ច សេដ្ឋកិច្ច និងអភិវឌ្ឍ
សាងសង់សាលារៀន
For building schools
ការបង់ពន្ធជូនរដ្ឋ គឺជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ចំណូលពីពន្ធគឺដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេសកម្ពុជារបស់យើងទាំងអស់គ្នា
Paying Tax is the obligation for all Cambodian people. Tax is contributed to the development of our nation!






មជ្ឈមណ្ឌលពិគ្រោះយោបល់របស់អគ្គនាយកដ្ឋានពន្ធដារ (Call Center)




